ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ ឯកសារដើមនិងអ្នកដែលឆ្លងកាត់របបខ្មែរក្រហមជាឯកសារដ៏មានតម្លៃ

◆ និស្សិតនាយទាហានរៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៤៥ ខែមករា ឆ្នាំ២០១២

# ស្វែងរកការពិត

លេខ១៨៥ ខែមករា ឆ្នាំ២០១២

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

### មាតិកា

◆ទស្សនាវដ្តីអំពីប្រវត្តិសាស្ត្រ ....................................... ១
◆ការបង្កើតក្រុមឯកសារកម្ពុជា ....................................... ២

**ផ្នែកឯកសារ**

◆ពង្រឹងគោលជំហរឯករាជ្យ-ម្ចាស់ការ ....................................... ៧

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ប្រវត្តិសាស្ត្រដៅទិសអនាគត ....................................... ១៤
◆ម្តាយនិងកូនជាប់គុកនៅភ្នំទ្រយោង ....................................... ១៦
◆អតីតសន្តិសុខវ័យក្មេងនៅគុកភ្នំទ្រយោង ....................................... ១៨
◆អ្នករៀបចំម្ហូបសម្រាប់ ខៀវ សំផន ....................................... ២១
◆គណៈឃុំខ្មែរក្រហមគាំទ្រឲ្យមានការ ....................................... ២៣
◆ទុយ អោម អតីតអនុលេខាស្រុក ....................................... ២៥
◆ការប្រមាថទៅលើព្រះពុទ្ធសាសនា ....................................... ២៧
◆និស្សិតនាយទាហានវិទ្យាស្ថានកងទ័ព ....................................... ២៩
◆ឃ្លាំមើលមើលសាលាក្តីខ្មែរក្រហម ....................................... ៣៦

**ផ្នែកច្បាប់**

◆សាច់រឿងពាក់កណ្តាល ឬកប់ភ័ស្តុតាងចោល? ....................................... ៣៧

**វេទិកាពិភាក្សាសាធារណៈ**

◆យុត្តិធម៌ជាមូលដ្ឋានគ្រឹះសម្រាប់ការផ្សះផ្សា ....................................... ៤៦
◆ការពិនិត្យមើលសាឡើងវិញលើការបរបោះឆ្នោត ....................................... ៥០

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ កំណាប់ឯកសារជីវិត ....................................... ៥៩



សិស្សានុសិស្សតម្រង់ជួរចូលបន្ទប់សវនាការ

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ** : សុខ វណ្ណៈ, ហ៊ិន សុផានី, រី លក្ខិណា, គាត លក្ខិណា, ពៅ ពុទ្ធារី, លី សុខឃាង, តាឆាណា សែណាទី, ហ្សារីតា ហ្គ្រុយប៊ឺច, ស៊ីវ ហេឌី **អ្នកនិពន្ធនិងស្រាវជ្រាវ** : ទាវ សារៈមុនិន្ទ, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែ** : ទែន សុខស្រីនិត **និពន្ធនាយកទូទៅ** : ឆាំង យុ **ជំនួយការនិពន្ធនាយក** : ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រ** : ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ** : ម៉ម សុផាត Email: dccam@online.com.kh, Homepage: www.dccam.org

# ឯកសារដើមនិងអ្នកដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមជាឯកសារដ៏មានតម្លៃ

ក្នុងខែមករានេះ នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា លោក វ៉ាន់ថាន់ ពៅដារ៉ា បានធ្វើសក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអំពីភាពដែលអាចទុកចិត្តបាន និងយថាភាពនៃឯកសារដែលមជ្ឈមណ្ឌលមាន ហើយសព្វថ្ងៃ ឯកសារទាំងនេះកំពុងប្រើប្រាស់នៅសាលាក្តីខ្មែរក្រហមក្នុងករណី០០២ ។ លោក វ៉ាន់ថាន់ ពៅដារ៉ា បានផ្តល់សក្ខីកម្មថា ឯកសារទាំងអស់នៅក្នុងបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺសុទ្ធតែជាឯកសារពិតប្រាកដដែលបង្កើតឡើងដោយរបបខ្មែរក្រហម ។ សាលាក្តីខ្មែរក្រហមក៏បានទទួលស្គាល់ឯកសារទាំងអស់នេះដែរ ដោយក្នុងឆ្នាំ២០១០ សាលាក្តីនេះបានទទួលស្គាល់មជ្ឈមណ្ឌលឯកសារកម្ពុជាថាជាម្ចាស់ជំនួយសប្បុរសមួយដែលបានផ្តល់ឯកសារជាងប្រាំសែនទំព័រចាប់តាំងពីឆ្នាំ២០០៦មក ។ ទោះជាយ៉ាងនេះក្តី ក្រុមការពារក្តីរបស់ជនជាប់ចោទបានជំទាស់ទៅនឹងការដាក់បញ្ចូលឯកសារទាំងអស់នេះដើម្បីយកមកជំនុំជម្រះទោសកូនក្តីរបស់ខ្លួន ។

នួន ជា បានជំទាស់ទៅនឹងឯកសារមួយចំនួនដែលបង្កើតឡើងក្នុងសម័យដែលខ្លួនធ្លាប់ដឹកនាំ ។ នួន ជា ក៏ជំទាស់មិនទទួលស្គាល់ឯកសារដែលស្កេនចេញពីឯកសារដើមនៃសៀវភៅ «ទង់បដិវត្ត» ដែរ ដោយអះអាងថា ឯកសារនោះមិនមែនជាឯកសារពិតទេ ហើយទាមទារឲ្យអង្គជំនុំជម្រះយកឯកសារដើមមកបង្ហាញគាត់ដោយផ្ទាល់ ។ តាមពិត នួន ជា ស្គាល់សៀវភៅ «ទង់បដិវត្ត» នេះច្បាស់ណាស់ ព្រោះគាត់គឺជាអ្នកនិពន្ធម្នាក់របស់សៀវភៅនេះជាមួយ ប៉ុល ពត ដែលបានបោះពុម្ពផ្សាយជាប្រចាំដើម្បីចែកជូនដល់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ។ នួន ជា ផ្ទាល់ធ្លាប់ចាត់ទុកថា សៀវភៅនេះមានតម្លៃណាស់ដែលសមាជិកបក្សម្នាក់ៗត្រូវតែត្រូវឲ្យអានដើម្បីជ្រួតជ្រាបពីមាគ៌ាដឹកនាំរបស់បក្ស ។ ពេលនេះមជ្ឈមណ្ឌលឯកសារកម្ពុជាចាត់ទុកថា ឯកសារដែលនៅសេសសល់ទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យពិតជាមានសារសំខាន់ និងមានតម្លៃមិនអាចខ្វះបាន ហើយឯកសារទាំងអស់នោះគឺជាប្រភពព័ត៌មានដ៏ចាំបាច់មួយ ដើម្បីឲ្យសាធារណជនដឹងពីអ្វីដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយឯកសារទាំងនោះមានតម្លៃសម្រាប់ឲ្យក្មេងកម្ពុជាជំនាន់ក្រោយរៀនសូត្រពីអ្វីដែលបានកើតឡើងចំពោះឪពុកម្តាយ និងជីដូនជីតារបស់ខ្លួន ។ ឯកសារទាំងអស់នោះអាចធ្វើឲ្យក្មេងជំនាន់ក្រោយដឹងពីគោលនយោបាយដែលធ្វើឲ្យប្រជាជនកម្ពុជាជិតពីរលាននាក់ស្លាប់បាត់បង់ជីវិត ។

នួន ជា ប្រហែលជាមិនមានភាពស្រណុកក្នុងខ្លួនទេ ដែលឯកសាររបស់របបកម្ពុជាប្រជាធិបតេយ្យនៅសេសសល់យ៉ាងសន្ធឹកសន្ធាប់បែបនេះ ជាពិសេសសៀវភៅ «ទង់បដិវត្ត» ។ អ្វីដែល នួន ជា អះអាងនៅក្នុងបន្ទប់សវនាការខុសគ្នាស្រឡះទៅនឹងអ្វីដែលគាត់សរសេរឬអ្វីដែលបានសរសេរនៅក្នុងសៀវភៅ «ទង់បដិវត្ត» ។

ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺជាឯកសារក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនិងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហមនិងសម័យក្រោយមកទៀត ។

ឯកសារទាំងអស់នោះមានតម្លៃប្រហាក់ប្រហែលនឹងជីវិតមនុស្សដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហមដែរ ។ ទោះបីជាសាលាក្តីខ្មែរក្រហមអាចឬក៏មិនអាចលាតត្រដាងពីការពិតនៃប្រវត្តិសាស្ត្រដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានក៏ដោយ ឯកសារទាំងអស់នេះ ព្រមទាំងបទសម្ភាសន៍ជាមួយអ្នកធ្លាប់ឆ្លងកាត់របបខ្មែរក្រហមនៅតែមានមានសារសំខាន់មិនអាចកាត់ថ្លៃបានជាប្រវត្តិសាស្ត្រដើម្បីឆ្លុះបញ្ចាំងពីតថភាពក្នុងរបបខ្មែរក្រហម ។ **ញាណ សុជាតិ**



# ការចងក្រងឯកសារកម្ពុជា

ការចងក្រងឯកសារ និងការថែរក្សារឿងរ៉ាវទាក់ទងនឹងការរំលោភសិទ្ធិមនុស្សដែលបង្កឡើងដោយរបបផ្តាច់ការនានាពិតជាមានសារសំខាន់ណាស់ដើម្បីដឹងអំពីអ្វីដែលបានកើតឡើង ធានាឲ្យមានការទទួលខុសត្រូវ រក្សាការចងចាំ និងដើម្បីបង្ហាញពីការពិតឲ្យកាន់តែច្បាស់ ។ បណ្ណសារដែលបានប្រមូលឯកសារ និងភ័ស្តុតាងអំពីការរំលោភសិទ្ធិមនុស្សអាចអនុញ្ញាតឲ្យតុលាការ និងអ្នកស្រាវជ្រាវទូទៅធ្វើការវិភាគអំពីទស្សនៈប្រវត្តិសាស្ត្រដែលកំពុងតែមានភាពចម្រូងចម្រាស ដើម្បីកំណត់ឲ្យច្បាស់អំពីការទទួលខុសត្រូវ និងស្តារមកវិញនូវសិទ្ធិជាមូលដ្ឋានក្នុងការដឹងរឿងរ៉ាវពីអតីតកាលសម្រាប់ជនរងគ្រោះ ។

ដោយសារការចងក្រងឯកសារមានសារសំខាន់បែបនេះ ដំណើរការចងក្រងឯកសារនិងការថែរក្សាឯកសារទាំងនោះគឺមានលក្ខណៈស្មុគស្មាញនិងចម្រូងចម្រាសខ្លះ ។ ចំណោទបញ្ហាសាមញ្ញនោះគឺថា តើត្រូវរក្សាទុកបណ្ណសារនោះនៅកន្លែងណា នរណាជាអ្នកមើលការខុសត្រូវបណ្ណសារទាំងនោះ ហើយតើគួរឲ្យមានការអនុញ្ញាតមើលឯកសារនោះយ៉ាងដូចម្តេច ពេលដែលឯកសារនោះត្រូវការកន្លែងសុវត្ថិភាពដូចដើម និងត្រូវលាក់ពីអត្តសញ្ញាណរបស់សាក្សីនៅក្នុងឯកសារផងនោះ ។ ម្យ៉ាងវិញទៀត អស្ថិរភាពនយោបាយដែលកើតឡើងក្រោយរបបឃោរឃៅ គឺជាការបន្អាក់ដំណើរការចងក្រងឯកសារ និងជួនកាលការចងក្រងឯកសារពីអតីតកាលនោះអាចមានភាពគ្រោះថ្នាក់ផង ។

កម្ពុជាគឺជាឧទាហរណ៍មួយស្រាប់ ។ កាលពីបីទសវត្សរ៍កន្លងទៅ ខ្មែរក្រហមបានបង្កឲ្យមានភាពទុក្ខសោកក្នុងកម្រិតមួយដែលមិនអាចនឹកស្មានដល់ចំពោះប្រជាជនកម្ពុជា ។ ប្រជាជនកម្ពុជាជាងមួយភាគបួនបានស្លាប់ដោយស្នាដៃខ្មែរក្រហមតាមរយៈការវាយដំ ការធ្វើទារុណកម្ម ការធ្វើការហួសកម្លាំង និងការមិនឲ្យហូបឆ្អែត ។ តាមពាក្យពេចន៍ដែលបានរៀបរាប់នៅក្នុងភ្លេងជាតិរបស់ខ្មែរក្រហម ប្រទេសកម្ពុជាបានក្លាយជា “ឈាមក្រហមឆ្អៅស្រោចស្រពក្រុងវាលកម្ពុជាមាតុភូមិ” ។ ខ្មែរក្រហមបានប្រែក្លាយប្រទេសឲ្យធ្លាក់ចូលនៅក្នុងសភាពទាសកម្មសម័យទំនើប ដោយបំបាត់លុយកាក់ ទីផ្សារ កម្មសិទ្ធិឯកជន ទោះនៅក្នុងគ្រួសារក្តី ក្នុងគោលបំណងបំផ្លាញនូវភាពជាបុគ្គលទាំងអស់ ។ មុននឹងកងទ័ពវៀតណាមដណ្តើមយកបានទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៩ រដ្ឋាភិបាលខ្មែរក្រហមបានបំផ្លិចបំផ្លាញឯកសាររបស់ខ្លួនអស់ជា

ច្រើន តែមិនមែនទាំងអស់ទេ ។ នាពេលបច្ចុប្បន្ននេះ ឯកសារខ្មែរក្រហមដែលមាននៅក្នុងប្រទេសកម្ពុជា និងនៅបរទេសត្រូវបានប្រមូលចងក្រងទុក ហើយឯកសារទាំងនោះកំពុងតែប្រើប្រាស់ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ អត្ថបទនេះនឹងបញ្ជាក់អំពីការចងក្រងឯកសារនៅទីកន្លែងផ្សេង និងដាច់ដោយឡែកពីគ្នាចំនួនប្រាំកន្លែងទាក់ទងនឹងរបបខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា ។ ក្នុងចំណោមកន្លែងទាំងប្រាំនោះ បីកន្លែងត្រូវបានចងក្រងរួចហើយ មួយកន្លែងកំពុងតែចាប់ផ្តើមស្រាវជ្រាវ និងមួយកន្លែងទៀតកំពុងតែស្ថិតនៅក្នុងផែនការនៅឡើយ ។

## សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង


ឯកសារនៅសារមន្ទីរទួលស្លែង

នៅពេលដែលកងទ័ពវៀតណាមមកដល់ទីក្រុងភ្នំពេញ កងទ័ពទាំងនោះបានរកឃើញមន្ទីរឃុំឃាំងស-២១ និងឯកសារដ៏សន្ធឹកសន្ធាប់ដែលត្រូវបានចងក្រងយ៉ាងល្អិតល្អន់ទាក់ទងទៅនឹងការឃុំឃាំង ការធ្វើទារុណកម្ម និងការសម្លាប់អ្នកទោសប្រមាណជាង១៤,០០០នាក់ ។ ក្នុងឆ្នាំ១៩៨០ មន្ទីរស-២១ត្រូវបានប្តូរទៅជាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។ ក្នុងឆ្នាំ១៩៩២ ឯកសារដ៏មានតម្លៃទាំងនោះ ដែលរួមមានចម្លើយសារភាពចំនួន ៤,០០០ ដែលសរសេរដោយអ្នកដែលបានស្លាប់នៅមន្ទីរស-២១ និងរូបថតចំនួន៦,១៤៧សន្លឹក ត្រូវបានចុះកាតាឡុក ស្កេន និងថតជាម៉ៃក្រូហ្វីលដោយសាកលវិទ្យាល័យខនេល សហរដ្ឋអាមេរិក ។ មុននឹងកិច្ចការទាំងអស់នេះត្រូវបានធ្វើឡើង ចម្លើយសារភាពនិងរូបថតទាំងនោះត្រូវបានបំផ្លាញដោយធម្មជាតិ អ្នកស្រាវជ្រាវ និងអ្នកប្រមាញ់រកវត្ថុអនុស្សាវរីយ៍ ។ បច្ចុប្បន្ននេះ ឯកសារថតចម្លងម៉ៃក្រូហ្វីលទាំងនោះ ត្រូវបានរក្សាទុកនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មជ្ឈមណ្ឌលឯកសារកម្ពុជា សាកលវិទ្យាល័យខនេល និងសាកលវិទ្យាល័យយែល ។ ឯកសារដើមត្រូវបានការពារដោយសុវត្ថិភាពនៅក្នុងបន្ទប់ដែលមានបរិយាកាសល្អ ។ ឯកសារទាំងអស់នេះគឺជាប្រភពឯកសារដើមនៃភស្តុតាងនៅក្នុងសវនាការជំនុំជម្រះករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលជាអតីតប្រធានមន្ទីរស-២១ កាលពីឆ្នាំ២០១០ ។ ដោយសារតែវត្តមានរបស់ឯកសារនោះហើយ ទើបធ្វើឲ្យ ឌុច សារភាពនូវអ្វីដែលគាត់បានធ្វើ និងធ្វើឲ្យ ឌុច ត្រូវបានយកមកកាត់ទោស និងរកឃើញថាមានកំហុស ។

## មជ្ឈមណ្ឌលឯកសារកម្ពុជា

មជ្ឈមណ្ឌលឯកសារកម្ពុជាបានក្លាយជាស្ថាប័នឯករាជ្យក្រៅរដ្ឋាភិបាលមិនរកប្រាក់ចំណេញមួយ នៅក្នុងឆ្នាំ១៩៩៧ ក្រោយពីបានដំណើរការជាសាខាមួយនៃកម្មវិធីអំពើប្រល័យពូជសាសន៍កម្ពុជារបស់សាកលវិទ្យាយែលនៅសហរដ្ឋអាមេរិក អស់រយៈពេលពីរឆ្នាំរួចមក ។ នៅក្នុងឆ្នាំ១៩៩៩ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលលិខិតអនុញ្ញាតជាផ្លូវការមួយពីរាជរដ្ឋាភិបាលកម្ពុជាដែលស្នើឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាចុះប្រមូលនិងចងក្រងឯកសារទាំងឡាយដែលនៅសេសសល់ពីរបបខ្មែរក្រហមទាំងនៅក្នុងប្រទេសកម្ពុជានិងក្រៅប្រទេស ។ តាំងពីពេលនោះមក មជ្ឈមណ្ឌលឯកសារកម្ពុជា បានចាប់ដៃគូជាមួយស្ថាប័នអប់រំផ្សេងៗ ក្រុមអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិទាំងឡាយ ព្រមទាំងសហការជាមួយប្រទេសផ្តល់ជំនួយមួយចំនួនដើម្បីអភិវឌ្ឍនិងបង្កើតបណ្ណសារដ្ឋានដ៏ធំមួយទាក់ទងនឹងរបបខ្មែរក្រហម ។

បច្ចុប្បន្ន ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានចំនួនជាងមួយលានទំព័រដែលក្នុងនោះរួមមាន កំណត់ហេតុអង្គប្រជុំ របាយការណ៍ផ្សេងៗ សំណេររបស់ថ្នាក់នាំខ្មែរក្រហម សៀវភៅកំណត់ហេតុប្រចាំថ្ងៃ សៀវភៅសរសេរផ្សេងៗ ទស្សនាវដ្តីបក្សនិងរដ្ឋ ឯកសារពាក់ព័ន្ធទៅនឹងរដ្ឋាភិបាលបរទេស និងឯកសារសម្ងាត់របស់សន្តិបាលជាងមួយពាន់ឯកសារ ។ ឯកសារសម្ងាត់

នេះរួមមាន ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម និងអ្នកទោសនៅតាមមន្ទីរសន្តិសុខដែលបានប្រមូលពីទីតាំងផ្សេងក្រៅពីគុកទួលស្លែង ។ បច្ចុប្បន្ន មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែព្យាយាមធ្វើយ៉ាងណាឲ្យឯកសារទាំងអស់របស់ខ្លួនអាចប្រើប្រាស់បាន និងស្រាវជ្រាវឃើញនៅតាមប្រព័ន្ធអ៊ិនធឺណែត ។ បញ្ជីឯកសារទាំងនេះត្រូវបានបង្កើតរួចហើយនៅលើគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាៈ http://d.dccam.org/Database/Index1.htm

ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក៏នៅមានព័ត៌មានផ្សេងៗ ទាក់ទងទៅនឹងរណ្តៅសាកសពចំនួន ២០,០០០ កន្លែង គុកចំនួន ១៩៥កន្លែង និងបូជនីយដ្ឋានចំនួន ១២៨កន្លែង ។ បូជនីយដ្ឋានចំនួន៨០កន្លែងត្រូវបានកសាងដោយរដ្ឋាភិបាលកម្ពុជា និង៤០កន្លែងត្រូវបានកសាងឡើងដោយបុគ្គលឯកជន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានរូបថតចំនួន ៦០,០០០សន្លឹកទាក់ទងទៅនឹងសម័យខ្មែរក្រហម (រូបទាំងនេះមិនមែនបានមកពី




សារមន្ទីរទួលស្លែងទេ) និងកុនឯកសារចំនួន២៦០រឿងដែលបានផលិតឡើងនៅក្នុងសម័យខ្មែរក្រហម និងសម័យក្រោយៗមកទៀត ។ ឯកសារទាំងនេះត្រូវបានប្រមូលនៅក្នុងប្រទេសកម្ពុជា និងមកពីក្រៅប្រទេសរួមមាន ប្រទេសស៊ុយអ៊ែដ ន័រវេ៉ និងប្រទេសហូល្លង់ ។ ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានរួមបញ្ចូលនូវញត្តិផ្សេងៗ ដែលបានចុះហត្ថលេខាដោយអ្នកនៅរស់ពីសម័យខ្មែរក្រហមជាងមួយលាននាក់ ដែលបានរៀបរាប់អំពីទុក្ខវេទនាដែលខ្លួនបានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហម ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានអត្ថបទសម្ភាសន៍ចំនួន៥០,០០០នាក់ដែលបានចុះសម្ភាសន៍ជាមួយជនរងគ្រោះ និងជនដៃដល់ក្នុងរយៈពេលជាងដប់ប្រាំឆ្នាំមកនេះ ។

លើសពីនេះទៅទៀត តាំងពីឆ្នាំ២០០៦មក មជ្ឈមណ្ឌលឯកសារកម្ពុជាបានសហការជាមួយសាកលវិទ្យាល័យណ័រវេស្ទឺននៅសហរដ្ឋអាមេរិក ដើម្បីចងក្រង និងផ្សព្វផ្សាយរាល់ឯកសារទាំងអស់របស់តុលាការខ្មែរក្រហមដែលរួមមាន វីដេអូដំណើរការសវនាការជាភាសាបារាំង ខ្មែរ និង អង់គ្លេស អត្ថបទវិភាគប្រចាំថ្ងៃ អត្ថបទកាសែត មតិយោគបល់របស់អ្នកជំនាញ ព្រមទាំងរូបភាពវីដេអូសម្ភាសន៍ជាមួយភាគីដើមបណ្តឹងរដ្ឋប្បវេណី និងប្រជាជនកម្ពុជាផ្សេងៗទៀត ។ ទាំងអស់នេះត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រ www.cambodiatribunal.org ។ ឯកសារមួយភាគធំរបស់តុលាការខ្មែរក្រហមដែលជាឯកសារសម្ងាត់ត្រូវបានផ្តល់ជូនដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដោយឥតគិតថ្លៃ ។ តុលាការខ្មែរក្រហមបានទទួលស្គាល់មជ្ឈមណ្ឌលឯកសារកម្ពុជា ថាជាអ្នកផ្តល់ជំនួយដ៏ធំមួយរបស់ខ្លួនដែលមានទឹកប្រាក់រហូតដល់ទៅបីសែនដុល្លារសហរដ្ឋអាមេរិក ។

បណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាគ្រឹះស្ថានស្រាវជ្រាវដ៏សំខាន់មួយ និងជាប្រភពភស្តុតាងដ៏ធំមួយរបស់តុលាការខ្មែរក្រហម ។ ក៏ប៉ុន្តែ ក្រោយពីតុលាការខ្មែរក្រហមត្រូវបានបញ្ចប់ ឯកសារទាំងនេះនឹងជាជំនួយដល់ការស្រាវជ្រាវ និងការអប់រំផ្សេងៗជាច្រើនបែបដែលមានបំណងបំពេញនូវសិទ្ធិចង់ដឹងអំពីការពិតចំពោះការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរនៅក្នុងសម័យខ្មែរក្រហម ។ ឧទាហរណ៍ មជ្ឈមណ្ឌលឯកសារកម្ពុជាបាន

បោះពុម្ពផ្សាយសៀវភៅស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ហើយកំពុងតែសហការជាមួយក្រសួងអប់រំ ដើម្បីបណ្តុះបណ្តាលគ្រូបង្រៀន និងបញ្ចូលមេរៀនខ្មែរក្រហមទៅក្នុងកម្មវិធីសិក្សាជាតិ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានធ្វើកិច្ចការផ្នែកផ្សព្វផ្សាយព័ត៌មានជូនតុលាការខ្មែរក្រហមដែរ ព្រមទាំងបានស្រាវជ្រាវ និងបោះពុម្ពសៀវភៅជាច្រើនច្បាប់ជាភាសាខ្មែរ និងអង់គ្លេស ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានផលិតកុនឯកសារមួយចំនួនដែរ ។ បច្ចុប្បន្ន មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែប្រមូលឈ្មោះ និងប្រវត្តិរូបអ្នកដែលបានស្លាប់ និងបាត់ខ្លួននៅក្នុងរបបខ្មែរក្រហមដែលសព្វថ្ងៃមានឈ្មោះជាងមួយលានរួចមកហើយ ។ បញ្ជីឈ្មោះទាំងនេះនឹងត្រូវបោះពុម្ពជាសៀវភៅដ៏ក្រាស់មួយ ហើយនឹងចែកជូនតាមសាលាឃុំផ្សេងៗទូទាំងប្រទេសកម្ពុជា ដើម្បីធ្វើយ៉ាងណាឲ្យអ្នកនៅរស់អាចឃើញឈ្មោះបងប្អូនរបស់ខ្លួនដែលបានស្លាប់ និងបាត់ខ្លួន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែសហការជាមួយបណ្ណសារដ្ឋានមួយនៃប្រទេសន័រវេ ដើម្បីបញ្ចូលឈ្មោះទាំងនេះទៅក្នុងទិន្នន័យកុំព្យូទ័រ ។

លើសពីនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែក្លាយខ្លួនទៅជាវិទ្យាស្ថានស្លឹករឹត ដែលជាមជ្ឈមណ្ឌលនៃការសិក្សាពីអំពើប្រល័យពូជសាសន៍ដ៏បំផុតនៅទ្វីបអាស៊ី ។ នៅឆ្នាំ២០១០ ក្រសួងមហាផ្ទៃបានចេញអាជ្ញាប័ណ្ណឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាបង្កើតវិទ្យាស្ថានស្លឹករឹត និងសាងសង់អគារនេះនៅក្នុងបរិវេណវិទ្យាល័យបឹងត្របែកក្នុងទីក្រុងភ្នំពេញ ។ អាជ្ញាប័ណ្ណនោះបានរៀបរាប់ថា «វិទ្យាស្ថានស្លឹករឹតមានបេសកកម្មប្រមូល និងស្រាវជ្រាវឯកសារទាក់ទងនឹងអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងប្រទេសផ្សេងទៀត ដើម្បីការចងចាំ យុត្តិធម៌ និងការផ្សះផ្សានៅក្នុងព្រះរាជាណាចក្រកម្ពុជា» ។ វិទ្យាស្ថានស្លឹករឹតនឹងមានសារមន្ទីរមួយដែលភ្ញៀវជាតិ និងអន្តរជាតិអាចចូលទស្សនាសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងទទួលបានភាពស្ងប់ស្ងាត់នៅក្នុងអគារមួយដែលរៀបចំឡើងក្នុងន័យព្យាបាលអ្នកដែលចូលមកទស្សនា ។ វិទ្យាស្ថានស្លឹករឹតនឹងមានសារមន្ទីរមួយ និងកន្លែងស្រាវជ្រាវមួយ ដែលមានបំណងបន្តប្រមូលឯកសារ ធ្វើការវិភាគ និងអភិរក្សព័ត៌មានអំពីសម័យខ្មែរក្រហម ។ កន្លែងស្រាវជ្រាវនេះនឹងបង្កលក្ខណៈងាយស្រួលដល់បញ្ញវន្តជាតិ និងអន្តរជាតិចូលសិក្សាអំពីការរំលោភសិទ្ធិមនុស្សនៅទូទាំងទ្វីបអាស៊ី ។

លើសពីនេះ វិទ្យាស្ថានស្លឹករឹតនឹងមានសាលារៀនមួយដែលសិស្សកម្ពុជានិងបរទេសអាចមកសិក្សាមុខវិជ្ជាផ្សេងៗទាក់ទងនឹងសិទ្ធិមនុស្សក្នុងតំបន់ ។ មុខវិជ្ជានេះអាចយកទៅបំពេញក្រេឌីតបញ្ចប់ការសិក្សាបាននៅសាលាផ្សេងទៀតបាន ។ ព័ត៌មានបន្ថែមទៀតទាក់ទងមជ្ឈមណ្ឌលស្លឹករឹតអាចរកបាននៅលើគេហទំព័រនេះ www.cambodiasri.org ។

## គម្រោងសាលាក្តីទូរនិមិត្តនៃសាកលវិទ្យាល័យកាលីហ្វ័រញ៉ាប៊ឺគ្លី

***(University of California-Berkeley)***

ក្នុងខែកុម្ភៈ ឆ្នាំ២០១០ សាកលវិទ្យាល័យកាលីហ្វ័រញ៉ាប៊ឺគ្លី បានសហការជាមួយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីបង្កើតនូវអន្តរគេហទំព័ររួមគ្នាមួយ ដោយធ្វើការបង្កើតឡើងវិញនូវការបង្ហាញមួយដែលពេញលេញ និងត្រឹមត្រូវជាក់លាក់អំពីបរិយាកាសជុំវិញបន្ទប់សវនាការ ការថែរក្សាទុកឯកសារទាំងឡាយរបស់តុលាការ ព្រមទាំងចែកចាយព័ត៌មានរបស់តុលាការទៅកាន់គ្រូបង្រៀន អ្នកជំនាញផ្នែកច្បាប់ ក្រុមអ្នកអនុវត្តការងារ និងសាធារណជនទូទៅ ។ គម្រោងសាលាក្តីទូរនិមិត្តនៃសាលាក្តីខ្មែរក្រហមនឹងធ្វើការប្រមូលផ្តុំនូវរាល់ឯកសារ និងព័ត៌មានទាំងអស់របស់តុលាការដូចជា ប្រតិចារិករបស់តុលាការ ឯកសារ វត្ថុតាង សេចក្តីថ្លែងការណ៍ និងភស្តុតាងដទៃទៀតរួមទាំងប្រភេទឯកសារដទៃទៀតដូចជា សារព័ត៌មាន និងរូបថតផ្សេងៗ ។ ឯកសារដែលប្រមូលបានទាំងអស់នេះនឹងត្រូវបានរក្សាទុកជាអចិន្ត្រៃយ៍នៅក្នុងគេហទំព័របណ្ណសារដែលអាចចូលរកបានតាមរយៈអាសយដ្ឋាន vt.eccc.gov.kh. នៅក្នុងគេហទំព័របណ្ណសារនេះក៏មានរួមបញ្ចូលនូវបទអត្ថាធិប្បាយរបស់អ្នកជំនាញផ្សេងៗ អត្ថបទសម្ភាសន៍ជាមួយមន្ត្រីតុលាការ និងជាមួយអ្នកចូលរួមតាមដានសវនាការ និងឯកសារផ្សព្វផ្សាយរបស់អង្គការសង្គមស៊ីវិលនានា ។ គម្រោងសាលាក្តីទូរនិមិត្តនឹងព្យាយាមធ្វើការពង្រីកទំហំនៃការផ្តល់ព័ត៌មាន និងឯកសារនានា ព្រមទាំងផលប៉ះពាល់ជាទូទៅដែលពាក់ព័ន្ធនឹងតុលាការទៅប្រជាជនកម្ពុជាឲ្យកាន់តែទូលំទូលាយ

តាមរយៈការផ្តល់ឲ្យសារធារណជនអាចចូលមើលឯកសារទាំងឡាយរបស់តុលាការបាននៅតាមសាលារៀន មជ្ឈមណ្ឌលព័ត៌មាន និងបូជនីយដ្ឋាននានានៅទូទាំងប្រទេស ។

## បណ្ណសារដ្ឋានជាតិកម្ពុជា

បណ្ណសារដ្ឋានជាតិកម្ពុជា គឺជានាយកដ្ឋានមួយរបស់ទីស្តីការគណៈរដ្ឋមន្ត្រី "ដែលទទួលបន្ទុកក្នុងការថែរក្សា ការពារឯកសារ ទាំងឡាយដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដែលមានតម្លៃជាប្រវត្តិសាស្ត្រ និងគតិយុត្តិ ។ ឯកសារទាំងអស់នៃបណ្ណសារដ្ឋានជាតិកម្ពុជា ត្រូវបានរៀបចំដាក់លើធ្នើប្រវែង ១,៨០០ម៉ែត្រ ដែលគ្របដណ្តប់គ្រប់ផ្នែកទាំងអស់នៃរដ្ឋបាលរបស់រាជរដ្ឋាភិបាល" ។ នៅក្នុងចំណោមកម្រងឯកសារទាំងអស់ គឺមានឯកសារជាងមួយសែនទំព័រ បានមកពីក្រសួងពាណិជ្ជកម្មនៃកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាសក្ខីកម្មនានារបស់ជនរងគ្រោះដែលធ្វើជាសាក្សីនៅក្នុងតុលាការឆ្នាំ១៩៧៩ អំឡុងពេលនៃការកាត់ទោស អៀង សារី និង ប៉ុល ពត ដោយកំបាំងមុខ ។ បណ្ណសារដ្ឋានជាតិកម្ពុជា "គឺជាស្ថាប័នសាធារណៈមួយដែលមានគោលបំណងធ្វើឲ្យគ្រប់ស្ថាប័នរដ្ឋបាលកម្ពុជាបច្ចុប្បន្ន ក៏ដូចជាអង្គការផ្សេងៗ និងអ្នកស្រាវជ្រាវគ្រប់រូបអាចស្រាវជ្រាវរកមើលឯកសារបានដោយទូលំទូលាយ" ។

## មជ្ឈមណ្ឌលតម្កល់ឯកសារផ្នែកច្បាប់

ទោះបីជានៅលើគេហទំព័រឃ្លាំមើលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម និងគេហទំព័រសាលាក្តីទូរនិមិត្ត (សាលាក្តីវើចួល) មានបង្ហោះនូវឯកសារឌីជីថលរបស់សាលាក្តីខ្មែរក្រហមយ៉ាងណា ក៏រដ្ឋាភិបាលជប៉ុនបានប្រកាសពីគម្រោងផ្តល់ថវិកាចំនួនពីរលានដុល្លារសហរដ្ឋអាមេរិក ដើម្បីស្ថាបនានូវមជ្ឈមណ្ឌលតម្កល់ឯកសារផ្នែកច្បាប់មួយសម្រាប់តម្កល់កម្រងរូបិយនៃកំណត់ត្រារបស់តុលាការដែលមានទីតាំងនៅជិតព្រលានយន្តហោះភ្នំពេញ ។ មានការរំពឹងទុកថា គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាជាអ្នករៀបចំចាត់ចែងការស្ថាបនានេះ ។ នៅក្នុងសេចក្តីប្រកាសរបស់ខ្លួននៅឆ្នាំ២០១០ ស្ថានទូតជប៉ុនបានលើកឡើងថា "មជ្ឈមណ្ឌលតម្កល់ឯកសារផ្នែកច្បាប់របស់សាលាក្តីខ្មែរក្រហមនឹងតម្កល់ទុកនូវកំណត់ត្រារបស់សាលាក្តីខ្មែរក្រហម បង្ហាញនូវឯកសារផ្លូវការសម្ងាត់ផ្សេងៗជូនដល់សាធារណជន ហើយថែមទាំងអាចឲ្យប្រជាជននៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅបរទេសដែលមានចំណាប់អារម្មណ៍លើសាលាក្តីនេះដូចជា អ្នកស្រាវជ្រាវ មេធាវី និងនិស្សិតជាដើម អាចរកមើលកំណត់ត្រាទាំងនោះបាន" ។ គម្រោងនេះមិនទាន់មានការកំណត់ពេលវេលាឲ្យបានច្បាស់លាស់នោះទេ ហើយក៏ពុំទាន់មានគម្រោងអ្វីជាក់លាក់នោះដែរក្នុងការគ្រប់គ្រងការរកមើលជាសាធារណៈ ។

## សេចក្តីបញ្ចប់

គំនិតផ្តួចផ្តើមទាំងនេះក្នុងការចងក្រងឯកសារ បានចូលរួមចំណែកក្នុងការថែរក្សាព័ត៌មានទាក់ទងនឹងរបបខ្មែរក្រហមសម្រាប់មនុស្សជំនាន់ក្រោយ ក៏ដូចជាអ្នកស្រាវជ្រាវក្នុង និងក្រៅប្រទេសផងដែរ ។ ប៉ុន្តែ ទាក់ទងនឹងគម្រោងស្ថាបនាមជ្ឈមណ្ឌលតម្កល់ឯកសារផ្នែកច្បាប់ដែលមិនទាន់បានចាប់ផ្តើមនោះ នៅតែមានភាពស្រពេចស្រពិលនៅឡើយ ។

ជាជាងការសាងសង់អគារថ្មីទៀត ដើម្បីតម្កល់ទុកឯកសារប្រភេទក្រដាសផ្សេងៗរបស់សាលាក្តីខ្មែរក្រហម បណ្ណសារដ្ឋានជាតិកម្ពុជាអាចធ្វើការតម្កល់ទុកឯកសារទាំងអស់នោះជាមួយនឹងកំណត់ត្រាផ្សេងៗរបស់តុលាការឆ្នាំ១៩៧៩ ដែលធ្វើការកាត់ទោសមេដឹកនាំខ្មែរក្រហមលើកដំបូង ។ បណ្ណសារដ្ឋានជាតិកម្ពុជាមានបុគ្គលដែលទទួលបានការហ្វឹកហ្វឺនក្នុងការថែរក្សាឯកសារប្រវត្តិសាស្ត្រសំខាន់ៗនានា ជាពិសេស ឯកសាររបស់សាលាក្តីខ្មែរក្រហមទាំងអស់នឹងអាចតម្កល់នៅទីតាំងដូចគ្នានោះជូនដល់សាធារណជនដែលមានចំណាប់អារម្មណ៍ ។

បណ្ណសារដ្ឋានជាតិនឹងមានគម្រោងសាងសង់អគារបន្ថែមទៀត រួមទាំងសាលាបណ្ណសារមួយផងដែរ ។ លើសពីនេះទៅទៀត ការឧបត្ថម្ភជាថវិកាពីសំណាក់រដ្ឋាភិបាលបរទេសនានាក្នុងការជួយថែរក្សាឯកសាររបស់សាលាក្តីខ្មែរក្រហមនឹងអាចបន្សល់ទុកនូវកេរដំណែលមួយយ៉ាងជ្រាលជ្រៅ ប្រសិនបើរដ្ឋាភិបាលទាំងនោះមានបំណងគាំទ្រនូវការធ្វើទំនើបភាវូបនីយកម្មលើឧបករណ៍បរិក្ខារ ក៏ដូចជាការអភិវឌ្ឍជំនាញដល់បុគ្គលិកនៃស្ថាប័នរដ្ឋជាមូលដ្ឋាននេះដែលទទួលបន្ទុកថែរក្សាការពារឯកសារប្រវត្តិសាស្ត្រកម្ពុជា ។

**គាឆាណា សែណាធី**

# ពង្រឹងគោលជំហរឯករាជ្យ-ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិ និងប្រជាជនខ្លួនដោយខ្លួនឯង

## ដកស្រង់ចេញពីឯកសារខ្មែរក្រហម D២១៣៨២

***១) ប្រវត្តិនៃមាគ៌ាឯករាជ្យ-ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិ និងប្រជាជនខ្លួន***

*ឆ្លងតាមការតស៊ូបដិវត្តន៍យ៉ាងតឹងតែង លំបាកវេទនា ស្មុគស្មាញបត់បែនក្រងិក្រងក់ច្រើនរាប់មិនអស់តាំងពីសម័យតស៊ូអាវុធ វាយបណ្តេញអាណានិគមបារាំង រហូតដល់សម័យតស៊ូនយោបាយសម្ងាត់ ក្រោយសន្និសីទហ្សឺណែវទៀត បក្សបានដកពិសោធន៍ដ៏ថ្លៃថ្លាជាច្រើន ដែលចេញពីចលនាជាក់ស្តែងនៃការតស៊ូបដិវត្តន៍របស់ប្រជាជនយើង ដែលចេញពីសាច់ពីឈាមនៃយុទ្ធជន កម្មាភិបាល និងប្រជាជនយើង ។ ក្នុងបទពិសោធន៍ដ៏ថ្លៃថ្លាទាំងនេះ បក្សបានឃើញច្បាស់ថា ដើម្បីឲ្យបដិវត្តន៍កម្ពុជាសម្រេចជ័យជម្នះទីអវសាន្តបាន គឺវាយបណ្តេញទាំងចក្រពត្តិនិយម វាយកម្ទេចទាំងវណ្ណៈសក្តិភូមិ នាយទុន ប្រជាជាតិ ប្រជាជនកម្ពុជា និងបដិវត្តន៍កម្ពុជាត្រូវជឿជាក់លើកម្លាំងប្រជាជាតិ និងប្រជាជនខ្លួនថា មានលទ្ធភាព និងសមត្ថភាពពេញទីក្នុងការសម្រេចបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យនៅប្រទេសកម្ពុជា ដូចតែប្រជាជនសូវៀត ប្រជាជនចិន ប្រជាជនវៀតណាម និងប្រជាជនសកលលោកផ្សេងទៀតដែលបានសម្រេចបដិវត្តន៍នៅក្នុងប្រទេសគេរៀងៗខ្លួនដែរ ។ ប្រជាជាតិ ប្រជាជន និងបដិវត្តន៍កម្ពុជាត្រូវជឿជាក់លើការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ដូច្នេះ ក្នុងការធ្វើបដិវត្តន៍នៅប្រទេសកម្ពុជាយើងត្រូវពឹងផ្អែកលើកម្លាំង និងសមត្ថភាពរបស់ប្រជាជនយើងលើធនធានប្រទេសជាតិយើងជាសំខាន់ ។ ពោលគឺបក្សយើងត្រូវខិតខំឃោសនាអប់រំ និងចលនាកៀងគរប្រជាជនកម្ពុជាឲ្យមានការភ្ញាក់រឭកបដិវត្តន៍ ឲ្យចងកំហឹងឆាបឆេះសន្ធោសន្ធៅចំពោះពួកចក្រពត្តិបរទេស ដែលជ្រៀតជ្រែកឈ្លានពានទឹកដីកម្ពុជាយើង ដែលជិះជាន់ ឆក់ប្លន់ប្រជាជនកម្ពុជា យើងនិងមានកំហឹងសន្ធោសន្ធៅចំពោះពួកសក្តិភូមិ-នាយទុន ដែលជិះជាន់ ហុតឈាម អង្កៀមឆ្អឹង និងមើលងាយមើលថោកប្រជាជនកម្ពុជាយើងអស់រយៈជាងពីរពាន់ឆ្នាំមកហើយ ។ បើប្រជាជនយើងមានការភ្ញាក់រឭកបដិវត្តន៍ និងមានកំហឹងជាតិ កំហឹងវណ្ណៈច្បាស់លាស់ហើយ នោះគេនឹងចូលរួមប្រាស្រ័យធ្វើបដិវត្តន៍ វាយកម្ទេចខ្មាំងយ៉ាងសស្រាក់សស្រាំបំផុត ។ ដូច្នេះ ប្រជាជនកម្ពុជាក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជាមិនឃោសនាអប់រំ មិនចលនាកៀងគរ មិនដឹកនាំប្រជាជនកម្ពុជាឲ្យក្រោកឡើងធ្វើការតស៊ូបដវត្តន៍វាយកម្ទេចខ្មាំង រំដោះប្រទេសជាតិ និងប្រជាជនខ្លួនដោយខ្លួនឯងទេ ហើយបែរជាដេករង់ចាំឲ្យបក្សបដិវត្តន៍ប្រទេសដទៃមកធ្វើបដិវត្តន៍កម្ពុជាជំនួសប្រជាជនកម្ពុជាទៅវិញនោះ នោះបដិវត្តន៍កម្ពុជានឹងពុំអាចសម្រេចជ័យជម្នះនៅកម្ពុជាបានឡើយ ព្រោះបក្សបដិវត្តន៍ និងប្រជាជននៃប្រទេសនានាគេមានភារកិច្ចត្រូវសម្រេចបដិវត្តន៍នៅក្នុងប្រទេសគេដែរ ។*

*ដោយមានជំនឿយ៉ាងមុតមាំយ៉ាងនេះ និងដោយឈរលើទស្សនៈ និងគោលជំហរខាងលើនេះនៅឆ្នាំ១៩៦០ បក្សក៏បានលើកមាគ៌ាដ៏ត្រឹមត្រូវ និងភ្លឺស្វាង គឺមាគ៌ាឯករាជ្យ ម្ចាស់ការខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិ និងប្រជាជនខ្លួនដោយខ្លួនឯងក្នុងការដឹកនាំចលនាតស៊ូបដិវត្តន៍នៅកម្ពុជា ក៏ដូចក្នុងការកសាងកម្លាំងបដិវត្តន៍គ្រប់ផ្នែកជារៀងរហូតមកទៀតដែរ ។*

*តាំងពីមានមាគ៌ាឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិ និងប្រជាជនខ្លួនដោយខ្លួនឯងនេះមកចលនាបដិវត្តន៍កម្ពុជាមានសន្ទុះផុលផុសខ្លាំងក្លា គគ្រឹកគគ្រេងឡើងជាលំដាប់នៅទូទាំងប្រទេស ។*

*ក្នុងចលនាតស៊ូនយោបាយសម្ងាត់១៣ឆ្នាំ ពិសេសចាប់ពីឆ្នាំ១៩៦០ រហូតមកដល់ឆ្នាំ១៩៦៧នេះ ហើយដែលចលនា*

តស៊ូនយោបាយតាមគ្រប់រូបភាពស្រួចស្រាល់នឹងមានសន្ទុះ ផុលផុស ខ្លាំងក្លា ទាំងនៅជនបទទាំងនៅទីក្រុង ។

ចេញពីសន្និសីទហ្សឺណែវមក បដិវត្តន៍យើងមានតែបាតដៃទទេ ។ មកទល់ឆ្នាំ១៩៦០ យើងមានមាគ៌ាយុត្តិសាស្ត្រ មាគ៌ាយុទ្ធវិធី ដើម្បីដឹកនាំសកម្មភាពបដិវត្តន៍យើង ដោយឯករាជ្យ ម្ចាស់ការ ។ ជាបន្តបន្ទាប់មកទៀត យើងបានកសាងមូលដ្ឋានបផ្អែកបដិវត្តន៍របស់យើងដោយឯករាជ្យ ម្ចាស់ការ ។ យើងបានកសាងកម្លាំងបដិវត្តន៍ កម្លាំងប្រជាជន មហាជនបដិវត្តន៍កាន់តែរីកចម្រើនធំធាត់ឡើងជាលំដាប់ ។ ក្រោយមកទៀត យើងបានកសាងកងកម្លាំងប្រដាប់អាវុធរបស់យើង ដែលពេលនោះ ហៅថាកងការពារសម្ងាត់ដោយឯករាជ្យ ម្ចាស់ការដោយពឹងផ្អែកលើមធ្យោបាយ និងលទ្ធផលរបស់បដិវត្តន៍ និងប្រជាជនយើងក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់បក្សកុម្មុយនីស្តកម្ពុជាយើង ។ ក្នុងរយៈកាលដ៏លំបាកស្មុគស្មាញនេះ បក្សមិនត្រឹមតែបានដឹកនាំចលនាតស៊ូបដិវត្តន៍ កសាងកម្លាំងបដិវត្តន៍ កសាងមូលដ្ឋានបផ្អែកបដិវត្តន៍បានប៉ុណ្ណោះទេ តែបក្សនៅបានដឹកនាំចលនាបដិវត្តន៍ វាយសម្រុកខ្មាំងខាងនយោបាយយ៉ាងខ្លាំងក្លាទៀត ធ្វើឲ្យខ្មាំង ទាំងចក្រពត្តិអាមេរិក ទាំងបរិវារក្បត់ជាតិ ទាំងពួកវណ្ណៈ កាន់អំណាចប្រតិកិរិយាត្រូវបកអាក្រាត វែកមុខ មានការរើករេរច្របូកច្របល់ បែកបាក់ផ្ទៃក្នុង និងត្រូវបរាជ័យយ៉ាងអាម៉ាស់ជាបន្តបន្ទាប់ ។

ក្នុងរយៈកាលនៃការតស៊ូនយោបាយដ៏លំបាកស្មុគស្មាញនេះ បក្សអាចឧបត្ថម្ភខ្លួនបានទាំងមាគ៌ានយោបាយ ទាំងកម្លាំងបដិវត្តន៍ ទាំងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ដោយឯករាជ្យ ម្ចាស់ការទាំងស្រុង ។ នេះជាជ័យជម្នះនៃមាគ៌ាឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិ និងប្រជាជនខ្លួនដោយឯករាជ្យរបស់បក្សទាំងស្រុង ។

តមកទៀត ដោយមានមាគ៌ានិងមានទស្សនៈគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន យ៉ាងត្រឹមត្រូវ និងរឹងមាំយ៉ាងនេះហើយ បានជាក្នុងសម័យសង្គ្រាមផ្ទៃក្នុងពីដើមឆ្នាំ១៩៦៨ ដល់ដើមឆ្នាំ១៩៧០ ដែលចក្រពត្តិអាមេរិក និងបរិវារវាបង្កឡើង ដើម្បីកម្ទេចកម្លាំងបដិវត្តន៍ កម្ទេចមូលដ្ឋានបផ្អែកបដិវត្តន៍ និងកម្ទេចបដិវត្តន៍កម្ពុជាជាស្ថាពរ បក្សបានដឹកនាំប្រជាជនកម្ពុជាតស៊ូអាវុធ រួមផ្សំនយោបាយប្រឆាំងទល់នឹងសង្គ្រាមផ្ទៃក្នុងនេះយ៉ាងអង់អាចក្លាហានបំផុត ហើយដណ្តើមបានជ័យជម្នះជាបន្តបន្ទាប់ ។ ពេលនោះ យើងគ្មានអាវុធមួយដើមទេ យើងពុំទាន់មានកងកម្លាំងប្រដាប់អាវុធរៀបរយប្រមូលផ្តុំទេ តែដោយឈរលើគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិនិងប្រជាជនខ្លួនដោយខ្លួនឯង បក្សបានដឹកនាំប្រជាជនយើងក្រោកឡើងធ្វើកុប្បកម្ម វាយដណ្តើមអាវុធពីដៃខ្មាំងពីក្នុងប៉ុស្តិ៍បន្ទាយខ្មាំងយកមកបំពាក់ឲ្យខ្លួន ហើយកសាងចាត់តាំងជាកងឈ្លប ប្រើអាវុធខ្មាំងនេះទៅវាយប្រហារខ្មាំងវិញបានយ៉ាងស័ក្តិសិទ្ធបំផុត ។



ការប្រជុំរៀនសូត្រនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

នៅក្នុងសម័យសង្គ្រាមផ្ទៃក្នុងនេះ ដោយឈរលើជំហរ និងទស្សនៈឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួនកម្រិតខ្ពស់ បក្សមិនត្រឹមតែបានដឹកនាំប្រជាជន ប្រយុទ្ធការពារកម្លាំងបដិវត្តន៍ និងការពារមូលដ្ឋានបផ្អែកបដិវត្តន៍បានប៉ុណ្ណោះទេ តែបក្សនៅបានកសាងពង្រឹងពង្រីកកម្លាំងបដិវត្តន៍ កសាងពង្រឹងពង្រីកមូលដ្ឋានបផ្អែកបដិវត្តន៍បានកាន់តែរឹងប៉ឹងខ្លាំងក្លា និងរីកចម្រើនធំធាត់ច្រើនថែមទៀត ។ បក្សបានដឹកនាំការតស៊ូបដិវត្តន៍ ទប់ទល់នឹងការវាយ

កម្ចាត់សង្គ្រាមផ្ទៃក្នុងដែលចក្រពត្តិអាមេរិក និងបរិវារក្បត់ជាតិ លន់ នល់, សិរិ មតៈ, សឺង ង៉ុកថាញ់ បង្កឡើងឲ្យបរាជ័យយ៉ាងដំណំៗជាបន្តបន្ទាប់ ដោយឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួនទាំងស្រុង ។ ពោលគឺក្នុងសម័យសង្គ្រាមផ្ទៃក្នុងនេះដែលសភាពការណ៍ក្នុងប្រទេសមានភាពតានតឹងស្មុគស្មាញជាខ្លាំង ហើយសភាពការណ៍ក្រៅប្រទេសនៅលើឆាកអន្តរជាតិក៏គ្មានអនុគ្រោះដល់ចលនាតស៊ូបដិវត្តន៍កម្ពុជាយើង សូម្បីបន្តិចបន្តួចសោះឡើយ ។ តែតាមពន្លឺនៃមាគ៌ាឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន បក្សបានពុះពារគ្រប់ឧបសគ្គ និងឆ្លងកាត់ការលំបាកវេទនាគ្រប់បែបយ៉ាង ដឹកនាំចលនាតស៊ូអាវុធ រួមផ្សំនយោបាយ ដោយខ្លួនឧបត្ថម្ភខ្លួនទាំងខាងមាគ៌ា



នយោបាយ ទាំងមាគ៌ាសតិអារម្មណ៍ និងមាគ៌ាចាត់តាំង ហើយអាចឧបត្ថម្ភខ្លួនបានទាំងស្រុង ទាំងខាងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ទាំងខាងអាវុធយុទ្ធភណ្ឌ ដោយពឹងផ្អែកលើធនធាន និងមធ្យោបាយខ្លួនទាំងស្រុង និងពឹងផ្អែកលើកម្លាំងប្រជាជនខ្លួនទាំងស្រុង ។

ប្រវត្តិសង្ខេបនៃចលនាតស៊ូបដិវត្តន៍របស់យើង ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជាក្នុងពីររយៈកាលកន្លងទៅនេះ គឺរយៈកាលតស៊ូនយោបាយ និងរយៈកាលតស៊ូអាវុធ រួមផ្សំនយោបាយប្រឆាំងទល់នឹងសង្គ្រាមផ្ទៃក្នុងបានបញ្ជាក់ច្បាស់ថា មាគ៌ាឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិ និងប្រជាជនខ្លួនដោយខ្លួនឯងរបស់បក្សនេះ គឺត្រឹមត្រូវឥតខ្ចោះ ហើយជាមាគ៌ាតែមួយគត់ដែលបដិវត្តន៍កម្ពុជា ប្រជាជាតិ និងប្រជាជនកម្ពុជាត្រូវប្រកាន់យកយ៉ាងខ្ជាប់ខ្ជួនក្នុងគ្រប់កាលៈទេសៈ ដើម្បីឈានទៅកាន់ជ័យជម្នះទីអវសាន ។ មាគ៌ាឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិខ្លួនរបស់បក្សនេះក៏ត្រូវបានផ្សព្វផ្សាយជ្រួតជ្រាបកាន់តែជ្រាលជ្រៅឡើងៗ ទៅក្នុងជួរបដិវត្តន៍យើង និងទៅក្នុងប្រជាជន និងយុវជន-យុវនារីយើង ។ មាគ៌ាដ៏ត្រឹមត្រូវនេះបានក្លាយទៅជាគោលជំហរដ៏រឹងមាំ ហើយដែលកាន់តែរឹងមាំឡើងៗជាលំដាប់តមកទៀតរបស់ចលនាបដិវត្តន៍កម្ពុជាយើង ក៏ដូចជារបស់ប្រជាជនកម្ពុជាយើងទាំងមូលដែរ ។ ទោះបីជួបឧបសគ្គ ឬការលំបាកវេទនាយ៉ាងណា ទោះបីស្ថិតក្នុងសភាពការណ៍តឹងតែងស្មុគស្មាញទាំងនៅក្នុងប្រទេស ទាំងនៅលើឆាកអន្តរជាតិយ៉ាងណា ក៏បដិវត្តន៍យើង ប្រជាជន យុវជន និងយុវនារីកម្ពុជាយើងមិនយ្វេងយ្វោង មិនងាករេពីគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិ និងប្រជាជនខ្លួនដ៏ត្រឹមត្រូវនេះដែរ ។ ប្រជាជន យុជន-យុវនារីបដិវត្តន៍កម្ពុជាយើង គ្មានដែលរវើរវាយ ស្រមើស្រមៃ ដេកសង្ឃឹម ឬដេករង់ចាំ ឬមានសតិអារម្មណ៍ពឹងផ្អែកលើជំនួយបរទេសម្តងណាឡើយ ។

**២) មហាជ័យជម្នះជាប្រវត្តិសាស្ត្រនាថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ជាមហាជ័យជម្នះនៃមាគ៌ាឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិ និងប្រជាជនខ្លួនដ៏ត្រឹមត្រូវរបស់បក្ស**

ដោយត្រូវបរាជ័យយ៉ាងដំណំៗជាបន្តបន្ទាប់នៅក្នុងការបង្កសង្គ្រាមផ្ទៃក្នុងនៅកម្ពុជារបស់វា ចក្រពត្តិអាមេរិក និងពួកអាក្បត់ លន់ នល់, សិរិ មតៈ, សឺង ង៉ុកថាញ់ ពុំអាចសម្រេចផែនការកម្ទេចកម្លាំងបដិវត្តន៍ កម្ទេចមូលដ្ឋានបង្អែកបដិវត្តន៍ និងកម្ទេចចលនាបដិវត្តន៍កម្ពុជា ដើម្បីយកប្រទេសកម្ពុជាធ្វើជាមូលដ្ឋានយោធាបម្រើសង្គ្រាមឈ្លានពានរបស់វានៅអាស៊ីអាគ្នេយ៍បានឡើយ ។ ថ្ងៃ១៨ មីនា ឆ្នាំ១៩៧០ ចក្រពត្តិអាមេរិកក៏បានបញ្ជាឲ្យ

ពួកអាក្សត់ លន់ នល់, សិរិ មតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ ធ្វើរដ្ឋប្រហាររំលំឯករាជ្យ សន្តិភាព អាព្យាក្រឹតនៃកម្ពុជា ប៉ុនប៉ងកម្ទេចបដិវត្តន៍ កម្ទេចកម្លាំងស្នេហាជាតិក្នុងរយៈតែមួយព្រឹប ហើយប្រែក្រឡៃកម្ពុជាឲ្យទៅជាអាណានិគមបែបថ្មីរបស់ចក្រពត្តិអាមេរិកភ្លាមមួយរំពេច ។ តែដោយមានទុនជាកម្លាំងប្រដាប់អាវុធ បដិវត្តន៍ដែលធ្លាប់វាយ ហើយវាយឈ្នះពួកអាក្សត់ លន់ នល់ ទុនជាមូលដ្ឋានបផ្អែកបដិវត្តន៍រឹងប៉ឹងដែលអាចឧបត្ថម្ភខ្លួនបានខាងសេដ្ឋកិច្ចមួយរយភាគរយ ទុនជាកម្លាំងនយោបាយនៅក្នុងប្រជាជនកម្ពុជាដ៏ច្រើនកុះករ ពិសេសប្រជាជនកម្មករ កសិករក្រ និងកសិករកណ្តាលថ្នាក់ក្រោមកាលពីសម័យសង្គ្រាមផ្ទៃក្នុង បក្សក៏បានដឹកនាំប្រជាជនកម្ពុជា ធ្វើសង្គ្រាមផ្ទៃក្នុងបក្សក៏បានដឹកនាំប្រជាជនកម្ពុជាធ្វើសង្គ្រាមបដិវត្តន៍ទប់ទល់ និងវាយកម្ទាត់សង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិក និងបរិវារយ៉ាងអង់អាចក្លាហានភ្លាមដែរ ។ គ្រាន់តែពួកអាក្សត់ លន់ នល់, សិរិ មតៈ, សឺង ង៉ុកថាញ់, ចេង ហេង, អ៊ិន តាំ ធ្វើរដ្ឋប្រហារភ្លាម ប្រជាជនកម្ពុជាក្រោមការដឹកនាំរបស់បក្សក៏បានក្រោកឡើងវាយទាំងយោធា ទាំងនយោបាយនៅគ្រប់ទិសទីទូទាំងកម្ពុជា ។ ចក្រពត្តិអាមេរិក បរិវារ និងពួកអាក្សត់ជាតិមិនត្រឹមតែមិនអាចសម្រេចបំណងដ៏ឧក្រិដ្ឋរបស់វាបានប៉ុណ្ណោះទេ តែវាត្រូវកងកម្លាំងប្រដាប់អាវុធបដិវត្តន៍កម្ពុជាដ៏ក្មេងខ្ចី និងប្រជាជនកម្ពុជាក្រោមការដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជាវាយប្រហារពីគ្រប់ទិស ។

នៅក្នុងសង្គ្រាមបដិវត្តន៍ប្រឆាំងនឹងសង្គ្រាមឈ្លានពានដ៏កាចសាហាវរបស់ចក្រពត្តិអាមេរិក និងបរិវារនេះដោយឈរលើគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិ និងប្រជាជនខ្លួនកម្រិតខ្ពស់បំផុត ចលនាបដិវត្តន៍យើងក៏បានរីកចម្រើនលោតផ្លោះទៅមុខយ៉ាងឆាប់រហ័សឈានពីជ័យជម្នះមួយទៅជ័យជម្នះមួយកាន់តែធំដុំថែមទៀតជាលំដាប់ ។ កងកម្លាំងប្រដាប់អាវុធ បដិវត្តន៍កម្ពុជាក៏បានកសាងខ្លួន ពង្រឹងពង្រីកខ្លួន ធំធាត់ឡើង និងខ្លាំងក្លាឡើងទៅតាមមាគ៌ាឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន យ៉ាងឆាប់រហ័សបំផុត ។ ចាប់ផ្តើមពីកងឈ្លបដែលមានតែមួយក្រុម តែពួកតូចៗ និងមានអាវុធសម័យបន្តិចបន្តួច រួមផ្សំនឹងអាវុធបូរាណ និងអាវុធធ្វើដោយខ្លួនឯង នៅពេលក្រោយរដ្ឋប្រហារភ្លាម កងកម្លាំងប្រដាប់អាវុធបដិវត្តន៍យើងក៏បានប្រែក្លាយទៅជាកងទ័ពប្រមូលផ្តុំ មានតាំងពីកងអនុសេនាធំ កងវរសេនាតូចឡើងរហូតដល់កងវរសេនាធំ និងកងពលទៀតដែលមានអាវុធធុនស្រាល ធុនធ្ងន់ទំនើបៗសព្វបែបយ៉ាងដែលវាយដណ្តើមបានមកពីខ្មាំងបំពាក់ឲ្យខ្លួន ។

កម្លាំងបដិវត្តន៍គ្រប់ផ្នែកដទៃទៀតក៏រីកចម្រើនធំធាត់លោតផ្លោះ ព្រមជាមួយគ្នាដែរ ពិសេសកម្លាំងនយោបាយនៅក្នុងចំណោមប្រជាជន និងកម្លាំងសេដ្ឋកិច្ច ។

ចលនាបដិវត្តន៍កម្ពុជាយើងដែលរីកចម្រើនធំធាត់ខ្លាំងក្លាលើគ្រប់វិស័យ បានដណ្តើមជ័យជម្នះធំៗជាបន្តបន្ទាប់លើខ្មាំងសត្រូវទាំងនៅលើសមរភូមិយោធា ទាំងនៅលើសមរភូមិនយោបាយ សេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច និងការងារទូត ហើយរហូតដល់ដណ្តើមបានមហាជ័យជម្នះទាំងស្រុង និងជាស្ថាពរនាថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ នេះ ។ ក្នុងសង្គ្រាមបដិវត្តន៍ជាងប្រាំឆ្នាំកន្លងទៅនេះ ប្រជាជនកម្ពុជា បដិវត្តន៍កម្ពុជា ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជាបានពឹងផ្អែកលើកម្លាំងខ្លួន លើធនធាននៃប្រទេសជាតិខ្លួន ឧបត្ថម្ភខ្លួនខាងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ពិសេសខាងការស៊ីចុកស្លៀកពាក់បានទាំងស្រុង ឧបត្ថម្ភខ្លួនខាងអាវុធយុទ្ធភណ្ឌ ធ្វើសង្គ្រាមបដិវត្តន៍បានជាអតិបរមា និងភាគច្រើនលើសលប់ ។ ទាំងនេះជាព្រឹត្តិការណ៍ដែលកម្រមានក្នុងប្រវត្តិនៃសង្គ្រាមបដិវត្តន៍នៅលើសកលលោក ។ ពោលគឺប្រទេសជាតិតូចមួយមានប្រជាជនតិច បដិវត្តន៍មួយធ្វើសង្គ្រាមវាយចក្រពត្តិ និងបរិវារឈ្លានពានផង ហើយឧបត្ថម្ភខ្លួនទាំងសព្វទាំងគ្រប់ដោយឯករាជ្យ ម្ចាស់ការបានផង ។

ដូច្នេះ មហាជ័យជម្នះនាថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ និងមហាព្រឹត្តិការណ៍ដ៏កម្រមាននៅលើសកលលោកខាងលើនេះ គឺពិតជាបានមកដោយសារមាគ៌ាឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួនដ៏ត្រឹមត្រូវរបស់បក្សដែលជ្រួតជ្រាប ហើយដែលបានក្លាយទៅជាគោលជំហរបដិវត្តន៍យ៉ាងរឹងប៉ឹងរបស់កងទ័ព ប្រជាជន និងយុវជនយុវជនារីបដិវត្តន៍យើង ។

មាគ៌ា និងគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិ និងប្រជាជនខ្លួនដោយខ្លួនឯង

យ៉ាងរឹងប៉ឹងរបស់បដិវត្តន៍ និងប្រជាជនកម្ពុជាយើងនេះបាន បញ្ជាក់ច្បាស់ ហើយលេចធ្លោឡើងជាពិសេស ទាំងនៅក្នុងប្រទេស ទាំងនៅលើឆាកអន្តរជាតិនៅដើមឆ្នាំ១៩៧៣ ដែលសកលលោក ធ្វើការចរចាសម្រុះសម្រួលជាមួយចក្រពត្តិអាមេរិកដែលវៀតណាម និងលាវចុះកិច្ចព្រមព្រៀងបញ្ឈប់សង្រ្គាមជាមួយចក្រពត្តិអាមេរិក ដែលចក្រពត្តិអាមេរិក និងសកលលោកគាបសង្កត់ឲ្យបដិវត្តន៍កម្ពុជាធ្វើការចរចាជាមួយចក្រពត្តិអាមេរិក ។ នៅពេលនោះ សភាពការណ៍សកលលោក ក៏ដូចជាសភាពការណ៍នៅក្នុងប្រទេសកម្ពុជាមានការស្មុគស្មាញជាខ្លាំង ដោយឧបាយកលពិសពុលរបស់ចក្រពត្តិអាមេរិកផង និងដោយការសម្រុកគំរាមកំហែងទម្លាក់គ្រាប់បែកដោយយន្តហោះបេ៥២របស់ចក្រពត្តិអាមេរិកផង តែបដិវត្តន៍កម្ពុជា ប្រជាជនកម្ពុជា កងកម្លាំងប្រដាប់អាវុធបដិវត្តន៍កម្ពុជា ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជាដែលឈរយ៉ាងរឹងមាំលើគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ហើយដែលកាន់កាប់វាសនាប្រទេសជាតិ និងប្រជាជនខ្លួនយ៉ាងរឹងមាំក្នុងដៃដោយខ្លួនឯង បានប្តេជ្ញាពុះពារគ្រប់ឧបសគ្គ ទ្រាំទ្រលំបាកវេទនាគ្រប់បែបយ៉ាងបន្តលើកជ្រោងគ្រវីទង់ប្រយុទ្ធ វាយកម្ទេចចក្រពត្តិអាមេរិក និងបរិវារតែម្នាក់ឯងនៅលើសាកលលោកយ៉ាងអង់អាចក្លៀវក្លា ទីបំផុត ដើម្បីកិត្តិយស និងអត្តិភាពនៃប្រជាជាតិ និងប្រជាជនកម្ពុជា និងដើម្បីកិត្តិយស និងអត្តិភាពនៃចលនាបដិវត្តន៍កម្ពុជា ។

ដោយឈរលើមាគ៌ាឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិ និងប្រជាជនខ្លួនយ៉ាងរឹងមាំ ដូច្នេះ ហើយបានជាយើងអាចវាយសង្រ្គាមអាកាសដ៏សាហាវឃោរឃៅបំផុតរបស់ចក្រពត្តិអាមេរិកឲ្យបរាជ័យទាំងស្រុងក្នុងរយៈតែប្រាំមួយខែកន្លះ ។ ហើយយើងក៏បានវាយកម្ទេចសង្រ្គាមឈ្លានពានដ៏កំណាចឃោរឃៅហ្វាស៊ីសបំផុតរបស់ចក្រពត្តិអាមេរិកឲ្យបរាជ័យរលំរលាយទាំងស្រុង និងជាស្ថាពរ ក្នុងរយៈពេលតែប្រាំឆ្នាំ មួយខែប៉ុណ្ណោះ ។

ដូច្នេះ មហាជ័យជម្នះជាប្រវត្តិសាស្រ្តនាថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥នេះ ជាមហាជ័យជម្នះនៃមាគ៌ាឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិ និងប្រជាជនខ្លួនដ៏ត្រឹមត្រូវរបស់បក្ស ។ ព្រោះបើគ្មានមាគ៌ាត្រឹមត្រូវនេះទេ បើគ្មានទស្សនៈ គោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិ និងប្រជាជនខ្លួនយ៉ាងរឹងប៉ឹងខ្ជាប់ខ្ជួនជារៀងរហូតមកទេ ម៉្លេះចលនាបដិវត្តន៍យើងប្រហែលជាត្រូវខ្មាំងវាយកម្ទេចបំផ្លិចបំផ្លាញ ឬក៏យ៉ាងហោចណាស់រាំងខ្ទប់មិនឲ្យរីកចម្រើនលោតផ្លោះឆាប់រហ័សដូច្នេះឡើយ តាំងពីក្រោយរដ្ឋប្រហារក្លាមម៉្លេះ ។ ម៉្លេះនៅឆ្នាំ១៩៧៣ ចលនាបដិវត្តន៍កម្ពុជា ប្រជាជនកម្ពុជា កងកម្លាំងប្រដាប់អាវុធបដិវត្តន៍កម្ពុជានឹងពុំហ៊ានលើកជ្រោងគ្រវីទង់ប្រយុទ្ធវាយចក្រពត្តិអាមេរិកជ្រងោៗ តែម្នាក់ឯងនៅលើសកលលោកដូច្នេះឡើយ ។ ដូច្នេះ វាក៏នឹងគ្មានមហាជ័យជម្នះជាប្រវត្តិសាស្រ្តនាថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ដែរ ។

**៣) ក្នុងសម័យសន្តិភាពដែលត្រូវការពារ និងកសាងប្រទេសឲ្យបានខ្លាំងក្លា សម្បូរសប្បាយ និងថ្កុំថ្កើង រុងរឿង យុវជនយុវនារីបដិវត្តន៍យើង ចាំបាច់ត្រូវពង្រឹងគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិខ្លួនឲ្យបានកាន់តែរឹងប៉ឹងថែមទៀត**

ឥឡូវ ប្រទេសយើងត្រូវបានរំដោះទាំងស្រុងហើយ ។ យើងរាល់គ្នាមានភារកិច្ចបន្តវាយសម្រុក ការពារប្រទេស និងកសាងកម្ពុជាថ្មីឲ្យបានខ្លាំងក្លា សម្បូរសប្បាយ និងថ្កុំថ្កើងរុងរឿងដោយល្បឿនលោតផ្លោះ ។ ដើម្បីសម្រេចភារកិច្ចធំថ្មីនេះឲ្យបានជ័យជម្នះលោតផ្លោះ តើយើងត្រូវពឹងផ្អែកលើអ្វីជាសំខាន់?

កាលពីក្នុងសម័យតស៊ូនយោបាយសម្ងាត់១៣ឆ្នាំ សម័យតស៊ូអាវុធ រួមផ្សំនយោបាយប្រឆាំងទល់នឹងសង្រ្គាមផ្ទៃក្នុងដែលចក្រពត្តិអាមេរិក និងបរិវារក្បត់ជាតិបង្កឡើង និងសម័យសង្រ្គាមបដិវត្តន៍ជាងប្រាំឆ្នាំចុងក្រោយនេះ ចលនាជាក់ស្តែងបានអប់រំយើងបានបញ្ជាក់ និងបង្ហាញច្បាស់ដល់យើងថា ត្រូវខ្លួនទីពឹងខ្លួនជាសំខាន់ ត្រូវពឹងផ្អែកលើកម្លាំង និងសមត្ថភាពប្រជាជនខ្លួន ហើយផ្អែកលើធនធានប្រទេសជាតិខ្លួនជាមូលដ្ឋាន ។ យើងបានដើរតាមមាគ៌ាដ៏ត្រឹមត្រូវនេះរបស់បក្ស យើងបានវាយចក្រពត្តិអាមេរិក និងបរិវារឈ្នះ យើងបានវាយរំលំវណ្ណៈសក្តិភូមិ នាយទុនដែលជាវណ្ណៈជិះជាន់ មានមូលដ្ឋានសេដ្ឋកិច្ច និងមូលដ្ឋាននយោបាយយ៉ាងរឹងមាំនៅក្នុងសង្គមកម្ពុជាជាងពីរពាន់ឆ្នាំមកហើយ

ឲ្យបរាជ័យរលំរលាយអស់ជាមូលដ្ឋាន ។ យើងឈ្នះធំសម្បើមយ៉ាងនេះហើយ ហើយយើងអាចរក្សាឯករាជ្យ និងអធិបតេយ្យភាពរបស់ប្រជាជាតិ ប្រជាជនបដិវត្តន៍ និងបក្សយើងបានយ៉ាងល្អស្អាត បរិសុទ្ធ គ្មានជំពាក់ជំពិនរសេមរសាមជាមួយនឹងមហាអំណាចណាទាំងអស់ ។ ដូច្នេះហើយ បានជាអត្តិភាព និងកិត្យានុភាពរបស់ប្រជាជាតិ ប្រជាជនកម្ពុជាដែលធ្លាប់តែត្រូវគេជិះជាន់មើលងាយមើលថោក អាប់ឱនកិត្តិយសរាប់សតវត្សរ៍មកហើយ អត្តិភាព និងកិត្តិយសនៃចលនាបដិវត្តន៍កម្ពុជា និងបក្សកុម្មុយនីស្តកម្ពុជាដែលសកលលោកពុំសូវស្គាល់ទេកាលពេលមុនបានលេចធ្លោឡើងខ្ពស់ត្រដែតត្រដឹម ទាំងនៅក្នុងប្រទេស ទាំងនៅលើឆាកអន្តរជាតិ ។ ប្រជាជនសកលលោកមានការគោរពស្ញប់ស្ញែង និងកោតសរសើរប្រជាជាតិ និងប្រជាជនកម្ពុជាបដិវត្តន៍ និងបក្សកុម្មុយនីស្តកម្ពុជាជាទីបំផុត ។ ប្រជាជនសកលលោក ពិសេសប្រជាជនដែលត្រូវគេជិះជាន់សង្កត់សង្កិនបានចាត់ទុកចលនាតស៊ូរបស់យើងជាគំរូដ៏ថ្លៃថ្លាវិសេសវិសាលណាស់ ព្រោះប្រទេសតូចប្រជាជនតិចដូចយើងនេះ ដោយប្រកាន់ខ្ជាប់មាគ៌ាឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន អាចវាយឈ្នះចក្រពត្តិអាមេរិក ដែលជាមេក្លោងចក្រពត្តិធំជាងគេ និងសាហាវឃោរឃៅហ្វូសស៊ីសជាងគេបំផុតនៅលើសាកលលោកនេះ ។ ដូច្នេះ កិត្តិយសរបស់ជាតិ ប្រជាជន និងចលនាបដិវត្តន៍យើងនៅលើសកលលោកសព្វថ្ងៃនេះខ្ពង់ខ្ពស់ វិសេសវិសាលសម្បើមណាស់ ។

ឥឡូវពេលរំដោះទូទាំងប្រទេសហើយ ក្នុងកិច្ចដំណើរការការពារប្រទេស និងកសាងប្រទេសបច្ចុប្បន្ន ក៏ដូចតទៅអនាគតទៀត យើងក៏ត្រូវរក្សាកិត្តិយសដ៏ឧត្តុង្គឧត្តមនេះ ហើយបន្តធ្វើជាគំរូដល់សកលលោក ដោយប្រកាន់ខ្ជាប់នូវមាគ៌ាឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិខ្លួនដោយខ្លួនឯងជាបន្តទៅទៀត ។

ដាក់ស្តែង ក្នុងកិច្ចការពារប្រទេស និងកសាងប្រទេសនេះ យើងត្រូវពឹងផ្អែកលើកម្លាំងប្រជាជនយើង លើទុនដែលយើងមាន និងលើធនធាននៃប្រទេសជាតិយើងជាសំខាន់ ។ ឯជំនួយមិត្តបរទេស បើទោះបីជាមានក៏មិនមែនជាកត្តាកំណត់ជ័យជម្នះក្នុងកិច្ចការពារប្រទេស និងកសាងប្រទេសយើងដែរ ។ វាគ្រាន់តែជាកត្តារួមផ្សំបន្តិចបន្តួចប៉ុណ្ណោះ ។ ដូច្នេះ យើងត្រូវប្រមូលអស់ថាមពលរបស់ប្រជាជាតិ និងប្រជាជនយើងប្រើឲ្យអស់លទ្ធភាព និងទុនដែលយើងមាន ដើម្បីវាយសម្រុក កសាងប្រទេសយើងឲ្យបានខ្លាំងក្លា សម្បូរសប្បាយឆាប់រហ័ស អាចការពារប្រទេសយើងបានដោយឯករាជ្យ ម្ចាស់ការគ្រប់ពេលវេលា ។

**វិធានការដាក់ស្តែង ៈ**

ដើម្បីការពារប្រទេស និងកសាងប្រទេសដោយឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួនយ៉ាងនេះបាន ៈ

១) ចំពោះមុខនេះ យើងត្រូវវាយសម្រុកបង្កបង្កើនផលខាងកសិកម្ម ពិសេស ស្រូវ ពោត សណ្តែក កៅស៊ូ ត្រី ឈើ ។ល ។ ឲ្យបានច្រើនបំផុតដើម្បីធ្វើជាទុនសម្រាប់ពង្រីកកសិកម្មផង កសាង និងពង្រឹង ពង្រីក ឧស្សាហកម្មផង បម្រើកិច្ចការពារប្រទេស ផង និងកែប្រែជីវភាពប្រជាជនយើង ។ ខាងឧស្សាហកម្ម យើងធ្វើដែរ តែជាបន្ទាប់ ព្រោះយើងមិនសូវមានទុនខាងឧស្សាហកម្មនេះទេ ។



សកម្មភាពធ្វើការងារក្នុងកម្ពុជាប្រជាធិបតេយ្យ

តែបើខាងកសិកម្ម យើងមានទុនច្រើនលើសលប់ ហើយមានលទ្ធភាពវាយសម្រុកពេញទំហឹងដោយឯករាជ្យម្ចាស់ការបាន ។

២) ក្នុងការផលិតខាងកសិកម្មក្តី ខាងឧស្សាហកម្មក្តី យើងត្រូវខិតខំធ្វើដោយខ្លួនឯង ។ អ្វីដែលយើងត្រូវការ អ្វីដែលយើងមិនទាន់មាន ឬមិនទាន់ចេះ យើងត្រូវខិតខំច្នៃប្រឌិត ធ្វើឲ្យរស់រវើកជាក់ស្តែង និងសមស្របទៅតាមលទ្ធភាព និងមធ្យោបាយដែលយើងមានឲ្យទាល់តែកើត ឲ្យទាល់តែមាន ។ ត្រូវចៀសវាងដាច់ខាតនូវទស្សនៈ គោលជំហរ និងរបៀបរបបធ្វើការងារសម្បូរបែបដែលរត់តាមសម្ភារៈ រត់តាមបច្ចេកទេស និងវិទ្យាសាស្ត្រនាយទុនក្នុងការកសាងប្រទេសយើង ។ ពោលគឺបើខ្វះអ្វី ត្រូវការអ្វី គិតតែពីទាមទារទិញពីបរទេស ឬសុំជំនួយបរទេស ។

ឧទាហរណ៍ ៈ ចង់ធ្វើស្រែឲ្យបានច្រើន គិតតែពីត្រាក់ទ័រ ម៉ាស៊ីនបូមទឹក ម៉ាស៊ីនច្រូតស្រូវ ។ល ។ តើរបស់ទាំងនេះ យើងបានពីណា យើងបានសាំងពីណាចាក់ ។ ដូច្នេះ យើងត្រូវទិញពីបរទេស ឬសុំជំនួយបរទេស ។ បើយើងបង្កបង្កើនផល តាមរបៀបសម្បូរបែបយ៉ាងនេះ លទ្ធភាព និងមធ្យោបាយយើងរត់មិនទាន់ដោះមិនរួចទេ ។ ដូច្នេះ យើងឯករាជ្យ ម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួនពុំបានទេ ។ ដូច្នេះ យើងត្រូវបង្ខំចិត្តសុំទានជំនួយបរទេស ។ តើកិត្តិយសជាតិ ប្រជាជន និងចលនាបដិវត្តន៍យើងយ៉ាងណាទៅ? ដូច្នេះ យើងត្រូវតែខិតខំប្រមូលកម្លាំងប្រជាជនយើង វាយសម្រុកធ្វើស្រែ ប្រមូលផ្តុំមធ្យោបាយផលិតកម្មដែលយើងមានដោះស្រាយបញ្ហាទឹក លើកទំនប់ ជីកប្រឡាយ លើកភ្លឺឲ្យបានខ្ពស់ខ្ទង់ច្រើនស្អេកស្កះ នោះយើងប្រាកដជាបង្កបង្កើនផលបានច្រើនដោយឯករាជ្យ ម្ចាស់ការ ហើយអាចរក្សាលើកស្ទួយកិត្តិយសជាតិ ប្រជាជន និងចលនាបដិវត្តន៍យើងបានទៀតផង ។

៣) ក្នុងកិច្ចកសាងប្រទេសនេះ យើងត្រូវលើកកម្ពស់ស្មារតីសន្សំសំចៃបដិវត្តន៍ខ្ពស់បំផុតគឺសន្សំសំចៃតាំងពីអំបិលមួយគ្រាប់ ស្រូវមួយក្តួរ ឬកូនឡៅខ្វងតូចតាចមួយឡើងទៅ ។ ធ្វើយ៉ាងណាថែរក្សារបស់របរតូចធំទាំងអម្បាលម៉ាន ដែលយើងមានហើយនេះ ឲ្យបានគង់វង្សល្អ កុំឲ្យខូចខាត បាក់បែកខ្ចាត់ខ្ចាយអសារឥតការ ទុកសម្រាប់ប្រើប្រាស់ក្នុងការផលិតផ្សេងៗ ក៏ដូចក្នុងកិច្ចការពារប្រទេស និងកសាងប្រទេសយើងឲ្យបានយូរអង្វែងជាអតិបរមា កុំពិបាកធ្វើ ឬទិញ ឬសុំជំនួយពីបរទេសទៀតឡើយ ។ ត្រូវចេះស្រឡាញ់ ចេះស្តាយទ្រព្យសម្បត្តិរួម របស់របររួម ក៏ដូចជារបស់របរប្រើប្រាស់ផ្ទាល់ខ្លួន ។ កម្ចាត់ដាច់ខាតនូវទស្សនៈគោលជំហរខ្ជះខ្ជាយ ធ្វើអីគ្រង់ណាចោលត្រង់នោះ ខូចខាតអស់ប៉ុន្មានណាក៏មិនគិត ក៏មិនស្តាយ ។ ហូបផង ចោលផង ស្មើគ្នា គ្មានដឹងគង់នោះឡើយ ។ តាមពិសោធន៍ជាក់ស្តែងកន្លងមកឃើញថា មធ្យោបាយ និងលទ្ធភាពដូចគ្នា បើធ្វើខ្ជះខ្ជាយបានតែមួយ តែបើធ្វើដោយសន្សំសំចៃហ្មត់ចត់បានរហូតដល់១០ ។ ដូច្នេះ ការសន្សំសំចៃមានសារសំខាន់ណាស់ក្នុងការកសាងប្រទេស និងការពារប្រទេសយើងសព្វថ្ងៃនេះ ។ បើចេះសន្សំសំចៃមានទុនតែល្មមក៏យើងអាចកសាងប្រទេសបានចម្រើនឆាប់រហ័ស ។ តែបើខ្ជះខ្ជាយទោះបីយើងមានទុនច្រើនជាងសព្វថ្ងៃ១០-២០ដងទៅទៀត ក៏យើងមិនងាយនឹងកសាងប្រទេសឲ្យបានសម្បូរសប្បាយដែរ ។ ព្រោះបើធ្វើ១០ វាត្រូវខ្ជះខ្ជាយចោល ឬខូចខាតចោលអស់៧-៨-៩ទៅហើយ ។

កន្លងមក ក្នុងពេលដែល យើងមានតែបាតដៃទទេ ហើយក្នុងពេលដែលយើងធ្វើសង្គ្រាមយ៉ាងតឹងតែងលំបាកវេទនាខ្វះសព្វខ្វះគ្រប់ផង ម្តេចក៏យើងអាចឧបត្ថម្ភខ្លួនបានដោយឯករាជ្យម្ចាស់ការ ហើយវាយចក្រពត្តិអាមេរិក និងបរិវារឈ្នះទៀត ។ ចុះឥឡូវ យើងមានសុខសន្តិភាព យើងមានទុនសព្វបែបយ៉ាងយើងសង្ឃឹម ហើយជឿជាក់ថា យើងអាចវាយសម្រុកការពារប្រទេស និងកសាងប្រទេសដោយឯករាជ្យ ម្ចាស់ការ បានជ័យជម្នះលោតផ្លោះទៀតពុំខានឡើយ ។ ដើម្បីកិត្តិយសជាតិ ប្រជាជន និងចលនាបដិវត្តន៍កម្ពុជាយើង ដើម្បីឯករាជ្យ និងអធិបតេយ្យភាពនៃប្រទេសជាតិយើងដែលយើងទាំងអស់គ្នាស្រឡាញ់លើសអាយុជីវិតទៅទៀត ហើយដែលយើងទាំងអស់គ្នាស្រឡាញ់ខិតខំប្រយុទ្ធការពារជារៀងរហូតមក យើងត្រូវតែប្តេជ្ញាខិតខំរក្សា ហើយពង្រឹងពង្រីកនូវគោលជំហរ ឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន ខ្លួនកាន់កាប់វាសនាប្រទេសជាតិ និងប្រជាជនខ្លួនឲ្យរឹងប៉ឹងជាបន្តទៀត ដើម្បីការពារប្រទេស និងកសាងកម្ពុជាថ្មីឲ្យបានខ្លាំងក្លាសម្បូរសប្បាយ និងថ្កុំថ្កើងរុងរឿងយ៉ាងឆាប់រហ័សបំផុត ។

# ប្រវត្តិសាស្ត្រដៅទិសអនាគត

ឈាង ចំរើន មានអាយុ២៨ឆ្នាំ មកពីខេត្តតាកែវ មានចំណាប់អារម្មណ៍ខាងអានពីព្រឹត្តិការណ៍ជុំវិញប្រវត្តិសាស្រ្តកម្ពុជា និងប្រវត្តិសាស្រ្តប្រទេសផ្សេងៗ ។ ចំរើន បាននិយាយថា “ការបង្រៀនប្រវត្តិសាស្រ្តគឺជាយានដ៏សំខាន់មួយក្នុងការស្វែងយល់ពីផលប៉ះពាល់របស់ទង្វើពីអតីតកាល និងស្វែងរកផ្លូវនៃក្តីសង្ឃឹមសម្រាប់អនាគតដ៏ល្អប្រសើរមួយ” ។

យ៉ាងណាមិញ ចំរើន បានទទួលស្គាល់ថាខ្លួនមិនសូវដឹងពីបទពិសោធន៍ជូរចត់របស់ឪពុកម្តាយប៉ុន្មានទេ ។ គាត់បានដឹងពីរឿងខ្មែរក្រហមនៅពេលមួយដែលឪពុករបស់គាត់បាននិយាយរៀបរាប់ពីការបង្ខំឲ្យធ្វើការ ភាពអត់ឃ្លាន សង្រ្គាម និងការកាប់សម្លាប់ដែលកើតមាននៅក្នុងរបបខ្មែរក្រហម ។ ចាប់តាំងពីពេលនោះមក ចំរើន មិនដែលបានសួរនាំអ្វីបន្ថែមទៀតពីឪពុកឡើយ ព្រោះគាត់មានអារម្មណ៍ថា ពិបាកនឹងទទួលយក ។ ប៉ុន្តែ អ្វីដែលគាត់ដក់ជាប់នៅក្នុងចិត្តនោះ គឺសំណួរមួយដែលសួរថា “ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ខ្មែរគ្នាឯង?”

ក្រោយពីរៀនចប់វិទ្យាល័យនៅឆ្នាំ២០០៥ ចំរើន បានសម្រេចចិត្តចូលរៀនប្រវត្តិសាស្រ្តនៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ដូចបងប្រុសរបស់គាត់គឺ ឈាង តារា ។ នៅឆ្នាំ២០០៧ ចំរើន ត្រូវបានជំរុញលើកទឹកចិត្តដោយបងប្រុសខ្លួនឲ្យស្ម័គ្រចិត្តចូលបំរើការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយសង្ឃឹមថានឹងបានពង្រីក និងពង្រីងចំណេះដឹងរបស់ខ្លួនបន្ថែមទៀតទាក់ទងនឹងប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ ។ ចំរើន បានទទួល



ស្គាល់ថាតាមរយៈបំរើការស្ម័គ្រចិត្តជាមួយនឹងជនរងគ្រោះ និងជនដៃដល់របស់របបខ្មែរក្រហម ចំរើន ទទួលបានបទពិសោធន៍ជាច្រើន ។ គាត់មានឱកាសជួបសម្ភាសន៍ជាមួយនឹងអតីតកម្មាភិបាលខ្មែរក្រហម និងជនរងគ្រោះខ្មែរក្រហមនៅឯខេត្តមណ្ឌលគិរី ។ គាត់បាននិយាយថា ពេលស្តាប់ព្រឿងរ៉ាវរបស់ជនដៃដល់ និងជនរងគ្រោះម្តងៗ ចំរើន មានអារម្មណ៍ថា ច្របូកច្របល់ ប៉ុន្តែក៏មានអារម្មណ៍អាណិតអាសូរដល់ប្រជាជនខ្មែរទាំងអស់ដែលបានរួចផុតពីរបបពិឃាដខ្មែរក្រហមនេះ ។ បើទោះជា ចំរើន បានធ្វើការស្ម័គ្រចិត្តឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាតែរយៈពេលមួយសប្តាហ៍ក៏ដោយ ក៏គាត់នៅតែមានចំណាប់អារម្មណ៍កាន់តែខ្លាំងឡើងក្នុងការស្វែងរកចម្លើយរបស់សំណួរដែលបានដក់ជាប់ក្នុងចិត្តគាត់តាំងពីយូរណាស់មកហើយ ។ ចំរើន បាននិយាយថា គាត់បានអានឯកសារជាច្រើនដើម្បីឆ្លើយនឹងសំណួរនោះ ប៉ុន្តែនៅតែគិតថាចម្លើយដែលរកឃើញនោះមិនទាន់មានខ្លឹមសារពេញលេញនៅឡើយទេ ។

ក្រោយពេលដែលបញ្ចប់ថ្នាក់សកលវិទ្យាល័យ ចំរើន បានដើរតាមគោលដៅរបស់ខ្លួនដើម្បីបង្រៀនប្រវត្តិវិទ្យានៅអនុវិទ្យាល័យមួយនៅខេត្តកំពង់ស្ពឺ ។ ចំរើន បាននិយាយថា គាត់អាចរកចម្លើយនៃសំណួររបស់ខ្លួនបានពេញលេញ នៅពេលដែលសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ត្រូវបានរៀបរៀងឡើង និងត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ ។ ចំរើន ទទួលស្គាល់ថាសៀវភៅប្រវត្តិសាស្ត្រនេះបានផ្តល់នូវព័ត៌មានស្តីពីព្រឹត្តិការណ៍សំខាន់ៗ តាមលំដាប់លំដោយដែលរៀបរាប់ពីមូលហេតុដែលខ្មែរក្រហមឡើងកាន់អំណាច និងពីមនោគមន៍វិជ្ជាដែលខ្មែរក្រហមបានអនុវត្ត ។ បន្ថែមលើនេះក្រោយពីមានឱកាសចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋានស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅខេត្តកំពង់ស្ពឺ ក្រោមកិច្ចផ្តួចផ្តើមដោយមជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយក្រសួងអប់រំនោះ គាត់បានទទួលស្គាល់ថា វគ្គបណ្តុះបណ្តាលនេះបានពង្រីកចំណេះដឹង និងវិធីសាស្ត្របង្រៀនរបស់គាត់ក្នុងនាមជាគ្រូបង្រៀនវ័យក្មេងម្នាក់ ។ គាត់បានយល់ពីវិធីសាស្ត្របង្រៀនថ្មីៗមានប្រយោជន៍ដល់ការបង្រៀនពីព្រោះថា វិធីសាស្ត្រនេះបានឆ្លុះបញ្ចាំងពីអ្វីដែលសិស្សបានដឹងពីប្រធានបទដែលត្រូវរៀន អ្វីដែលសិស្សចង់ដឹង និងពីអ្វីដែលសិស្សបានរៀនពីប្រធានបទនោះ ។

នៅពេលដែលសួរពីកត្តាប្រឈមក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅកាន់សិស្សជំនាន់ក្រោយ ចំរើន បាននិយាយថាមានសិស្សជាច្រើនមិនជឿលើការពន្យល់បកស្រាយពីស្ថានភាពរស់នៅរបស់ប្រជាជនកម្ពុជានៅក្រោមរបបខ្មែរក្រហមទេ ។ គាត់តែងតែត្រូវបានចោទសួរសំណួរជាច្រើនដូចជាហេតុអ្វីបានជាប្រជាជនកម្ពុជានៅជំនាន់នោះមិនហ៊ានតដៃប្រឆាំងនឹងខ្មែរក្រហម និងថាតើហេតុអ្វីបានជា ប៉ុល ពត សម្លាប់ប្រជាជនកម្ពុជា ។ លើសពីនេះសិស្សខ្លះបានបញ្ចេញកំហឹង ហើយមានបំណងចង់សងសឹកអតីតកម្មាភិបាលខ្មែរក្រហម ។ ចំរើន ស្វាគមន៍វគ្គបណ្តុះបណ្តាលនេះ ពីព្រោះវគ្គបណ្តុះបណ្តាលនេះបានផ្តល់នូវព័ត៌មានសំខាន់ៗដើម្បីឲ្យគាត់ធ្វើការឆ្លើយតបនឹងសំណួររបស់កូនសិស្ស ។ សំខាន់ជាងនេះ តាមរយៈសេចក្តីណែនាំនិងការពន្យល់បកស្រាយពីសារសំខាន់នៃការយល់ដឹងពីចិត្តសាស្ត្រក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅកាន់កូនជនរងគ្រោះ និងកូនជនដៃដល់ គាត់សង្ឃឹមថា នឹងប្រើប្រាស់វិធីសាស្ត្ររបស់វេជ្ជបណ្ឌិត កា ស៊ុនបូណាត ដើម្បីកាត់បន្ថយកំហឹង និងប្រតិកម្មភ្លាមៗរបស់សិស្សនៅពេលដែលដឹងពីការកាប់សម្លាប់របស់ជនដៃដល់ដែលនៅរស់រានមានជីវិត ។

ក្នុងនាមជាគ្រូបង្រៀនប្រវត្តិសាស្ត្រវ័យក្មេង ចំរើន សង្ឃឹមថានឹងបានចូលរួមយ៉ាងសកម្មក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅកាន់ក្មេងជំនាន់ក្រោយ ។ ចំរើន ជឿជាក់ថាការបង្រៀនប្រវត្តិសាស្ត្រនេះនឹងជួយឲ្យសិស្សជំនាន់ក្រោយស្វែងយល់ពីផលប៉ះពាល់នៃទង្វើកាលពីអតីតកាល បង្រៀនឲ្យក្មេងជំនាន់ក្រោយចេះអត់ឱនអធ្យាស្រ័យគ្នា ហើយរៀនអត់ឱនទោស និងបំភ្លេចអតីតកាល ដើម្បីធានាថាអនាគតរបស់កម្ពុជាមានសុវត្ថិភាព ។ នៅពេលដែលសួរពីគោលដៅទៅថ្ងៃអនាគត ចំរើន បាននិយាយថា គាត់បានប្តេជ្ញាថានឹងបន្តកិច្ចការបង្រៀនរបស់ខ្លួនដើម្បីចូលរួមចំណែកនៅក្នុងការផ្សះផ្សាជាតិ ។

**ទែន សុខស្រីនិត**

# ម្ដាយនិងកូនជាប់គុកនៅភ្នំទ្រយោង

គុកភ្នំទ្រយោងជាគុកមួយស្ថិតនៅក្នុងភូមិទ្រយោង ឃុំភ្នំលៀប ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ដែលបច្ចុប្បន្ននេះត្រូវបានសាលាក្ដីខ្មែរក្រហមចាត់ទុកជាទីតាំងឧក្រិដ្ឋកម្មមួយក្នុងចំណោមទីតាំងឧក្រិដ្ឋកម្មជាច្រើនទៀតក្នុងសំណុំរឿង ០០៤ ។ ស្ដ្រីម្នាក់ឈ្មោះ ណាន់ អាយុ៧៨ឆ្នាំ បានរៀបរាប់ឲ្យដឹងថា គាត់ធ្លាប់ជាប់គុកនៅភ្នំទ្រយោងដោយសារប្ដីរបស់គាត់រត់គេចខ្លួនពីការតាមសម្លាប់របស់កម្មាភិបាលខ្មែរក្រហម ។ ពេលនោះ កូនរបស់គាត់ឈ្មោះ ខេង អាយុប្រហែលជាងដប់ឆ្នាំក៏ជាប់គុកនៅទីនោះជាមួយគាត់ដែរ ។

ណាន់ កើតនៅឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) និងជាកូនច្បងក្នុងចំណោមបងប្អូនប្រាំមួយនាក់ (ស្រីប្រាំនាក់ និងប្រុសម្នាក់) ។ ឪពុកម្ដាយរបស់ណាន់ ស្លាប់តាំងពីសម័យសង្គមរាស្ត្រនិយមមកម្ល៉េះ ។ កាលនៅក្មេង ណាន់មិនដែលបានចូលរៀនទេ ព្រោះរវល់ជួយធ្វើស្រែចម្ការឪពុកម្ដាយ ។ ក្រោយពីរៀបការជាមួយប្ដីឈ្មោះ សែ រួចមក គាត់នៅតែបន្តរស់ក្នុងភូមិកំណើតនេះដដែល ដោយប្រកបការងារធ្វើស្រែចម្ការ ។ ពេលនោះ ណាន់មានកូនចំនួនប្រាំនាក់ក្នុងចំណោមនោះ មានតែកូនម្នាក់ប៉ុណ្ណោះដែលនៅរស់រហូតដល់សព្វថ្ងៃនេះ ។ កូនបីនាក់បានស្លាប់មុនរបបខ្មែរក្រហម និងម្នាក់ទៀតស្លាប់នៅសម័យខ្មែរក្រហម ដោយសារជំងឺ និងគ្មានពេទ្យព្យាបាល ។


ណាន់ ផ្ដល់បទសម្ភាសន៍នៅផ្ទះរបស់គាត់

នៅឆ្នាំ១៩៧៥ អ្នកភូមិទាំងអស់ រួមទាំងគ្រួសាររបស់ណាន់ ត្រូវបានជម្លៀសឲ្យទៅរស់នៅភ្នំកូនដំរី ។ គ្រួសាររបស់ណាន់មានរទេះគោមួយសម្រាប់ដឹកសម្ភារដូចជាស្រូវ និងអង្ករ ។ ណាន់រស់នៅភ្នំកូនដំរីបានមួយរយៈ ខ្មែរក្រហមបានជម្លៀសគ្រួសារគាត់និងអ្នកភូមិបន្តទៅភូមិស្រែះ បន្ទាប់មកទៅភូមិប៉ោយព្រីង ស្ថិតនៅក្នុងឃុំព្រះនេត្រព្រះ ។ ណាន់ ត្រូវបានចាត់តាំងឲ្យកាប់ឆ្ការព្រៃនៅភូមិប៉ុស្តិ៍ចាស់ ។ បន្ទាប់ពីកាប់ឆ្ការហើយ ខ្មែរក្រហមបានធ្វើខ្ទមមួយសម្រាប់ឲ្យគ្រួសារគាត់ស្នាក់នៅ ។ ក្រោយមកទៀត គាត់ត្រូវបានចាត់តាំងឲ្យដាំដំឡូង និងច្រូតស្រូវ ។ ចំណែកប្ដីគាត់ត្រូវបញ្ជូនឲ្យទៅលើកទំនប់នៅភូមិកំបោរស្រែះ ឃុំព្រះនេត្រព្រះ ក្រោយមកគាត់ធ្វើជាជំនួយការរបស់ វ៉ាល់ ដែលជាប្រធានកងចល័តតំបន់៥ ។ ចំពោះការហូបចុកវិញគឺមានតែបបរម្នាក់មួយវែកប៉ុណ្ណោះ ។ ណាន់បានបញ្ជាក់ថា "ក្នុងរបបខ្មែរក្រហមគាត់ហូបមិនគ្រប់គ្រាន់ទេ" ។

ពេលនោះ លេខាឃុំព្រះនេត្រព្រះឈ្មោះ គ្រក ។ ក្រោយមក គ្រក ត្រូវបានចាប់ខ្លួន រួចហើយផ្លាស់កម្មាភិបាលមកពីភូមិភាគនិរតីចូលកាន់តំណែងជំនួសវិញ ។ ចំណែកប្ដីរបស់ ណាន់ ក៏បានរត់គេចខ្លួនដោយសារតែភាពភ័យខ្លាច តែទីបំផុតកម្មាភិបាលមកពីភូមិភាគនិរតីតាមចាប់ខ្លួនបាន ។ ណាន់ មិនបានដឹងពីមូលហេតុដែលគាមចាប់ប្ដីរបស់គាត់ទេ ។ ណាន់ បានអះអាងថា "ប្ដីរបស់ខ្ញុំគ្មានកំហុសទេ តែកម្មាភិបាលមកពីភូមិភាគនិរតីបញ្ជាឲ្យចាប់គាត់" ។ ណាន់ បានរៀបរាប់ថា ប្ដីគាត់បានរត់ទៅគោកមន និងបេង នៅព្រំប្រទល់ខ្មែរ-ថៃ ។ ណាន់ ដឹងច្បាស់ថា ប្ដីរបស់គាត់ត្រូវបានចាប់នៅខេត្តឧត្តរមានជ័យ ។

ក្រោយពីប្តីរបស់គាត់បានរត់គេចខ្លួនអស់រយៈពេលកន្លះខែ ណាន់ ត្រូវបានចាប់យកមកដាក់គុកភ្នំទ្រយោងជាមួយកូនប្រុសរបស់គាត់ឈ្មោះ ខេង ទៅជាមួយផង ។ ណាន់ បានរៀបរាប់ថា «កម្មាភិបាលខ្មែរក្រហមយកខ្ញុំទៅភ្នំទ្រយោង ដើម្បីហាត់ពត់លត់ដំ ហើយប្រសិនបើយើងទៅលួចរបស់របរអ្វីហូប ឆ្នាំគុកនឹងវាយយើងចោល» ។ ណាន់ មិនបានចាំឆ្នាំប្រាកដពេលដែលខ្មែរក្រហមចាប់គាត់មកដាក់ឃុំឃាំងទេ ប៉ុន្តែគាត់ចាំថា គាត់ជាប់នៅទីនោះប្រមាណជាមួយខែប៉ុណ្ណោះមុននឹងវៀតណាមចូលមក ។ ណាន់ បានបញ្ជាក់ថា អ្នកទោសប្រុសនិងស្រីរស់នៅដេរុងគ្នា ។ ចំណែក ណាន់ និងកូនប្រុសរបស់គាត់ក៏ប្រធានគុកមិនឲ្យនៅជាមួយគ្នាដែរ ។ ណាន់ បាននិយាយថា «អ្នកទោសប្រុសៗត្រូវបានចាត់តាំងឲ្យវាយបំបែកថ្ម» ។ ចំណែក ណាន់ ត្រូវបានចាត់តាំងឲ្យកាប់ទន្រ្ទានខែត្រ ធ្វើជី និងប្រូតស្រូវ រីឯការហូបចុកវិញគឺមានតែបបរម្នាក់មួយវែកប៉ុណ្ណោះ ។ ទោះជាអត់ឃ្លានយ៉ាងណាក៏គាត់មិនហ៊ានទៅលួចដំណាំហូបដែរ ព្រោះ «បើយើងទៅលួច គេតាមទាន់គេវាយយើង ។

ខេងដែលអង្គុយនៅក្បែរម្តាយ (ណាន់) ក្នុងអំឡុងពេលសម្ភាសន៍នោះ បានបញ្ជាក់ថា «មានក្មេងជាច្រើនទៅតាមម្តាយពេលចេញទៅធ្វើការ» ។ ក្រោយមក ខេង ត្រូវបានចាត់តាំងឲ្យទៅរស់នៅឆ្ងាយពីម្តាយ ។ ខេង ធ្លាប់លួចមកលេងផ្ទះម្តងនៅភូមិត្រពាំងវែង ឃុំព្រះនេត្រព្រះ ។ ខេង បន្តថា «ខ្ញុំលួចមកផ្ទះម្តង ។ ពេលខ្ញុំដើរមកផ្ទះ កម្មាភិបាលម្នាក់សួរខ្ញុំថា ទៅណា? ខ្ញុំថាទៅបើកអង្ករ» ។ ដោយសារខ្ញុំជាកូនក្មេងទើបមិនសូវមាននរណាចាប់អារម្មណ៍នឹងខ្ញុំ» ។ ខេង បានបន្ថែមទៀតថា «យប់ស្ងាត់ អត់មាននរណាហ៊ានដើរចេញទេ» ។

ខេង ក៏ត្រូវចាត់តាំងឲ្យកាប់ទន្រ្ទានខែត្រជាមួយក្មេងដទៃ ។ ពេលនោះក្មេងៗដែលមានអាយុប្រហាក់ប្រហែលនឹង ខេង ខ្លះត្រូវទៅនៅម្តុំដើងភ្នំដើម្បីកើបអាចម៍គោយកមកធ្វើជី ។ ពេលខ្លះ ខេង បានទៅតាមម្តាយគាត់ធ្វើការ និងបានឃើញអ្នកទោសបុរសកំពុងជាប់ខ្នោះ ប៉ុន្តែមិនដឹងថាមានកំហុសអ្វីទេ ។

ខេង និយាយថា «ពេលខ្ញុំដើរទៅបើករបប ខ្ញុំឃើញជើងអ្នកទោសជាប់ខ្នោះ និងដេកនៅក្នុងរោងមួយ» ។ ចំណែកការសម្លាប់ ខេង មិនដែលបានដឹងនោះទេ ។ ខេង បានបន្តថា គាត់ឮថា សឿន គឺជាប្រធានគុកភ្នំទ្រយោង ប៉ុន្តែគាត់មិនដែលបានឃើញមុខ សឿន ទេ ។ ចំណែក ណាន់ ធ្លាប់ឮឈ្មោះ អ៊ុម ចែម ប៉ុន្តែគាត់មិនដឹងថា អ៊ុម ចែម ជានរណាទេ ។


ទិដ្ឋភាពស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

នៅពេលកងទ័ពវៀតណាមមកដល់ ខេង បានឮសំឡេងមីក្រូប្រកាសឲ្យប្រជាជនត្រឡប់មកផ្ទះ និងបានឮសំឡេងសន្ទឹកឡានរបស់កងទ័ពវៀតណាមយ៉ាងច្រើន ហើយប្រជាជនក៏នាំគ្នារត់ ។ ចំណែក ណាន់ អះអាងថា «ពុំមានអ្នកទោសនៅសល់ទេ សូម្បីតែអ្នកទោសដែលជាប់ខ្នោះក៏មិនមានដែរ ។ ទាំងអស់គ្នានាំគ្នារត់» ហើយ ណាន់ និងកូនបានត្រឡប់មករស់នៅស្រុកកំណើតរហូតដល់សព្វថ្ងៃ ។

**ហ៊ិន សុធានី**

# អតីតសន្តិសុខវ័យក្មេងនៅគុកភ្នំទ្រយោង

ក្នុងវ័យ១៧ឆ្នាំ ស៊ុម សល់ ត្រូវបានខ្មែរក្រហមជ្រើសរើសចេញពីកងនិរសារឃុំរហាល ស្រុកព្រះនេត្រព្រះដើម្បីមកធ្វើជាអ្នកយាមនៅមន្ទីរសុខគុកភ្នំទ្រយោងក្នុងឆ្នាំ១៩៧៨ ។ ប្រជាជនរស់នៅស្រុកព្រះនេត្រព្រះភាគច្រើនបានស្គាល់គុកភ្នំទ្រយោងនេះថា ជាគុកមួយក្រោមការគ្រប់គ្រងរបស់ អ៊ឹម ចែម លេខាស្រុកព្រះនេត្រព្រះពីឆ្នាំ១៩៧៧ ដល់ខែមករា ឆ្នាំ១៩៧៩ ។ អ្នកស្រុកបានដឹងថា ផ្ទះរបស់ អ៊ឹម ចែម មានទីតាំងនៅភ្នំល្វៀបដែលមានចម្ងាយប្រមាណពីរគីឡូម៉ែត្រប៉ុណ្ណោះពីគុកភ្នំទ្រយោងនេះ ។

កើតនៅឆ្នាំ១៩៦០ នៅភូមិស្ទឹងកំបុត ឃុំរហាល ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង (បច្ចុប្បន្ន ខេត្តបន្ទាយមានជ័យ) សល់ មានឪពុកឈ្មោះ ស៊ុម ផាន់ និងម្តាយឈ្មោះ ជួប នៅ ។ សល់ រៀនត្រឹមថ្នាក់ទី១០ នៅសាលាបឋមសិក្សាសំបួរ ហើយក៏ឈប់រៀននៅឆ្នាំ១៩៧២ ដោយសារតែបញ្ហាអសន្តិសុខនៅក្នុងប្រទេស ហើយគ្រូបង្រៀនបានបោះបង់ចោលសាលាផង ។

ក្នុងឆ្នាំ១៩៧៣ ទាហាន លន់ នល់ បានបើកការវាយលុកចូលទៅភូមិកំណើតរបស់ សល់ និងកៀរអ្នកភូមិឲ្យមករស់នៅទីប្រជុំជនមួយចំនួនដូចជានៅជប់វារី ទឹកថ្លា និងស្វាយស៊ីសុផុន វិញ ព្រោះទីនោះត្រូវបានគ្រប់គ្រងដោយរបបសាធារណរដ្ឋខ្មែរ ។ សល់ និងក្រុមគ្រួសារក៏ត្រូវបានជម្លៀសទៅនៅទីប្រជុំជនដែរ ។

ពេលខ្មែរក្រហមបានកាន់កាប់ប្រទេសកម្ពុជាទាំងស្រុងនៅឆ្នាំ១៩៧៥ សល់ និងគ្រួសារបានត្រឡប់ចូលមករស់នៅស្រុកកំណើតវិញ ។ ខ្មែរក្រហមបានរៀបចំភូមិឃុំ និងចាត់តាំងឈ្មោះ ហ៊ាន ឲ្យធ្វើជាប្រធានភូមិ ដោយខណៈពេលនោះខ្មែរក្រហមឲ្យហូបជាលក្ខណៈឯកជននៅឡើយ ។ បន្ទាប់ពីធ្វើស្រែបានមួយវស្សា ខ្មែរក្រហមបានជម្លៀសប្រជាជននៅភូមិស្ទឹងកំបុតទាំងអស់ឲ្យមករស់នៅភ្នំកូនដំរីដែលមានទីតាំងនៅខាងត្បូងឃុំព្រះនេត្រព្រះវិញ ។ សល់ បានរៀបរាប់ថា នៅទីនោះជីវភាពមានការខ្វះខាតជាខ្លាំង ហើយអង្ករដែលទទួលបានមានចំនួនបន្តិចបន្តួចប៉ុណ្ណោះ ។ ពេលខ្លះ កម្មាភិបាលខ្មែរក្រហមបើកកន្ទក់ឲ្យប្រជាជនហូប ។ គ្រួសាររបស់ សល់ ធ្លាប់យកកន្ទក់ទៅលីងលាយទឹកអំបិលដើម្បីហូប ។ សល់ ត្រូវបានប្រធានភូមិចាត់តាំងឲ្យទៅធ្វើការក្នុងកងកុមារដែលមានកុមារសរុបទាំងអស់៣០នាក់ ដោយឃ្វាលគោជាច្រើនក្បាលនៅតាមជើងភ្នំកូនដំរី ។ ការហូបចុកនៅនៅតែមានការលំបាក ។ សល់ បានរៀបរាប់ថា «យើងនាំគ្នារកកន្ទក់បណ្តើរ ដើរឃ្វាលគោបណ្តើរ ដោយសារការហូបមិនឆ្អែត ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏មិនមានអ្នកណាម្នាក់ហ៊ាននិយាយថាហូបមិនឆ្អែតទេ គឺនៅស្ងៀម» ។


ស៊ុម សល់

នៅចុងឆ្នាំ១៩៧៦ ឪពុកម្តាយ សល់ បានផ្លាស់មករស់នៅភូមិរហាល ឃុំព្រះនេត្រព្រះវិញ ។ ពេលមកដល់ភូមិរហាល សល់ មិនត្រូវអនុញ្ញាតឲ្យរស់នៅជួបជុំឪពុកម្តាយទៀតឡើយ គឺត្រូវបំបែកឲ្យទៅធ្វើការនៅកងចល័តឃុំទានកាំ ដែលមាន វ៉ាន ជាប្រធានកងចល័តឃុំ និង ស ជាលេខាឃុំ ។ បន្ទាប់ពីលេខាឃុំឈ្មោះ ស បាត់ខ្លួន ណុញ មកពីកំពតធ្វើជាលេខាឃុំជំនួស ។ ក្រោយមក កម្មាភិបាលមកពីភូមិភាគនិរតីម្នាក់ឈ្មោះ រស់ ចូលមកជំនួសទៀត ។ សល់ បានរៀបរាប់ថា ការងារកងចល័តឃុំមាន

ដូចជា លើកទំនប់ប្រឡាយ ប្រព័ន្ធភ្លឺស្រែ ពីឃុំទានកាំភ្លាប់មកគោកឈើនាង ហើយមានអ្នកខ្លះចាប់កណ្តុរ ឬសត្វល្អិតផ្សេងៗយកមកហូបដោយសារតែអត់ឃ្លានខ្លាំង ។

ក្រោយមក សល់ ត្រូវបានប្រធានកងចល័តឃុំ វ៉ាន ហៅឲ្យមកធ្វើជានិរសារគាត់រត់សំបុត្រទៅតាមភូមិនិងសហករណ៍ផ្សេងៗ ។ សល់ បានរៀបរាប់ថា «ទោះបីបាននៅជិតថ្នាក់ដឹកនាំក៏ដោយ ក៏នៅក្នុងចិត្តមានការតក់ស្លុត និងភ័យខ្លាចជារៀងរាល់ថ្ងៃដែរ ព្រោះខ្លាចអង្គការយកទៅសម្លាប់ចោល» ។ សល់ បានបញ្ជាក់ថា ពេលប្រធានឃុំឈ្មោះ ស ជាអ្នកគ្រប់គ្រងស្ថានភាពក្នុងភូមិឃុំមានការលំបាកជាមធ្យមទេ ប៉ុន្តែពេលផ្លាស់កម្មាភិបាលមកពីភូមិភាគនិរតីគ្រប់គ្រងជំនួសវិញ ស្ថានភាពកាន់តែលំបាកខ្លាំងឡើងៗ ទាំងការងារ និងការហូបចុក ។

នៅចុងឆ្នាំ១៩៧៧ សល់ បានសុំប្រធានឃុំឈ្មោះ រស់ ទៅធ្វើការនៅភូមិរហាលវិញ ដោយយកលេសថាសុំទៅផ្ទះវិញ ។ នៅពេលនោះ រស់ បានសួរគាត់ថា «មិត្តឯងសុំទៅនៅផ្ទះវិញនេះមានមូលហេតុអ្វី?» សល់ ក៏បានឆ្លើយប្រាប់ភ្លាមថា «ខ្ញុំនឹកម៉ែនឹកឪ ពីព្រោះខ្ញុំបែកគាត់យូរគ្រាន់ហើយ» ។ បន្ទាប់មក រស់ បានធ្វើសំបុត្រមួយឲ្យ សល់ កាន់មករកឪពុកម្តាយវិញ ។ ឪពុកម្តាយរបស់គាត់បានប្រាប់ឲ្យគាត់យកសំបុត្រទៅប្រាប់ខាងសហករណ៍ដើម្បីបានបបរហូប ព្រោះបើគ្មានសំបុត្រគឺគ្មានរបបហូបទេ ។

នៅពេលជួបប្រធាននារីឃុំរហាលឈ្មោះ ថា ហើយបានមើលសំបុត្ររបស់ សល់ រួច គាត់ក៏ស្នើ សល់ ឲ្យធ្វើជានិរសាររបស់គាត់ទៀត ។ បន្ទាប់មក សល់ បានទៅរស់នៅផ្ទះជាមួយថា រួមជាមួយយុវជនក្មេងៗ ប្រហែលជាដប់នាក់ផ្សេងទៀត ។ ការងាររបស់និរសារនៅពេលនោះគឺដើរមើលដំណាំ និងការពារកុំឲ្យប្រជាជនចូលលួចបូតស្រូវ និងដំឡូងហូប ។ ប៉ុន្តែបានតែមួយរយៈខ្លី បុរសម្នាក់ឈ្មោះ ណុប ក៏មកកាន់តំណែងជំនួស ថា ។ ពេលនៅជាមួយ ណុប ការងាររបស់និរសារមានដូចជា រត់សំបុត្រពីសហករណ៍មួយទៅសហករណ៍មួយទៀត ។ សល់ បញ្ជាក់ថា រាល់សំបុត្រទាំងអស់សុទ្ធតែបិតជិតឈឹង មិនអាចបើកមើលបានទេ ។

នៅឆ្នាំ១៩៧៨ ប្រធានឃុំឈ្មោះ ណុប បានប្រាប់ សល់ ថា ប្រធានគុកភ្នំទ្រយោងត្រូវការជ្រើសរើសសន្តិសុខមួយចំនួនដើម្បីយាមអ្នកទោស ។ បន្ទាប់មក ណុប ក៏បានបញ្ជូន សល់ ឲ្យទៅធ្វើសន្តិសុខនៅគុកភ្នំទ្រយោង ។ នៅពេលទៅដល់ភ្លាម សល់ បានជួបប្រធានគុកភ្នំទ្រយោងឈ្មោះ សឿន ដែលមានកំណើតនៅខេត្តតាកែវ ។ សល់ បានរៀបរាប់ពី សឿន ថា «គាត់មានរាងសង្ហាសម្បុរ សជ្រះ សក់ស្កូត មានពុកមាត់ស្រមូម និងមានកម្ពស់ប្រហែលជាមួយម៉ែត្រចិតសិប ។ គាត់មាន ប្រពន្ធនិងកូនប្រុសពីរនាក់ដោយកូនប្រុសបងមានឈ្មោះ នូ និងកូនប្រុសពៅមិនស្គាល់ឈ្មោះ» ។

នៅពេល សល់ ក្លាយជាកងសន្តិសុខការពារអ្នកទោស អង្គការបានបើកខោអាវថ្មីជាឯកសណ្ឋានពណ៌ខ្មៅ ស្បែកជើងកង់ឡាន មួកកន្តិបពណ៌អាចម៍សេះផលិតនៅប្រទេសចិន និង ក្រមាមួយសម្រាប់បង់ក ព្រមទាំងកាំភ្លើងការ៉ាប៊ីនមួយដើម ។ សល់ និយាយថា សន្តិសុខនៅគុកភ្នំទ្រយោងមានចំនួនសរុបប្រហែល ៣០ នាក់ដោយបែកចេញជាបីក្រុមតូចៗ ។ សល់ ស្ថិតនៅក្នុងក្រុមដែលយាមការពារអ្នកទោសវាយថ្ម និងធ្វើស្រែចម្ការ ដោយក្នុង



នោះមានឈ្មោះដូចជាៈ ខេច, យៃ, ធឿន និង អយ ។

សល់ បានរៀបរាប់ពីទីកន្លែងរបស់គុកថា នៅទីនោះមានរោងសម្រាប់សន្តិសុខ និងមានរោងវែងមួយសម្រាប់ដាក់អ្នកទោសដែលស្ថិតនៅជាប់ជើងភ្នំ ។ អ្នកទោសត្រូវបានបែងចែកជាពីរកម្រិតដែរ គឺកម្រិតធ្ងន់ និងកម្រិតស្រាល ដោយមានអ្នកទោសប្រុស ស្រី ក្មេង ចាស់រាប់រយនាក់ ។ ចំពោះអ្នកទោសកម្រិតធ្ងន់ត្រូវដាក់ខ្នោះជើងដែលធ្វើអំពីឈើមានចោះរន្ធ ហើយស៊ករនុកដែក ។ នៅពេលប្រជុំម្តងៗ សឿន តែងតែណែនាំកងការពារគុកទាំងអស់ថា «ធ្វើយ៉ាងកុំឲ្យមានអ្នកទោសណាម្នាក់លួចរត់ ត្រូវប្រុងប្រយ័ត្ននៅពេលបណ្តើរអ្នកទោសទៅធ្វើការ ហើយមិនត្រូវនៅជិតអ្នកទោសទេព្រោះខ្លាចអ្នកទោសដណ្តើមយកកាំភ្លើងបានបាញ់សម្លាប់សន្តិសុខវិញ ។ ករណីបើអ្នកទោសលួចរត់ កងការពារមានសិទ្ធិបាញ់អ្នកទោសនោះចោល ហើយបើអ្នកទោសរត់រួចកងការពារអាចមានទោសដល់ស្លាប់» ។ ក្រៅពី សឿន នៅមានឈ្មោះ ភីម និង ថង ជាអ្នកគ្រប់គ្រងនៅទីនោះដែរ ។

សល់ បានបន្ថែមទៀតថា នៅមន្ទីរសន្តិសុខគុកភ្នំទ្រយោងក៏មានកន្លែងសួរចម្លើយ និងធ្វើទារុណកម្មដែរ ប៉ុន្តែមិនដឹងច្បាស់ថាទីតាំងនោះនៅកន្លែងណាមួយទេ ។ ចំណែកអ្នកសួរចម្លើយគឺខ្មែរក្រហមជ្រើសរើសយកអ្នកណាដែលមានមាឌធំៗ ។ សល់ សម្គាល់ឃើញថា នៅមន្ទីរសន្តិសុខភ្នំទ្រយោងនេះ មានអ្នកទោសខ្លះស្លាប់ដោយសារការសម្លាប់ ឈឺ និងអត់ឃ្លាន ។

សល់ បានបន្ថែមទៀតថា នៅពេលដែលកងទ័ពវៀតណាមជិតចូលមកដល់ អ៊ឹម ចែម បានកោះហៅកងសន្តិសុខនៅភ្នំទ្រយោងទាំងអស់ទៅប្រជុំនៅផ្ទះរបស់គាត់នៅភ្នំលៀប ។ សល់ នៅចាំពាក្យរបស់ ចែម ថា «ឥឡូវនេះយួនចូលមកជិតដល់ស្រុកខ្មែរយើងហើយ ដូច្នេះយើងត្រូវប្រុងប្រយ័ត្ន ។ យួននឹងចូលមកយកក្បាលយើង និងអារ-កយើងនឹងផាងត្នោត» ។ ពាក្យនោះធ្វើ សល់ ភ័យយ៉ាងខ្លាំង ។ សល់ បន្តថា «ក្មេងៗមួយចំនួនទៀតមានការភ័យខ្លាច ហើយនាំគ្នារត់ចូលព្រៃតាមកម្មាភិបាលខ្មែរក្រហមផ្សេងទៀតដោយក្នុងនោះមាន ខេច, យៃ, ធឿន, និង អយ ផង ។ អ្នកទាំងនេះរត់ទៅនៅជាយដែនថៃ ក្រោយមកត្រូវស្លាប់ដោយសារជំងឺគ្រុនចាញ់ ជាន់មីន និងត្រូវគ្រាប់ ។

ក្រោយមក សល់ បានរៀបការនៅឆ្នាំ១៩៨៣ ហើយរស់នៅខេត្តបន្ទាយមានជ័យរហូតដល់សព្វថ្ងៃ ។ **សុខ វណ្ណៈ**



# អ្នករៀបចំម្ហូបសម្រាប់ ខៀវ សំផន


មាស ចាន់ណា

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មាស ចាន់ណា មានតួនាទីជាអ្នករៀបចំម្ហូបសម្រាប់លោក ខៀវ សំផន ។ ចាន់ណា និយាយថា «ខៀវ សំផន ជាមនុស្សស្លូតបូត និងមានសន្តានចិត្តល្អ ដោយគាត់ធ្លាប់យកម៉ាស៊ីនថតមកថតរូបឲ្យខ្ញុំ និងមិត្តរបស់ខ្ញុំទៀត» ។ ប៉ុន្តែ ពេលឃើញ ខៀវ សំផន និងមេដឹកនាំផ្សេងទៀតត្រូវបាននាំខ្លួនមកកាត់ទោសនៅតុលាការខ្មែរក្រហមបែបនេះ ធ្វើឲ្យគាត់យល់ថា «មេដឹកនាំទាំងនេះមិនល្អដូចជាអ្វីដែលគាត់បានគិតនោះទេ» ។ មាស ចាន់ណា សព្វថ្ងៃអាយុ៥០ឆ្នាំ រស់នៅស្រុកជុំគិរី ខេត្តកំពត ។ ចាន់ណា មានមុខរបរធ្វើស្រែចម្ការ ។ ម្តាយរបស់ ចាន់ណា ស្លាប់នៅឆ្នាំ១៩៧៩ ។

ចាន់ណា ជាកូនទីបួននៅក្នុងចំណោមបងប្អូនប្រាំមួយនាក់ (ប្រុសពីរ និង ស្រីបួន) ។ កាលពីនៅតូច ដោយសារតែជីវភាពគ្រួសារក្រីក្រពេក ចាន់ណា បានឈប់រៀនត្រឹមថ្នាក់ទីពីរនៅវត្តស្រែ រួចមកជួយធ្វើស្រែឪពុកម្តាយនៅផ្ទះវិញ ។

នៅពេលដែលខ្មែរក្រហមចូលកាន់កាប់អំណាចទាំងស្រុងនៅឆ្នាំ១៩៧៥ ចាន់ណា និងក្មេងៗនៅក្នុងភូមិពោធិ៍ចំនួនប្រហែលជា៤០នាក់ត្រូវបានចាត់តាំងឲ្យចូលកងចល័តរែកដីនៅអូរផ្តៅ ក្រោមការដឹកនាំរបស់គ្រូឈ្មោះ ថន ប្រធានភូមិឈ្មោះ តាឌឹក និងប្រធានឃុំ តាផែន ។ នៅទីនោះ រយៈពេលមួយសប្តាហ៍ទើប ចាន់ណា ត្រូវបានអនុញ្ញាតឲ្យត្រឡប់មកសួរសុខទុកឪពុកម្តាយម្តង ដោយសារតែការងាររមមាញឹកខ្លាំងពេក ។ ពេលមកដល់ផ្ទះម្តងៗ ចាន់ណា សប្បាយរីករាយណាស់ ចំណែកម្តាយរបស់គាត់តែងតែណែនាំគាត់ថា «កូនកុំមកផ្ទះ ព្រោះយើងនៅក្រោមបង្គាប់គេ» ។ នៅពេលខ្លះ ចាន់ណា ត្រូវទៅលើកទំនប់នៅស្ទឹងកេ រយៈពេលពីរបីខែទើបបានត្រឡប់មកផ្ទះវិញ ។ នៅទីនោះ ចាន់ណា តែងតែព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួនជានិច្ច ព្រោះអ្នកដែលចូលកងចល័តជំណាលគាត់ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោលទាំងខ្សែៗ ។

នៅឆ្នាំ១៩៧៧ អង្គការចាប់ផ្តើមជ្រើសរើសអ្នកដែលមានប្រវត្តិស្អាតស្អំ ធ្វើការសកម្ម និងអត់ធ្មត់នឹងការងារ ហើយស្ថិតនៅក្នុងកុមារឈានមុខឲ្យទៅធ្វើការនៅភ្នំពេញ ដោយក្នុងមួយឃុំទាំងមូលមានចំនួន១៥នាក់ ក្នុងនោះភូមិពោធិ៍មានចំនួនប្រាំនាក់ ដូចជាឈ្មោះ ទ្រោធ, គាត់, អុន, កុល និង ណាវ ឲ្យទៅធ្វើការនៅភ្នំពេញ និងដប់នាក់នៅភូមិផ្សេងទៀត ។ ចាន់ណា បានរៀបរាប់ថា «បើមិនខិតខំជាកុមារឈានមុខមិនដឹងថាអាយុជីវិតធ្លាក់ដល់ណាទេ» ។ ដល់ថ្ងៃចាកចេញ អង្គការបានហៅឈ្មោះម្តងម្នាក់ៗឲ្យឡើងជិះឡាន រួចធ្វើដំណើរទៅសម្រាកនៅទីរួមខេត្តតាកែវ (ផ្ទះតាម៉ុក) មួយយប់ ទើបបន្តដំណើរមកភ្នំពេញ ។ ចាន់ណា នៅចាំបានថា យប់នោះ តាម៉ុក ក៏បានមកណែនាំប្រាប់កុមារៗថា «ចៅៗ ខំប្រឹងធ្វើការ» ។ ស្អែកឡើងក្រោយពីហូបបាយរួច ឡានក៏បានដឹកបន្តមកភ្នំពេញ ហើយបែងចែកកុមារឲ្យធ្វើការនៅអង្គភាពផ្សេងៗពីគ្នា ។

ចាន់ណា ដែលមានអាយុ១៥ឆ្នាំ ត្រូវបែកពីឪពុកម្តាយមកធ្វើការនៅភ្នំពេញតែម្នាក់ឯង មានតួនាទីជាអ្នករៀបចំម្ហូបសម្រាប់មេដឹកនាំខ្មែរក្រហមជាមួយសមាជិកប្រាំនាក់ទៀតមាន អុន, រ៉េម, ប៉ុន, ផា, យន នៅមហោស្រពកន្លែងទទួលភ្ញៀវបរទេស ។ នៅទីនោះ ចាន់ណា ស្គាល់មេដឹកនាំធំៗ ដូចជា ប៉ុល ពត, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ ដោយក្នុងចំណោមនោះ

គាត់នៅជិតស្និទ្ធជាមួយ ខៀវ សំផន ជាងគេ ។ ខៀវ សំផន មានសម្លៀកបំពាក់អាវធំ ដែលជាខោអាវបរទេស ពេលធ្វើដំណើរ គាត់ជិះឡានពណ៌ខ្មៅមានអ្នកការពារពីរនាក់ទៅជាមួយគាត់ ។ ខៀវ សំផន តែងតែមកហូបបាយនៅទីនេះ ក្រោយពីហូបរួច ទើបត្រឡប់ទៅកន្លែងរបស់គាត់វិញ ។ ខៀវ សំផន ចូលចិត្តហូបសម្លម្ជូរ និងហូបតែទឹកក្តៅខណ្ឌៗមិនហូបស្រាទេ ។ ចាន់ណា បន្តថា ខៀវ សំផន មិនដែលរស់នៅមួយកន្លែងទេ ដោយនៅទីនេះបន្តិច ទីនោះបន្តិច ទៅក្រៅប្រទេស ហើយក៏ខស្សហ៍ចេញចូលវាំងញឹកញាប់ដែរ ។ ចំណែកអត្តចរិតវិញគឺមិនសូវនិយាយស្តីអីទេ បើនិយាយ គឺសាច់ការ ។

នៅទីនេះ ចាន់ណា សម្គាល់ឃើញថា ពេល ប៉ុល ពត មកហូបបាយ គឺគាត់តែងតែប្រាប់ ខៀវ សំផនជាមុន ហើយ ខៀវ សំផន ក៏បានប្រាប់មកពួកគាត់បន្តឲ្យរៀបចំម្ហូបបន្ថែម ។ ពេលដែលពួកគាត់ជួបជុំគ្នាហើយគឺគាត់អង្គុយតែគ្នាគាត់ទេនៅតុវិល នៅផ្ទះខាងលិច ។ ចំណែក នួន ជា យូរៗទើបគាត់មកម្តង ។ ក្រោពីនេះមានមេដឹកនាំផ្សេងទៀតដូចជា អៀង សារី និង សុន សេន ក៏មកហូបបាយទីនេះដែរ នៅពេលដែលមានការប្រជុំនៅស្តាតអូឡាំពិក និងមហោស្រព ។

ចាន់ណា ស្គាល់អ្នកទាំងនេះច្បាស់គឺដោយសារតែគាត់ខស្សហ៍ឃើញ ខៀវ សំផន, អៀង សារី និង នួន ជា មកនិយាយលេងជាមួយគាត់ ។ លើសពីនេះទៅទៀត ចាន់ណា ក៏ឃើញមេដឹកនាំទាំងនេះ បើកការប្រជុំជាមួយក្រុមរបស់គាត់ ដោយ ខៀវ សំផន ប្រាប់ថា បើមានភ្ញៀវមក កុំដើរកាត់ គឺលើកតែទឹក និងរៀបចំទំនុកលើតុបានហើយ ។ ក្រោពីប្រជុំជាមួយក្រុមគាត់ ចាន់ណា ក៏ឃើញមានប្រជុំរយៈពេលមួយម៉ោងទៅពីរម៉ោងជាច្រើនលើកផងដែរ ដោយមានអ្នកចូលរួមប្រហែល៧០-៨០ នាក់មកពីភូមិឃុំផ្សេងៗ ។

ចាន់ណា ធ្វើការនៅទីនេះមិនដែលព្រួយបារម្ភអំពីការហូបចុកខ្វះខាតទេ ព្រោះថាអង្ករមាននៅក្នុងឃ្លាំងពេញ នៅពេលអស់អង្ករហូបអាចទៅយកនៅពេលណាក៏បាន ។ ចំណែកត្រី និងសាច់មានមនុស្សដឹកមកដល់កន្លែងជារៀងរាល់ថ្ងៃ ពេលព្រឹក និងល្ងាច និងមានបន្លែម និងផ្លែឈើហូបទៀត ក្រោយពីមេដឹកនាំទាំងនេះហូបមិនអស់ ។ នៅពេលចូលឆ្នាំ ចាន់ណា និងអ្នកផ្សេងទៀតត្រូវបានអនុញ្ញាតឲ្យចេញទៅមើលការសម្តែងសិល្បៈនៅពហុកីឡដ្ឋាន ដោយសិល្បៈនោះមានលេងដូចកុន និងល្ខោនដែរ ។ ប៉ុន្តែទោះបីជាខ្លួនរបស់គាត់បានហូបស្រួលក៏ដោយ ក៏គាត់តែងតែគិតនិងបារម្ភសុខទុក្ខរបស់ឪពុកម្តាយ និងបងប្អូនរបស់គាត់ដែរ ព្រោះចាប់តាំងពីមកនៅភ្នំពេញគាត់មិនត្រូវបានអនុញ្ញាតឲ្យត្រឡប់មកលេងស្រុកកំណើតទេ ។

ក្រោពីការងារទាំងនេះ ចាន់ណា ត្រូវទៅទទួលភ្ញៀវបរទេសនៅព្រលានយន្តហោះ ដែលភាគច្រើនជាភ្ញៀវចិន និងកូរ៉េ ដោយពេលនោះគាត់ត្រូវបានតម្រូវឲ្យស្លៀកសំពត់ហូល ឬជាមួងជាមួយអាវប៉ាក់ដៃខ្លី ។ នៅពេលខ្លះ គាត់ឃើញមានវត្តមានរបស់ ខៀវ សំផន, នួន ជា និង អៀង សារី ទៅទទួលជាមួយដែរ ។ នៅពេលភ្ញៀវមកដល់ គាត់ត្រូវស្រែកថា “ជយោ! ប្រទេសចិន ឬកូរ៉េ” ។ បន្ទាប់មក រថយន្តបានដឹកភ្ញៀវទាំងនេះទៅ កន្លែងស្នាក់នៅផ្សេងទៀតដោយមានអ្នករៀបចំកន្លែង និងអាហារផ្សេង ។

ទោះបីជា ចាន់ណា មិនដែលបានដឹងពីស្ថានភាពខាងក្រៅក៏ដោយ ប៉ុន្តែ ចាន់ណា បានដឹងថា មានការចាប់មនុស្សយកទៅសម្លាប់ដែរ តាមរយៈការលួចខ្សឹបប្រាប់តៗគ្នា ហើយក៏ដឹងថា សោ ភឹម ដែលជាលេខាភូមិភាគបូព៌ាត្រូវបានចាប់ខ្លួនយកទៅសម្លាប់ដែរ ។

ក្រោយពីកងទ័ពវៀតណាមបានចូលរំដោះ ចាន់ណា បានរត់ទៅដល់សំឡូត ។ ដោយសារនៅទីនោះមានភាពចលាចលខ្លាំងពេក ចាន់ណា បានធ្វើដំណើរបកក្រោយវិញ ។ ប៉ុន្តែពេលធ្វើដំណើរមកដល់ស្រុកបាកាន ខេត្តពោធិ៍សាត់ ចាន់ណា ក៏បានជួបកងទ័ពវៀតណាម ។ រយៈពេលដែលសម្រាកនៅស្រុកនេះមួយសប្តាហ៍ កងទ័ពវៀតណាមបានចែកអង្ករ និងរបស់របរផ្សេងឲ្យគាត់ដើម្បីធ្វើដំណើរត្រឡប់មកផ្ទះវិញ ។ ដោយសារតែមិនទុកចិត្តកងទ័ពវៀតណាម ចាន់ណា មិនហ៊ាននិយាយប្រាប់ថា ខ្លួនមានស្រុកកំណើតនៅកំពតទេ ដោយកុហកថានៅបូព៌ា ។ ក្រោយមក ចាន់ណា ត្រឡប់មករស់នៅស្រុកកំណើតវិញ ហើយគាត់បានរៀបការនៅឆ្នាំ១៩៨៣ ។

**គាត លក្ខិណា**

# អតីតគណៈឃុំខ្មែរក្រហមគាំទ្រឱ្យមានការកាត់ទោសមេដឹកនាំ

សៅ វិន ជាមនុស្សម្នាក់ដែលមិនត្រូវបានសម្លាប់ក្រោយពីដឹងថា គាត់ប្រព្រឹត្តខុសសីលធម៌នៅសម័យខ្មែរក្រហម វិន មានតួនាទីជាគណៈឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

កាលពីកុមារ វិន បានចូលរៀននៅសាលាវត្តអង្គរការក្រោយមកទៅរៀនបន្តនៅអនុវិទ្យាល័យខេត្តតាកែវ ។ ដោយសារតែមិនមានលុយគ្រប់គ្រាន់សម្រាប់សិក្សា ពេលរៀនបានត្រឹមថ្នាក់ទី៥ វិន ក៏បានឈប់រៀន ហើយត្រឡប់មកជួយធ្វើស្រែចម្ការឪពុកម្តាយនៅផ្ទះវិញ ។ ក្រោយមក វិន បានដើរធ្វើជាកម្មករនៅភ្នំពេញ ដោយស្នាក់នៅវត្តសំពៅមាស ។ នៅឆ្នាំ១៩៦៨ វិន បានរៀបការជាមួយនារីម្នាក់ឈ្មោះ មាស សុន បន្ទាប់ពីស្គាល់គ្នារយៈពេលបីឆ្នាំ ។ បន្ទាប់ពីរៀបការរួច ឪពុករបស់ វិន បានមកយកអ្នកទាំងពីរត្រឡប់មកស្រុកកំណើតវិញ ដោយប្រកបការងារធ្វើស្រែចម្ការ ។


សៅ វិន

នៅឆ្នាំ១៩៧០ ក្រោយពីមានរដ្ឋប្រហារទម្លាក់សម្តេចសីហនុ វិន បានស្ម័គ្រចិត្តចូលធ្វើបដិវត្តន៍ ដោយមាន មុំ ដែលជាមេឃុំជាផងទផងជាអ្នកនាំចូល ។ ដោយឃើញថា វិន មានចិត្តស្មោះត្រង់នឹងអង្គការបដិវត្តន៍ មុំ បានចាត់តាំង វិន ឲ្យធ្វើជាមេភូមិត្រពាំងទឹក ។ មកដល់ខែមករា ឆ្នាំ១៩៧១ ភូមិឃុំមួយចំនួនក្នុងស្រុកត្រាំកក់ក៏បានក្លាយទៅជាតំបន់ប្រទាញប្រទង់រវាងយោធាខ្មែរក្រហម និងទាហាន លន់ នល់ ។ បន្ទាប់មក វិន ក៏បានជម្លៀសប្រជាជនមួយចំនួនធំដែលនៅជិតផ្សារអង្គតាសោមឲ្យមករស់នៅឃុំពពេលវិញ ។ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំដដែល វិន ត្រូវបានអង្គការស្រុកចាត់តាំងឲ្យធ្វើជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជាប្រចាំឃុំជាផងទង ។ ដោយសារភាពចលាចលកាន់តែខ្លាំងឡើងៗ ព្រមទាំងមានការទម្លាក់គ្រាប់បែក និងការបាញ់ផ្លោងពីខាងទាហាន លន់ នល់ ខ្លាំងចេញពីអង្គតាសោមមក ប្រជាជនមួយចំនួនក៏នាំគ្នារត់ចូលព្រៃ និងមួយចំនួនទៀតដឹកលេណដ្ឋានដើម្បីការពារអាយុជីវិតរៀងៗខ្លួន ។

ក្រោយមក កងទ័ពយៀកកុងសហការជាមួយយោធាខ្មែរក្រហមវាយ ទាហាន លន់ នល់ បណ្តាលឲ្យមានការស្លាប់ និងរបួសជាច្រើននាក់ ។ ខណៈនោះ វិន ក៏បាន ចូលរួមប្រជុំជាមួយលេខាភូមិភាគនិរតីឈ្មោះ តា ម៉ុក ហៅតា ១៥ ដែលគ្រប់គ្រងខេត្តចំនួន៤ រួមមាន ខេត្តតាកែវ, ខេត្តកំពត, ខេត្តកំពង់ស្ពឺ និងកណ្តាល និងអនុលេខាឈ្មោះ ជូ ជេត ហៅ ស៊ី, កង ចាប ហៅ សែ, សោម, មាស មុត និងថ្នាក់ដឹកនាំមួយចំនួនទៀត ។ នៅក្នុងអង្គប្រជុំនោះ តាម៉ុក ជាប្រធាន និងមានការចូលរួមពីយាយ ចែម និង តាទិតផងដែរ ដោយ តាម៉ុក បានលើកឡើងអំពីគោលនយោបាយទាក់ទងនឹងខ្មាំងថា “ថ្នាក់ឃុំ ស្រុក ខេត្ត មិនអាចសម្រេចសម្លាប់នរណាម្នាក់បានទេ បើហ៊ានសម្រេចមានតែដឹករណ្តៅកប់ខ្លួនឯងប៉ុណ្ណោះ” ។ ប៉ុន្តែការអនុវត្តផ្ទុយនឹងអ្វីដែល តាម៉ុក បានលើកឡើង ដោយពេលនោះថ្នាក់តំបន់ ឬ ភូមិភាគជាអ្នកសម្រេចរឿងទាំងនេះដដែល ។

នៅថ្ងៃទី១៧មេសា ឆ្នាំ១៩៧៥ ប្រហែលជាបីម៉ោងក្រោយពីខ្មែរក្រហមបានទទួលជ័យជម្នះ អង្គការបានចាប់បង

ប្រុសរបស់ វ៉ន យកទៅដាក់នៅមន្ទីរ២០៨ (ព្រៃក្ទួច) ស្ថិតនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ដោយចោទថាជារដ្ឋការ លន់ នល់ ។ មួយរយៈក្រោយមក វ៉ន បានទៅជួបកូនស្រីរបស់ តាម៉ុក ឈ្មោះ យាយខុម ដែលជាគណៈស្រុក១០៥ ដើម្បីសុំដោះលែងបងរបស់គាត់ ។ ដោយសារមានការអាណិតដល់ វ៉ន ជាជនបដិវត្តន៍ដែរ ទើបយល់ព្រមដោះលែងបងប្រុសគាត់វិញ ។

នៅខែឧសភា ឆ្នាំ១៩៧៥ អង្គការបានផ្លាស់ វ៉ន ឲ្យធ្វើជាគណៈឃុំកំពង់ស្វាយមើលការខុសត្រូវរួម នៅស្រុកកៀនស្វាយ ខេត្តកណ្តាល ក្រោមការគ្រប់គ្រងរបស់ បូ ជាគណៈស្រុកវិញ ។ នៅទីនោះ វ៉ន បានដឹកនាំប្រជាជនជីកប្រឡាយ លើកទំនប់ ធ្វើស្រែចម្ការបានយ៉ាងល្អ ។ ប៉ុន្តែទោះបីជាខំធ្វើកិច្ចការនោះបានយ៉ាងល្អក៏ដោយ ក៏ប្រជាជនហូបចុកមិនបានគ្រាប់គ្រាន់ដែរ ចំណែកប្រជាជនថ្មីមួយចំនួនត្រូវអង្គការចាប់ខ្លួនទៀតដោយសារជាប់និន្នាការនយោបាយអ្នកដែលធ្លាប់ធ្វើជាទាហានឬជាអ្នករដ្ឋការ លន់ នល់ ។

នៅឆ្នាំ១៩៧៧ អង្គការមានគោលដៅឲ្យប្រធានភូមិនិងគណៈឃុំជម្លៀសប្រជាជនមួយចំនួនចេញពីភូមិកំណើត ជាពិសេសប្រជាជនថ្មីឲ្យមករស់នៅខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ។ នៅឆ្នាំ១៩៧៨ វ៉ន បានដឹកនាំប្រជាជនឲ្យដាំដំណាំក្រូចនៅជិតមន្ទីរពេទ្យនៅឃុំស្វាយធំ ហៅថាមន្ទីរពេទ្យធំ ។ នៅទីនោះគាត់បានឃើញស្ត្រីម្នាក់ដែលជាអ្នកថ្មីទើបសម្រាលកូន ហើយមើលទៅអស់កម្លាំងដងក៏ប្រាប់ទៅនារីពេទ្យម្នាក់ឲ្យបេះក្រូចមកឲ្យគាត់ហូប ។ ដោយសារតែសន្តានចិត្តល្អរបស់ វ៉ន នេះ ត្រូវបានអង្គការចោទប្រកាន់ថា ខុសសីលធម៌ ពីព្រោះតែនារីសម្រាលកូននោះជាប្រពន្ធរបស់ទាហាន លន់ នល់ ។ ចាប់តាំងពីពេលនោះមកអង្គការបានបន្ថយឋានៈរបស់ វ៉ន ហើយផ្លាស់ពីគណៈឃុំកំពង់ស្វាយឲ្យទៅធ្វើជាសមាជិកឃុំបឹងខ្យាងវិញ ។ វ៉ន តែងតែព្រួយបារម្ភពីសុវត្ថិភាពរបស់ខ្លួនជានិច្ច ព្រោះខ្មែរក្រហមចាប់ផ្តើមចាប់គណៈស្រុកកណ្តាលស្ទឹងឈ្មោះ គ្រុយ និងឈ្មោះ យ៉ាន់ ជាបន្តបន្ទាប់ ។ ស្របពេលនោះ របបអាហាររបស់ប្រជាជន និងការរស់នៅមានការខ្វះខាតយ៉ាងខ្លាំង ចំណែកកម្មាភិបាលខ្មែរក្រហមមានបាយហូបគ្រប់គ្រាន់ ថែមទាំងមានមាន់ស្ងោរទៀត ។

រហូតមកដល់ឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមចូលមកដល់ប្រទេសកម្ពុជា វ៉ន បានរត់ត្រឡប់មករស់នៅស្រុកកំណើតវិញ ។ សព្វថ្ងៃ វ៉ន រស់នៅជាមួយប្រពន្ធឈ្មោះ ញឹម អឿន ព្រមទាំងកូនចំនួនដប់នាក់ ។ ក្រៅពីតួនាទីជាក្រុមប្រឹក្សាឃុំជាងទង និងធ្វើអាចារ្យវត្ត វ៉ន ប្រកបមុខរបរធ្វើស្រែចម្ការ ដើម្បីជួយផ្គត់ផ្គង់ជីវភាពគ្រួសារ ។

ទោះបីជា វ៉ន ជាអតីតកម្មាភិបាលខ្មែរក្រហមបម្រើឲ្យរបបនេះក៏ដោយ ប៉ុន្តែគាត់មានអារម្មណ៍រីករាយដែលមេដឹកនាំខ្មែរក្រហមត្រូវបានតុលាការនាំយកមកកាត់ទោស ហើយគាត់ចង់ដឹងថាតើមេដឹកនាំទាំងបួននាក់នោះឆ្លើយរបៀបណាចំពោះរឿងរ៉ាវដែលកើតឡើងនៅអំឡុងពេលដែលគាត់កាន់អំណាច ។

**រី លក្ខិណា**

# ដំណឹងស្វែងរកក្រុមគ្រួសារ

នាងខ្ញុំឈ្មោះ ហាយ សុវណ្ណារី អាយុ៤០ឆ្នាំ រស់នៅភូមិកំពង់ត្រាចទី១ ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត សូមប្រកាសស្វែងរកឪពុកឈ្មោះ រួម មិនចាំត្រកូល (ព្រោះពេលនោះនាងខ្ញុំមានអាយុទើបតែ៦ឆ្នាំប៉ុណ្ណោះ) ជាទាហាន លន់ នល់ និង ម្តាយ (មិនចាំឈ្មោះ) ព្រមទាំងបងប្អូនចំនួន៦នាក់ទៀត គឺទី១) ឈ្មោះ រិទ្ធិ ភេទប្រុស,២) ឈ្មោះ ពៅ ភេទប្រុស,៣) ឈ្មោះ ជា ភេទស្រី ៤) ឈ្មោះ ធី ភេទស្រី ៥) ឈ្មោះ ភារុណ ភេទប្រុស និងប្អូនទី៦) មិនចាំឈ្មោះ (ទៅជាមួយម្តាយ) ។ នាងខ្ញុំបានបែកពីឪពុកម្តាយ និងបងប្អូន នៅពេលខ្មែរក្រហមជម្លៀសគ្រួសារខ្ញុំឲ្យទៅនៅស្រុកឈូក ។ ក្រោយឆ្នាំ១៩៧៩ ឪពុកចិញ្ចឹមរបស់ខ្ញុំឈ្មោះ ហាយ សួន បានយកនាងខ្ញុំទៅរស់នៅជាមួយគាត់នៅស្រុកកំពត និងបានដាក់ឈ្មោះថ្មីឲ្យនាងខ្ញុំថា ហាយ សុវណ្ណារី ។ ចាប់តាំងពីពេលនោះមកខ្ញុំមិនដែលបានឮ ឬទទួលដំណឹងពីគ្រួសារខ្ញុំទេ ។ ប្រសិនបើបងប្អូនណាបានឮឈ្មោះ ឬស្គាល់គ្រួសារនាងខ្ញុំ សូមមេត្តាទាក់ទងអាសយដ្ឋាននាងខ្ញុំដូចខាងលើ និងតាមរយៈទូរស័ព្ទលេខ ០៩២ ២៩៧ ២៧៩ ឬ មជ្ឈមណ្ឌលឯកសារកម្ពុជា អាសយដ្ឋានផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ភ្នំពេញ ឬតាមរយៈទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ។ សូមអរគុណ ។

# ទុយ អោម អតីតអនុលេខាស្រុករៀបរាប់ពីប្រវត្តិ


ទុយ អោម

ទុយ អោម អាយុ៧០ឆ្នាំ មានស្រុកកំណើតនៅស្រុកបាភ្នំ ខេត្តព្រៃវែង ។ នៅក្នុងរបបខ្មែរក្រហម អោម បានកាន់តួនាទីជាច្រើនដូចជា ឈ្លបឃុំ, សេដ្ឋកិច្ចតំបន់ភ្លោះ២៣-២៤ និងក្រោយមកជាអនុលេខាស្រុកមានជ័យថ្មី (ខេត្តស្វាយរៀង) ។ អោម មានបងប្អូនដប់នាក់ ហើយគាត់ជាកូនទីប្រាំ ។ កាលពីក្មេង អោម ចូលរៀននៅសាលាបឋមសិក្សាវត្តប្រកស្វាយ ។ ពេលរៀនដល់ថ្នាក់ទី១០ គាត់ក៏ឈប់រៀន រួចទៅបួសនៅវត្តប្រកស្វាយ ។ គាត់បានចូលសិក្សាបន្តនៅសាលារងរយៈពេលបីវស្សា ប៉ុន្តែដោយសារគាត់ប្រលងធ្លាក់ គាត់ក៏ផ្លាស់មកសិក្សាផ្នែកធម្មវិន័យរយៈពេលបីវស្សាទៀត ទើបគាត់ប្រលងជាប់សញ្ញាបត្រធម្មត្រី ។

ក្រោយមក អោម បានលាចាកសិក្ខាបទ រួចរៀបការប្រពន្ធ ។ អោម បានមកប្រកបមុខរបរធាក់ស៊ីក្លូនៅភ្នំពេញ និងបានចូលធ្វើជាខ្សែបង្កប់របស់ខ្មែរក្រហម ។

នៅឆ្នាំ១៩៧០ អោម ចូលរួមជាមួយយៀកកុងនិងបានហ្វឹកហាត់បច្ចេកទេសបាញ់កាំភ្លើងនៅត្រង់ព្រំប្រទល់ស្រុកក្រាំងលាវ និងស្រុកកំពង់ត្របែកខេត្តព្រៃវែង ដោយពេលនោះ មេបញ្ជាការរបស់យៀកកុងប្រាប់ថា គស៊ូដើម្បីរំដោះយកសម្តេចនរោត្តម សីហនុ មកវិញ ។ បន្ទាប់ពីរៀនបច្ចេកទេសចប់ អោម បានឡើងទៅវាយជាមួយទាហាន លន់ នល់ នៅសមរភូមិកអណ្តើក និងបានកាត់ផ្តាច់ខ្សែភ្លើង និងខ្សែទូរស័ព្ទរបស់ លន់ នល់ មួយចំនួនទៀត ។

នៅឆ្នាំ១៩៧១ ស្រុកបាភ្នំបានរៀបចំរចនាសម្ព័ន្ធ ដឹកនាំភូមិឃុំថ្មី អោម ក៏សុំអនុញ្ញាតពីមេបញ្ជាការវៀតណាមដើម្បីឈប់ធ្វើទ័ព ហើយត្រឡប់មកធ្វើការនៅសមរភូមិក្រោយវិញ ។ ប៉ុន្តែនៅពេល អោម មកដល់ស្រុកវិញ តំណែងមេឃុំនិងមេភូមិត្រូវបានចលនាបដិវត្តន៍រៀបចំរួចរាល់ហើយ ដូច្នេះគាត់ត្រូវបានតែងតាំងឲ្យធ្វើជាប្រធានសន្តិសុខឃុំស្រែកោង ។

អោម កាន់តួនាទីជាប្រធានឈ្លបឃុំរហូតដល់ឆ្នាំ១៩៧៥ ទើបអង្គការផ្លាស់គាត់ទៅគ្រប់គ្រងសេដ្ឋកិច្ចតំបន់២៤ រួមមានស្រុកពាមជរ, កំពង់ត្របែក, ពាមរក៍, មេសាង, បាភ្នំ, កំចាយមា ដែលស្ថិតក្នុងភូមិភាគបូព៌ា ។ ពេលនោះ អោម មានតួនាទីចុះត្រួត


ទុយ អោម

ពិនិត្យមើលការខ្វះខាតនៅតាមរោងបាយ របបអាហារ សម្លៀកបំពាក់ ការរស់នៅរបស់ប្រជាជននៅសហករណ៍ អ្នកជំងឺ និងមន្ទីរពេទ្យសង្គមកិច្ចនៅតាមភូមិដើម្បីសរសេរសំបុត្រស្នើអង្គរនិងថ្នាំពេទ្យយកមកបើកឲ្យ ។

មកដល់ឆ្នាំ១៩៧៧ អង្គការបានបញ្ជូន អោម ឲ្យទៅដោះស្រាយជីវភាពប្រជាជននៅស្រុកមួយចំនួនក្នុងតំបន់២៣វិញ ។ អោម ទទួលភារកិច្ចដើរត្រួតពិនិត្យមើលការរស់នៅរបស់ប្រជាជនតាមសហករណ៍ទូទាំងតំបន់នេះ ។ ដំបូង អោម បានចុះទៅធ្វើការនៅមន្ទីរស្រុកកំពង់រោទ៍ (ទីរួមខេត្តស្វាយរៀង) ហើយនៅទីនោះគាត់ឃើញអ្នកទោសប្រមាណ៤០០នាក់នៅជាប់ឃុំឃាំងនៅមន្ទីរសុខស្រុកនោះ ។ អោម បានហៅអ្នកទោសមកសួរពីទោសកំហុសដែលបានប្រព្រឹត្តនិងបានបញ្ជាឲ្យប្រធានសន្តិសុខដោះលែងអ្នកទោសទាំងអស់នោះ ។ ប៉ុន្តែនៅពេលនោះ អោម ក៏មានភារកិច្ចរៀបចំជម្លៀសប្រជាជនចេញពីតំបន់២៣ដែរ នៅពេលគាត់ទទួលបញ្ជាពីថ្នាក់លើ ។ ក្រោយមក អោម ទទួលតួនាទីជាចំដោយឡែកមួយទៀត គឺធ្វើជាអនុលេខាស្រុកមានជ័យថ្មី (បច្ចុប្បន្ន ស្រុកស្វាយទាប ខេត្តស្វាយរៀង) ។

នៅឆ្នាំ១៩៧៩ អោម និងគ្រួសារបានរត់ភៀសខ្លួនទៅជំរំស្រះកែវប្រទេសថៃ ហើយនៅទីនោះគាត់បានចូលជាមួយចលនាខ្មែរក្រហមម្តងទៀត ។ ក្រោយមក អោម ទទួលតួនាទីជាប្រធានទំនាក់ទំនងក្នុងកងវរសេនាធំ១០៧, ១០៨ និង១០៩ កងពល ៤៥០ (ដោយមាន សុខ ភាព និង សូ ហុង ដឹកនាំ) ហើយគាត់ត្រូវបានបញ្ជូនឲ្យមកប្រចាំការនៅដំបូកក្នុង, សៀ, ល្វា សំពៅលូន ខេត្តបាត់ដំបង ។ អោម បានបន្តតួនាទីរបស់ខ្លួននៅក្នុងជួរកងទ័ពខ្មែរក្រហម រហូតដល់មានសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជាឆ្នាំ១៩៩៦ ទើបគាត់លាឈប់ ។ បច្ចុប្បន្ន អោម និងគ្រួសាររស់នៅក្នុងឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដោយប្រកបរបរដាំពោត សណ្តែក និងដំឡូង ។ **សោម ប៊ុនថន**


ទុយ អោម ចូលរួមសវនាការករណី០០២

# ការប្រមាថនៅលើព្រះពុទ្ធសាសនា

យោងតាមការរៀបរាប់របស់ប្រជាជនដែលរួចរស់ជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ បទសម្ភាសន៍ ឯកសាររាប់ម៉ឺនទំព័រ និងរូបថតដែលសេសសល់ បានបញ្ជាក់យ៉ាងច្បាស់ថា របបខ្មែរក្រហមបានបំផ្លិចបំផ្លាញគម្ពីរក្បួនខ្នាត វាយកម្ទេចវត្តអារាម កុដិ ព្រះវិហារ ផ្សឹកព្រះសង្ឃ សម្លាប់ព្រះសង្ឃ និងបង្ខំព្រះសង្ឃឲ្យយកប្រពន្ធ ដែលជាការប្រព្រឹត្តបំពានយ៉ាងធ្ងន់ធ្ងរទៅលើព្រះពុទ្ធសាសនា ។

ប៉ុន្តែផ្ទុយទៅវិញ នៅក្នុងសវនាការសួរដេញដោលលើភស្តុតាងកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០១១ នួន ជា បែរជាធ្វើការចោទប្រកាន់ចំពោះអ្នកដែលលើកឡើងថា កម្ពុជាប្រជាធិបតេយ្យបានបំផ្លាញព្រះពុទ្ធសាសនាទៅវិញ ដោយអះអាងថា អ្នកទាំងនោះមិនបានយល់ពី “ខ្លឹមសារពិតប្រាកដនៃព្រះពុទ្ធសាសនា” ទេ ។ នួន ជា បានបន្តថា “ខ្លឹមសារពិតប្រាកដនៃព្រះពុទ្ធសាសនាមាន ៖ សីល សមាធិ និង បញ្ញា ដែលកើតឡើងនៅក្នុងចិត្ត ហើយដែលជាប់ជាមួយនឹងការរស់នៅរបស់ប្រជាជន ។ តាមពិត “ខ្លឹមសារពិតប្រាកដនៃព្រះពុទ្ធសាសនា” ទាំងបីរបស់ នួន ជា គឺមានន័យដូចតទៅៈ

សីល ៖ គឺការដែលខ្លួន និងមេដឹកនាំខ្មែរក្រហមប្រព្រឹត្តអំពើល្អ ប្រកាន់ចរិយាល្អ ចាប់តាំងពីគាត់ធ្វើចលនាតស៊ូដំបូង ហើយសម្តែងឡើងដើម្បីទាញយកតែប្រយោជន៍ និងការគាំទ្រពីប្រជាជនក្រីក្រ ហើយដែលជួបការលំបាកប៉ុណ្ណោះ ។

សមាធិ ៖ នួន ជា និង មេដឹកនាំខ្មែរក្រហមខ្លួនឯងបានធ្វើឲ្យចិត្តជ្រះថ្លា និងសម្ងំនៅស្ងៀម ដោយធ្វើជាមិនដឹងមិនឮពីការបង្ខំឲ្យប្រជាជនធ្វើការជាទម្ងន់ ការខ្វះខាតអាហារ ថ្នាំសង្កូវ និងការស្លាប់របស់ប្រជាជនស្លូតត្រង់ទេ ។

បញ្ញា ៖ នួន ជា និងមេដឹកនាំខ្មែរក្រហម បានយកចំណេះដឹងដែលខ្លួនបានសិក្សារៀនសូត្រជ្រៅជ្រះពីបរទេសមកដឹកនាំ និងគ្រប់គ្រងប្រទេសរបស់ខ្លួនដែលបណ្តាលឲ្យប្រជាជនកម្ពុជាប្រមាណជិតពីរលាននាក់ស្លាប់ ។

នៅចំពោះមុខអង្គសវនាការ នួន ជា បានបន្ថែមថា “ការគោរពព្រះពុទ្ធសាសនាមិនចាំបាច់ទៅវត្តអារាមទេ គឺប្រតិបត្តិនៅក្នុងចិត្តបានហើយ ។ ព្រះពុទ្ធទ្រង់ប្រសូត្រ និងត្រាស់ដឹងនៅក្នុងព្រៃដោយមិនចាំបាច់មានកុដិទេ” ។ តាមទស្សនៈរបស់ នួន ជា ការមានវត្តអារាមនេះមិនមែនជា “ខ្លឹមសារពិតប្រាកដនៃព្រះពុទ្ធសាសនា” ពិតប្រាកដទេ ។ លើសពីនេះ នួន ជា បានលើកឡើងថា អ្នកដែលទុកព្រះពុទ្ធសាសនាក្នុងចិត្តពិតប្រាកដ គឺអ្នកនោះចេះខ្មាសបាប ស្អប់បាប និងមិនប្រព្រឹត្តបាប ។ នួន ជា ថែមទាំងអះអាងថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បើទោះបីជាគ្មានការអុជធូបថ្វាយបង្គំព្រះក៏ដោយ ក៏ខ្លឹមសារព្រះពុទ្ធសាសនានៅតែស្ថិតនៅក្នុងចិត្តរបស់ខ្លួន និងប្រជាជនជានិច្ច ។



ព្រះពុទ្ធបដិមាដែលបានវាយបំផ្លាញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ជាការពិតជាក់ស្តែង ក្នុងរបបគ្រប់គ្រងផ្តាច់ការរបស់ខ្លួន នួន ជា និងមេដឹកនាំខ្មែរក្រហមបានបង្គាប់ឲ្យមានការរុះរើ បំផ្លិចបំផ្លាញព្រះពុទ្ធ

បដិមា វត្តអារាម ឬកែប្រែវត្តអារាម ទៅជាកន្លែងចិញ្ចឹមជ្រូកឃុំឃាំងអ្នកទោស កន្លែងសម្លាប់មនុស្ស ឬយកធ្វើឃ្លាំងដាក់សម្ភារជាដើម ។ លើសពីនេះ ខ្មែរក្រហមបានផ្សឹកព្រះសង្ឃ បង្ខំឲ្យព្រះសង្ឃធ្វើការងារធ្ងន់ធ្ងរ និងបានចោទព្រះសង្ឃថាជាឈ្លើងជញ្ជក់ឈាមប្រជាជន ព្រះសង្ឃជាសត្វជ្រូក ដោយដេកចាំស៊ីតែអាហារដែលប្រជាជនយកទៅប្រគេនប៉ុណ្ណោះ ។ មិនត្រឹមតែធ្វើទុក្ខបុកម្នេញលើព្រះពុទ្ធសាសានាប៉ុណ្ណោះទេ នួន ជា និងមេដឹកនាំខ្មែរក្រហម ថែមទាំងបានធ្វើការហាមឃាត់ចំពោះការប្រតិបត្តិសាសនាឥស្លាម និងសាសនាដទៃទៀត ហើយបានជំរុញឲ្យមានការវាយកម្ទេចចោលវិហារឥស្លាម និងព្រះវិហារសាសនាកាតូលិកទៀតផង ។

តើទង្វើទាំងអស់នេះមិនមែនជាអំពើបាបតាមខ្លឹមសារព្រះពុទ្ធទេឬ? ហើយថាតើកាលដែលបង្ខំឲ្យព្រះសង្ឃយកប្រពន្ធផ្សឹកព្រះសង្ឃ សម្លាប់ព្រះសង្ឃ និងហាមឃាត់ជនជាតិភាគតិចដទៃទៀតមិនឲ្យប្រតិបត្តិសាសនារបស់ខ្លួននេះជាការខុសបាបរបស់ នួន ជា និងមេដឹកនាំខ្មែរក្រហមដទៃទៀតឬទេ?

ជាការឆ្លើយតប ព្រះសង្ឃព្រះនាម ឡៃ សុជា គង់នៅវត្តនាគវ័ន្ត មានពុទ្ធដីកាថា ការយកធម៌ព្រះពុទ្ធដាក់ក្នុងចិត្តគឺជាការត្រឹមត្រូវ ប៉ុន្តែមិនទាន់គ្រប់គ្រាន់នៅឡើយទេ បើយោងតាមឱវាទរបស់ព្រះពុទ្ធដែលមានចំនួន៨៤,០០០ព្រះធម្មខណ្ឌ ។ ប៉ុន្តែ ទង្វើនិងចិត្តត្រូវតែដើរស្របតាមខ្លឹមសាររបស់ព្រះពុទ្ធ ។ ព្រះអង្គបានសម្តែងពុទ្ធដីកាតបនឹងការអះអាងរបស់ នួន ជា ថា "ព្រះសង្ឃគឺជាតំណាងឲ្យព្រះពុទ្ធសាសនា" ចំណែក "វត្តអារាមមិនត្រឹមតែកន្លែងសក្ការបូជាប៉ុណ្ណោះទេ ប៉ុន្តែជាកន្លែងសម្រាប់ឲ្យព្រះសង្ឃគង់នៅរៀនសូត្រ និងប្រតិបត្តិធម៌វិន័យ ហើយព្រះសង្ឃដែលជាសាវរបស់ព្រះ មានតួនាទីអប់រំ និងផ្សព្វផ្សាយធម៌ព្រះពុទ្ធសាសនាបន្តទៅដល់ប្រជាជន" ។

ព្រះអង្គបានបញ្ជាក់ថា ការប្រតិបត្តិ និងការធ្វើឲ្យចិត្តជ្រះថ្លា គឺជាការគោរពព្រះពុទ្ធសាសនាដ៏ពិតប្រាកដដែល នួន ជា បានអះអាងជាការត្រឹមត្រូវ ។ ប៉ុន្តែសកម្មភាពជាក់ស្តែងរបស់ នួន ជា និងមេដឹកនាំខ្មែរក្រហមមិនបានប្រតិបត្តិដូច្នេះទេ ហើយបែរជាមកប្រព្រឹត្តអំពើឃោរឃៅទៅលើអ្នកដែលគោរពប្រតិបត្តិសាសនា និងបំផ្លាញព្រះពុទ្ធសាសនាទៅវិញ ។ ការប្រព្រឹត្តដូច្នេះរបស់ នួន ជា និងមេដឹកនាំខ្មែរក្រហម គឺជាការព្រឹត្តអំពើបាបរួចទៅហើយ ។

ការលើកឡើងរបស់ នួន ជា គ្រាន់តែលេសដោះស្រាយពីទោសកំហុស និងទង្វើដែលខ្លួនបានប្រព្រឹត្តក្នុងអំឡុងពេលកាន់កាប់អំណាចរបស់ខ្លួនចាប់ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩តែប៉ុណ្ណោះ ។ សម្តីរបស់ នួន ជា នៅចំពោះមុខអង្គសវនាការសាធារណៈជន និងព្រះសង្ឃ គឺជាការប្រមាថយ៉ាងធ្ងន់ធ្ងរទៅលើព្រះពុទ្ធសាសនាដែលប្រជាជនកម្ពុជាប្រតិបត្តិ និងប្រឹងប្រែងស្តារឡើងវិញក្រោយពីការគ្រប់គ្រងរបស់ខ្មែរក្រហម ។ ប៉ុន្តែចាប់តាំងពីថ្ងៃដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ រហូតមកដល់ថ្ងៃបើកសវនាការកាត់ទោស នួនជា រួមនិង ខៀវ សំផន អៀង សារី និង អៀង ធីរិទ្ធ នៅតែមិនព្រមទទួលស្គាល់នូវការប្រព្រឹត្តរបស់ខ្លួនដែលការបដិសេធនេះ ជាការព្រឹត្តអំពើបាបធ្ងន់ធ្ងរថែមមួយកម្រិតទៀតសម្រាប់មេដឹកនាំខ្មែរក្រហម ។

**សោម ប៊ុនថន និង ឌែន សុខស្រីនិត**



វត្តអារាមដែលបានវាយបំផ្លាញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

# និស្សិតនាយទាហានវិទ្យាស្ថានកងទ័ពជើងគោក រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងច្បាប់សង្គ្រាម

នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២ មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយក្រសួងការពារជាតិបានរៀបចំវគ្គបណ្តុះបណ្តាលដល់និស្សិតនាយទាហាននិងមន្ត្រីយោធានៅវិទ្យាស្ថានកងទ័ពជើងគោកក្នុងខេត្តកំពង់ស្ពឺ ។ វគ្គបណ្តុះបណ្តាលនេះរៀបចំឡើងក្នុងគោលបំណងពង្រីកការយល់ដឹងរបស់និស្សិតនាយទាហានអំពីរបបកម្ពុជាប្រជាធិបតេយ្យដោយការបង្ហាញពីទស្សនៈប្លែកៗអំពីរឿងរ៉ាវដែលកើតឡើង និងមូលហេតុដែលនាំឲ្យរឿងនោះកើតឡើង ព្រមទាំងរឿងរ៉ាវខុសៗគ្នាពីប្រភេទផ្សេងៗនៃអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានកើតមានឡើង ។ ជាងនេះទៅទៀតនាយទាហានទាំងអស់បានសាកល្បងវាយតម្លៃសកម្មភាពផ្សេងៗរបស់មេដឹកនាំខ្មែរក្រហមនិងពិភាក្សាអំពីប្រភេទផ្សេងៗនៃសកម្មភាពឬគោលនយោបាយដែលនាយទាហានអាចប្រើប្រាស់ដើម្បីការពារឧក្រិដ្ឋកម្មសង្គ្រាមនិងអំពើសាហាវឃោរឃៅទ្រង់ទ្រាយធំផ្សេងៗទៀតនៅក្រោមការបញ្ជារបស់ខ្លួន ។ សិក្ខាកាមមានឱកាសរៀនសូត្រនិងឆ្លុះបញ្ចាំងលើករណីប្រទេសផ្សេងៗទៀត ព្រមទាំងស្វែងយល់ពីច្បាប់សង្គ្រាមនិងសន្ធិសញ្ញាទីក្រុងហ្សឺណែវ ។ វិធីសាស្ត្រដែលប្រើប្រាស់នៅក្នុងវគ្គបណ្តុះបណ្តាលនេះមិនត្រឹមតែជួយឲ្យសិក្ខាកាមអាចធ្វើការពិនិត្យនិងពិចារណាទៅលើមនោគមវិជ្ជាខ្មែរក្រហមដើម្បីស្វែងយល់ពីអំឡុងរយៈពេលដ៏គួរឲ្យខ្លាចប៉ុណ្ណោះទេ ថែមទាំងជួយឲ្យនាយទាហានដឹងពីដំណើរការនៃការសម្រេចចិត្ត


និស្សិតនាយទាហាន នៅវិទ្យាស្ថានកងទ័ពជើងគោកក្នុងខេត្តកំពង់ស្ពឺ

ទៀតផង ។

វគ្គបណ្តុះបណ្តាលនេះដើរស្របនឹងវត្ថុបំណងទូទៅរបស់គម្រោងបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរួមមានការសម្របសម្រួល ការយល់ដឹងជាទូទៅ និងការវិភាគទៅលើមនោគមវិជ្ជានិងគោលនយោបាយរបស់ខ្មែរក្រហម ការកត់សម្គាល់លើមូលហេតុឫសគល់នៃអំពើប្រល័យពូជសាសន៍ ពិនិត្យទៅលើភាពដ៏គួរឲ្យភ័យខ្លាចដែលនាំទៅដល់ការកាប់សម្លាប់ការវាយតម្លៃពីផលប៉ះពាល់បច្ចុប្បន្ន ដែលមានមកលើសង្គមកម្ពុជា ក៏ដូចជាលើកទឹកចិត្តឲ្យមានការទទួលស្គាល់រឿងរ៉ាវរបស់ជនរងគ្រោះបង្កើតឲ្យមានសេចក្តីករុណា ការអាណិតអាសូរ និងការ


និស្សិតនាយទាហាននិងមន្ត្រីយោធានៅវិទ្យាស្ថានកងទ័ពជើងគោកក្នុងខេត្តកំពង់ស្ពឺ


និស្សិតនាយទាហានកំពុងអានឯកសារ

ផ្សះផ្សា ។ គោលដៅសំខាន់នៃវគ្គបណ្តុះបណ្តាលនេះគឺដើម្បីលើកទឹកចិត្តឲ្យផ្នែកផ្សេងៗនៅក្នុងសង្គម រួមទាំងផ្នែកកងទ័ពប្រឈមមុខនឹងអតីតកាលក្នុងគោលបំណងឲ្យពិភពលោកបានដឹងពីទស្សនៈរបស់ខ្លួន ។

ពិធីបើកវគ្គបណ្តុះបណ្តាលបានចាប់ផ្តើមឡើងដោយមានវត្តមានរបស់ឯកឧត្តមឧត្តមសេនីយឯក ស្តើង សេន នាយករងវិទ្យាស្ថានកងទ័ពជើងគោករួមទាំងគណៈប្រតិភូរបស់ក្រសួងការពារជាតិមួយចំនួនទៀត ។ ឯកឧត្តមឧត្តមសេនីយ៍ ស្តើង សេន បានផ្តើមសន្ទរកថាដោយរៀបរាប់ពីប្រវត្តិសង្ខេបរបស់វិទ្យាស្ថានទៅកាន់សិក្ខាកាមដែលមានចំនួន២០០នាក់ ។ សំណង់នានានៅក្នុងវិទ្យាស្ថានបានទទួលការឧបត្ថម្ភដ៏សប្បុរសធម៌ពីប្រទេសចិន ។

ឯកឧត្តមឧត្តមសេនីយ៍ឯកបានបញ្ជាក់បន្ថែមថា វិទ្យាស្ថានកងទ័ពជើងគោកនេះធ្លាប់ជាមជ្ឈមណ្ឌលអប់រំដល់កងទាហានគ្រប់ប្រភេទដូចជា ប៉ូលីស និងទាហានជាតិ ។ ដោយមានការកើនឡើងនូវចំណាប់អារម្មណ៍ពីសំណាក់សិស្សានុសិស្ស អ្នកចូលរួម ឯកឧត្តមឧត្តមសេនីយ៍ឯកបានបញ្ជាក់បន្ថែមទៀតថា អគារមួយចំនួនទៀតនឹងត្រូវពិចារណាទុកធ្វើជាអគារ សាលារៀនសម្រាប់និស្សិត ។ ដើម្បីឲ្យនិស្សិតនាយទាហានយកចិត្តទុកដាក់ទៅលើវគ្គបណ្តុះបណ្តាលនេះ ឯកឧត្តមឧត្តមសេនីយ៍ឯក ស្តើង សេន បានបញ្ជាក់ដោយសំឡេងច្បាស់ៗនិងម៉ឺងម៉ាត់ថា និស្សិតទាំងអស់នឹងត្រូវឆ្លងកាត់ការប្រឡងទៅលើមេរៀនដែលបានរៀនពីវាគ្មិនជាតិ និងអន្តរជាតិនេះ ។ វគ្គបណ្តុះបណ្តាលនេះនឹងបន្ថែមទៅលើបទពិសោធន៍ផ្ទាល់ ដែលនិស្សិតបានទៅទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនិងវាលពិឃាតជើងឯក និងការធ្វើទស្សនកិច្ចនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ឯកឧត្តមឧត្តមសេនីយ៍ឯកបានសំណូមពរឲ្យសិក្ខាកាមទាំងអស់យកចិត្តទុកដាក់ទៅលើវគ្គបណ្តុះបណ្តាលនេះពីព្រោះវគ្គសិក្សានេះនឹងផ្តល់ប្រយោជន៍ដល់ចំណេះដឹងផ្នែកប្រវត្តិសាស្ត្រ និងការប្រលង ។

**សកម្មភាព**

លោក ឌី ខាំបូលី អ្នកនិពន្ធសៀវភៅប្រវត្តិសាស្ត្រកម្ពុជា

ប្រជាធិបតេយ្យបានលើកឡើងនូវសំណួរចំនួនពីរអំពីមនោគមវិជ្ជា និងគោលនយោបាយរបស់ខ្មែរក្រហមក្នុងគោលបំណងទាញការចាប់អារម្មណ៍របស់សិក្ខាកាម ។ គាត់ចាប់ផ្តើមដោយពន្យល់ថា ខ្មែរក្រហមគឺចេញមកពីកុម្មុយនីស្តរបស់ម៉ាក្ស-លេនីន ក៏ប៉ុន្តែខ្មែរក្រហមបានប្រើប្រាស់លទ្ធិម៉ៅជ្រុលនិយមហួសហេតុ និងដឹកនាំដោយអ្នកដឹកនាំក្មេងខ្ចីគ្មានបទពិសោធន៍ និងចង់ឲ្យប្រទេសក្លាយជាទីរុងរឿងផុតគេ ។ របបនេះអនុវត្តគោលនយោបាយដែលមានភាពស្រមើស្រមៃហួសហេតុ និងមិនអាចប្រើការបាន ។ ខ្មែរក្រហមចង់កសាងសង្គមកុម្មុយនីស្តជឿនលឿនជាងប្រទេសកុម្មុយនីស្ត និងសង្គមនិយមដទៃទៀតនៅក្នុងពិភពលោក ។ ដើម្បីសម្រេចជ័យជម្នះទៅលើរបប លន់ នល់ មេដឹកនាំខ្មែរក្រហមបានប្រកាសថាខ្មែរក្រហមនឹងធ្វើការសម្លាប់ទៅលើជនក្បត់ប្រាំពីរនាក់ រួមមាន លន់ នល់, អ៊ិន តាំ, ចេង ហេង និង ឡុង បូរ៉េត ជាដើម ។ ទោះជាយ៉ាងនេះក្តី ខ្មែរក្រហមមិនបានគោរពធ្វើតាមសន្យាទេ ។ ខ្មែរក្រហមបានអនុវត្តនូវគម្រោងជម្លៀសដើម្បីបំបែកកម្លាំងសត្រូវ ។ កងកម្លាំងទាហាន និងអ្នកធ្វើការរាជការក្នុងរបប លន់ នល់ ជាច្រើនត្រូវបានសម្លាប់ ព្រោះខ្មែរក្រហមគិតថាអ្នកទាំងអស់នោះមិនមានភាពស្មោះត្រង់ ។ នៅក្នុងអំឡុងពេលគ្រប់គ្រងចំនួនបួនឆ្នាំ ខ្មែរក្រហមបានធ្វើការបោសសម្អាតទាហាននិងអ្នកដែលធ្លាប់ធ្វើការឲ្យរបប លន់ នល់ ។ ខ្មែរក្រហមមិនទុកនរណាម្នាក់ឡើយ ខ្មែរក្រហមបំបាត់





សាស្ត្រាចារ្យ ភីតធឺ ម៉ាហ្គ័រ

គោលដៅនេះ ខ្មែរក្រហមបានរៀបចំឲ្យមានសង្គមដែលគ្មានវណ្ណៈ គ្មានអ្នកមាន គ្មានអ្នកក្រ ដោយលុបបំបាត់ចោលនូវមូលធននិយម និងសក្តិភូមិនិយម ។ បូលី បានសង្កត់ធ្ងន់ទៅលើតម្រូវការចាំបាច់ក្នុងការពិនិត្យមើលទៅលើមូលហេតុថាតើគោលនយោបាយ និងមនោគមវិជ្ជារបស់ខ្មែរក្រហមខ្វះខាតនូវភាពជាក់ស្តែងដែលជាមូលហេតុនាំទៅដល់ការដួលរលំ ។

បូលី បានលើកពីអំណះអំណាងមួយចំនួន ដែលផ្តោតលើសាច់រឿងប្រវត្តិសាស្ត្របួន ៖ ការបោសសម្អាតនិងបន្សុទ្ធខ្សាំងផ្ទៃក្នុង ការរើបម្រះវណ្ណៈ ឯករាជ្យនិងការពឹងពាក់លើខ្លួនឯង និងការដាក់ជាសហករណ៍ ។ ដំបូង បូលី និយាយថា មុនពេលទទួលបានសក្តិភូមិនិយមនិងមូលធននិយមដោយការចុះយុទ្ធនាការចាប់ខ្លួន និងសម្លាប់ ។ ផ្ទុយទៅនឹងគោលការណ៍របស់របបមុនទាក់ទងនឹងការជឿជាក់និងជំនឿទុកចិត្តលើពួកក្រុមជនជាតិភាគតិចតំបន់ភ្នំ និងវៀតណាម រួមទាំងអ្នកដែលមានទំនាក់ទំនងជាមួយវៀតណាម ឬអ្នកដែលត្រូវបានកត់សម្គាល់ថាជាជនជាតិចាម ឬខ្មែរកាត់ចិន គឺសុទ្ធតែជាក្រុមដែលងាយនឹងរងគ្រោះពីការកាប់សម្លាប់ ។ បូលី បានផ្តល់ជាសម្មតិកម្មថា ការសម្លាប់របស់ខ្មែរក្រហមមានលក្ខណៈជាប្រព័ន្ធ ។ ចង្វាក់នៃការសម្លាប់ដ៏គួរឲ្យកត់សម្គាល់មួយគឺជាភារកិច្ចរបស់កម្មាភិបាលថ្នាក់ក្រោម ។ អ្នកដែលត្រូវបានចាប់ខ្លួននិងសម្លាប់ រួមមាន សោ ភឹម, ញឹម រស់, ជូ ជេត, ចេង អន, វ៉ន វ៉េត, កង ចាប,

ភ្នង និង ខែក ប៉ែន ។ អ្នកទាំងអស់នោះត្រូវបានចោទប្រកាន់ពីបទក្បត់នឹង ប៉ុល ពត និងចូលដៃជើងជាមួយវៀតណាម ។ គោលដៅជាយុទ្ធសាស្ត្ររបស់របបខ្មែរក្រហមគឺការបំបាត់វណ្ណៈ ។ របបនេះបានឲ្យអំណះអំណាងថា កសិករ និងកម្មករ បានទទួលការគាបសង្កត់ ដោយមូលហេតុនេះខ្មែរក្រហមបានធ្វើការជំរុញកសិករ និងកម្មករឲ្យងើបឡើងប្រឆាំងនឹងរបបចាស់ ។ តាមការពិត កសិករក្រីក្រ និងខ្វះខាតខ្សោយ ងាយស្រួលក្នុងការបញ្ចុះបញ្ចូលឲ្យចូលរួម ។

ទាក់ទងទៅនឹងគោលនយោបាយពឹងពាក់លើខ្លួនឯង ខ្មែរក្រហមជឿជាក់ថាប្រទេសកម្ពុជាមិនដែលបានទទួលនូវឯករាជ្យពិតប្រាកដនោះទេ ។ ប្រទេសកម្ពុជាត្រូវបានដាក់អាណានិគម ដោយពួកចក្រពត្តិ ពួកមូលធននិយម សក្តិភូមិ និងការគាបសង្កត់សង្កិន ។ ប្រជាជនដែលមានកម្លាំងកាយ ប៉ុន្តែមិនមានគ្មានតួនាទីអ្វីទាំងអស់ ។ ខ្មែរក្រហមចង់រៀបចំឋានៈប្រជាជននៅក្នុងសង្គមសាជាថ្មី ។

ដើម្បីសម្រេចគោលដៅនេះ របបខ្មែរក្រហមបានដាក់ចុះនូវគោលនយោបាយមួយចំនួនដូចជា ការដាក់ជាសហករណ៍រួម ដែលក្នុងនោះមានការបង្កើតឲ្យមានផែនការបួនឆ្នាំដែលមានគោលបំណងក្នុងការកសាងសង្គមនិយមមួយនៅគ្រប់ផ្នែកទាំងអស់ ។ គោលដៅសំខាន់គឺធ្វើឲ្យលើសប្រទេសចិនទៅទៀតដោយលុបបំបាត់ចោលឲ្យអស់នូវទ្រព្យសម្បត្តិឯកជន ។ បូលី បានបញ្ចប់ការបង្ហាញដោយបញ្ជាក់ថាមនុស្សជិតពីរលាននាក់បានស្លាប់ជាលទ្ធផលចេញពីគោលនយោបាយនិងមនោគមវិជ្ជាជ្រុលនិយមនេះ ។ បូលី បានលើកទឹកចិត្តឲ្យអ្នកចូលរួមទាំងអស់ធ្វើការស្រាវជ្រាវបន្ថែមដើម្បីស្វែងរកអំណះអំណាងផ្សេងៗទៀតទាក់ទងទៅនឹងរបបខ្មែរក្រហម ។ បន្ទាប់ពីការបង្ហាញ សិក្ខាកាមបានចោទជាសំណួរមួយចំនួន ដូចជាការធ្វើអន្តរាគមន៍របស់វៀតណាមនៅឆ្នាំ១៩៧៩ ការអត់អាហារ និងការគោរពសាសនានៅក្នុងរបបខ្មែរក្រហម ។

បន្ទាប់មក លោក គ្រីស្តូហ្វ័រ ឌៀរីង បានផ្តោតការបង្ហាញរបស់លោកទៅលើការវិភាគបែបប្រៀបធៀបទៅលើឧក្រិដ្ឋកម្មសង្គ្រាម និងអំពើសាហាវព្រៃផ្សៃក្នុងទ្រង់ទ្រាយធំ ។ លោក ឌៀរីង បានចាប់ផ្តើមដោយសួរសំណួរទៅកាន់សិក្ខាកាមទាំងអស់ថាតើសិក្ខាកាមយល់ថាអ្វីជាជំនាញសំខាន់បំផុតដែលនាយទាហានគួរតែចេះ ។ សិក្ខាកាមនារីម្នាក់ បានឆ្លើយថា នយោបាយ និងច្បាប់សង្គ្រាមគឺជាជំនាញសំខាន់បំផុត រីឯសិក្ខាកាមម្នាក់ទៀតបានឆ្លើយថា ជំនាញទាំងអស់សុទ្ធតែសំខាន់ស្មើៗគ្នា ។

ចំណែកលោកសាស្ត្រាចារ្យ ភីតធី ម៉ាហ៊្គ័រ ជាសាស្ត្រាចារ្យបង្រៀនច្បាប់ និងប្រវត្តិសង្គ្រាម នៅសកលវិទ្យាល័យកូឡុំប៊ី សហរដ្ឋអាមេរិក បានធ្វើការណែនាំខ្លួនដោយពន្យល់បកស្រាយមូលហេតុដែលជីតារបស់លោកបានធ្វើជាចៅក្រមម្នាក់នៅតុលាការណ៍រឹមប៊ឺក បន្ទាប់មកទៀត លោកបានបន្តសង្កត់ធ្ងន់ថាសង្គ្រាមមានផ្ទុកនូវអំពើឧក្រិដ្ឋដូចជា ការបំផ្លិចបំផ្លាញមូលដ្ឋានស៊ីវិល និងការសម្លាប់ប្រជាជន ។ល ។ ដើម្បីស្វែងយល់ពីលក្ខណៈនិងប្ញសគល់នៃច្បាប់សង្គ្រាម លោក បណ្ឌិត ម៉ាហ៊្គ័រ បានលើកឡើងពីខ្លឹមសារនៃទ្រឹស្តី "ច្បាប់សង្គ្រាម" ពីបុរាណកាលមក ។ ដំបូងលោកបានរៀបរាប់ពីប្ញសគល់នៃច្បាប់សង្គ្រាមទំនើបដែលមានជាប់ពាក់ព័ន្ធនឹងវប្បធម៌នៃសាសនាគ្រិស្ត ។ ការអធិប្បាយនេះអាចចាត់ទុកជាការផ្ទុយគ្នានឹងខ្លឹមសារស្តីពីសន្តិភាពដែលជាមូលដ្ឋាននៃសាររបស់ព្រះយេស៊ូគ្រិស្ត ។ ទាក់ទងនឹងចំណុចនេះលោកបានបកស្រាយមូលហេតុដែលសាសនាបានវិវឌ្ឍន៍ចេញទស្សនៈសន្តិភាពទៅជាវប្បធម៌ដែលទទួលស្គាល់សង្គ្រាម ។ ដើម្បីទទួលស្គាល់សង្គ្រាម គ្រិស្តសាសនិកត្រូវតែបង្កើតទ្រឹស្តីសង្គ្រាមដែលផ្អែកលើ "បុព្វហេតុយុត្តិធម៌" ។ នាពេលបច្ចុប្បន្ននេះ ទស្សនៈនៃបុព្វហេតុយុត្តិធម៌ត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងសង្គ្រាមអ៊ីរ៉ាក់កាលពីសាមសិបឆ្នាំមុន ។

ច្បាប់សង្គ្រាមបានចែងថាអ្នកឈ្នះអាចសម្លាប់អ្នកចាញ់ ។ ក្រោយពេលដែលសង្គ្រាមបានបញ្ចប់ផុតទៅក៏មានកិច្ចខិតខំប្រឹងប្រែងសំខាន់មួយដើម្បីកំណត់ក្បួនច្បាប់ដែលគ្រប់គ្រងនិងបំផុសបំផុលជម្លោះតាមវិធីសាស្ត្រមួយដែលនឹងមិនត្រឹមតែទប់ស្កាត់សង្គ្រាមទេ ប៉ុន្តែថែមទាំងកំណត់ស្ថានភាពណាដែលសង្គ្រាមអាចត្រូវបានចាត់ទុកថាស្របច្បាប់បានឬមិនបាន ។ សំខាន់ជាងនេះក្បួនច្បាប់នេះបានផ្តល់ជាមូលដ្ឋានសម្រាប់គោលការណ៍ជាច្រើនដែលអាចធ្វើការបែងចែករវាងទាហានយោធានិងប្រជាជនស៊ីវិល ។ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីតាក់តែងច្បាប់សង្គ្រាមក៏មានច្បាប់មួយដែលនៅមានមកដល់សព្វថ្ងៃនេះដែលទាហានយោធាត្រូវបាន

ផ្ដន្ទាទោសសម្រាប់ឧក្រិដ្ឋកម្មរបស់ខ្លួន ប៉ុន្តែចំណែកឯមេដឹកនាំយោធាវិញកម្រនឹងត្រូវបានផ្ដន្ទាទោសណាស់ ។

មុនឆ្នាំ១៩៨៦ច្បាប់សង្គ្រាមត្រូវបានកំណត់យ៉ាងច្បាស់ ។ សំណួរសាមញ្ញមួយអាចនឹងសួរថាហេតុអ្វីមន្ត្រីយោធាគួរតែគោរពច្បាប់សង្គ្រាម? សហរដ្ឋអាមេរិកបានអនុម័តច្បាប់សង្គ្រាមក្នុងឆ្នាំ១៨៦២តាមដីកាលេខ១០០ ។ បទបញ្ជារបស់ប្រធានាធិបតីសហរដ្ឋអាមេរិក អាប្រាហាម លីនខុន ដាក់ជូនកងពលខាងជើងរបស់សហរដ្ឋអាមេរិកក្នុងអំឡុងសង្គ្រាមស៊ីវិលរបស់ (អាមេរិក) បានបង្កើតច្បាប់បឋមដែលអាចជំរុញឲ្យមានការបង្កើតអនុសញ្ញាទីក្រុងហ្សឺណែវនិងតុលាការឧក្រិដ្ឋកម្មសង្គ្រាមដូចជាតុលាការណូរិមបឺកនិងតុលាការផ្សេងៗទៀត ។ ដីកានេះបានចាត់បញ្ចូលសកម្មភាពជាច្រើននៃសង្គ្រាមនិងរួមទាំងសកម្មភាពសង្គ្រាមឈ្លបដងដែរ ។ ច្បាប់សង្គ្រាមមានសេចក្ដីព្រាងច្បាប់ជាច្រើនដែលនៅតែបន្តពិភាក្សារហូតមកដល់សព្វថ្ងៃនេះ ។

លោកសាស្ត្រាចារ្យ រស់ ចន្ទ្រាបុត្រ បានផ្ដោតបទបង្ហាញរបស់លោកលើស្ថានភាពប្រវត្តិសាស្ត្របី ដូចជា ការអភិវឌ្ឍជុំវិញពិភពលោក ការអភិវឌ្ឍផ្នែកនយោបាយនៅអាស៊ីអាគ្នេយ៍និងចលនាវិកវរនៅកម្ពុជា ។ លោកសាស្ត្រាចារ្យបានជឿជាក់ថាសង្គ្រាមក្នុងប្រទេសកម្ពុជាកើតមានឡើងដោយសារតែឥទ្ធិពលនៃសង្គ្រាមលោក ។ ដោយសារតែសង្គ្រាមមិនទាន់បានបញ្ចប់ ក្រុមសម្ព័ន្ធមិត្តបានសម្រេចបែងចែកពិភពលោកជាពីរប្លុក (គឺប្លុកកុម្មុយនីស្តនិងប្លុកសេរី) នៅខែកុម្ភៈ ឆ្នាំ១៩៤៥ ។ ជាលទ្ធផលសង្គ្រាមត្រជាក់ក៏បានកើតមានឡើង ។

លោកសាស្ត្រាចារ្យក៏បានបន្តពន្យល់បកស្រាយបន្ថែមទៀតពីកត្តាដែលសង្គ្រាមនេះត្រូវបានគេឲ្យឈ្មោះថាសង្គ្រាមត្រជាក់ ។ មូលហេតុគឺដោយសារតែពួកប្រទេសមហាអំណាចគឺ (សហរដ្ឋអាមេរិកនិងសហភាពសូវៀត) មិនចូលរួមក្នុងសង្គ្រាមនេះដោយផ្ទាល់ ប៉ុន្តែបានបំផុសបំផុលឲ្យមានសង្គ្រាមតាមរយៈប្រទេសតូចតាច ។ យើងអាចយកសង្គ្រាមកូរ៉េមកធ្វើជាឧទាហរណ៍បាន ។ មានមនុស្សជាច្រើនបានព្រួយបារម្ភថាសង្គ្រាមលោកលើកទីបីអាចនឹងកើតមានឡើងនាអំឡុងពេលនេះ ។ សូម្បីតែសព្វថ្ងៃនេះឧបទ្វីបកូរ៉េគឺនៅតែបន្តសង្គ្រាមដាក់គ្នានៅឡើយ ។ ចំណុចមួយទៀតដែលថាប្រវត្តិសាស្ត្រមានសារសំខាន់នោះគឺស្ថានភាពជុំវិញវិបត្តិអាវុធមីស៊ីលរបស់ប្រទេសគុយបា ។ ជាក់ស្ដែង សហភាពសូវៀតបានដាក់អាវុធមីស៊ីលរបស់ខ្លួននៅក្នុងប្រទេសគុយបា ចំណែកសហរដ្ឋអាមេរិកវិញក៏បានដាក់អាវុធមីស៊ីល នៅប្រទេសទួគី និងប្រទេសប៉ូឡូញ ។ តាមពិត ប្លុកទាំងពីរនេះគឺកំពុងតែធ្វើសង្គ្រាមដាក់គ្នា ប៉ុន្តែនាចុងក្រោយបង្អស់ប្រទេសទាំងពីរនេះក៏បានសម្រេចដកអាវុធមីស៊ីលរបស់ខ្លួនចេញ ។ ក្រោយដកឲ្យចេញពីសង្គ្រាមរបស់ប្រទេសមហាអំណាចទាំងពីរនេះ ប្រទេសតូចតាចនៅតែបន្តជម្លោះក្នុងប្រទេសរបស់ខ្លួនរៀងៗខ្លួន ។

នៅក្នុងអំឡុងសង្គ្រាមត្រជាក់ ប្រទេសកម្ពុជាមិនទាន់បានទទួលឯករាជ្យភាពនៅឡើយទេ ។ ប្រទេសសៀមដែលនាពេលបច្ចុប្បន្ននេះជាប្រទេសថៃបានបង្កើតចលនាឥស្សរៈ ប៉ុន្តែមិនមែនបម្រើឲ្យសេរីភាព និងឯករាជ្យភាពរបស់កម្ពុជាឡើយ ។ សៀមមានបំណងចង់កាន់កាប់និងគ្រប់គ្រងខេត្តបាត់ដំបង ស្ទឹងត្រែង កំពង់ធំ និងខេត្តសៀមរាបរបស់ប្រទេសកម្ពុជា ។ បន្ទាប់ពីប្រទេសបារាំងបានបាត់បង់ការកាន់កាប់លើខេត្តទាំងប៉ុន្មាននេះសៀមបានសហការជាមួយប្រទេសជប៉ុនដើម្បីទាមទារការគ្រប់គ្រងលើខេត្តទាំងបួននេះ ។

នៅឆ្នាំ១៩៧០កម្ពុជាបានធ្លាក់ក្នុងស្ថានភាពវិកវរមួយ ។ សេនាប្រមុខ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្ដេចនរោត្តម សីហនុ ។ ដំបូងឡើយអ្នកគាំទ្ររបប លន់ នល់ ខ្លះបានជឿថាសាធារណរដ្ឋខ្មែរដែលកាន់កាប់អំណាចនេះនឹងអាចដោះស្រាយបញ្ហាសង្គមជាច្រើនដូចជាបញ្ហាអំពើពុករលួយ ។ យ៉ាងណាមិញការរំពឹងទុកនេះមិនកើតឡើងដូចដែលការគិតទុកឡើយពីព្រោះមានបញ្ហាជាច្រើនបានបន្តកើតមានឡើងឥតឈប់ឈរ ។ នាចុងបញ្ចប់ ប្រជាជនកម្ពុជាជាពិសេសគឺប្រជាជនតាមតំបន់ជនបទបានងាកមកគាំទ្រចលនារបស់ខ្មែរក្រហមដោយក្ដីសង្ឃឹមថាជ័យជម្នះរបស់ខ្មែរក្រហមនឹងយាងសម្ដេច សីហនុ មកកាន់កាប់អំណាចគ្រប់គ្រងប្រទេសវិញ ។ ក្នុងទស្សនៈវិស័យរបស់ប្រជាជនទាំងនេះគឺមានតែសម្ដេចសីហនុតែប៉ុណ្ណោះ ដែលអាចដោះស្រាយបញ្ហាសង្គមទាំងនេះបាន ។

**លី សុខឃាង**

# អ្នកចូលរួមសវនាការលើភស្តុតាងនៃសំណុំរឿង០០២ នៅអង្គ











# ជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងខែមករា ឆ្នាំ២០១២









# ឃ្លាំមើលសាលាក្តីខ្មែរក្រហម

គេហទំព័រឃ្លាំមើលការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org គឺជាប្រភពឈានមុខគេនៃសារព័ត៌មាន ដំណឹងវិវឌ្ឍន៍ថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទាក់ទងនិងដំណើរការរបស់សាលាក្តីខ្មែរក្រហម ។ គេហទំព័រនេះគឺសម្រាប់សាធារណជនទាំងអស់ក្នុងការស្វែងយល់អំពីដំណើរការរបស់សាលាក្តីនេះ ។

សំណុំរឿង០០២ ដែលទាក់ទិននឹងជនជាប់ចោទបីនាក់គឺ ខៀវ សំផន, នួន ជា និង អៀង សារី នឹងចាប់ផ្តើមបើកសវនាការចាប់ពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ នេះតទៅ ។ គេហទំព័រនេះធ្វើការចាក់ផ្សាយសវនាការកាត់ទោសទាំងស្រុងជាភាសាខ្មែរ អង់គ្លេស និងបារាំង ។ នៅក្នុងគេហទំព័រនេះមានការចែកចេញជាច្រើនផ្នែកគឺរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ វីដេអូសវនាការទាំងមូល និងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងនិងសវនាការ សារព័ត៌មានផ្សេងៗជុំវិញតុលាការ របាយការណ៍របស់សាលាក្តីខ្មែរក្រហមនិងអង្គការក្រៅរដ្ឋាភិបាលនានាដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ ប្រវត្តិសាស្ត្រ ប្រវត្តិរបស់តុលាការនេះនិងបទអត្ថាធិប្បាយរបស់អ្នកជំនាញ ។

គេហទំព័រនេះក៏នឹងជួយផ្តល់លក្ខណៈងាយស្រួលសម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិនិងអន្តរជាតិ ។ អ្នកឃ្លាំមើលសវនាការម្នាក់ដែលមានជំនាញផ្នែកច្បាប់មកពីសហរដ្ឋអាមេរិកនឹងមកអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះ និងសរសេររបាយការណ៍យ៉ាងលម្អិតមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍នេះក៏នឹងបកប្រែជាភាសាខ្មែរដែរ ។

គេហទំព័រឃ្លាំមើលការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះត្រូវបានត្រួតពិនិត្យដោយលោកសាស្ត្រាចារ្យច្បាប់ ដេវីដ ស៊ើហ្វើ អតីតឯកអគ្គរដ្ឋទូតគោចរសហរដ្ឋអាមេរិកទទួលបន្ទុកកិច្ចការឧក្រិដ្ឋកម្មសង្គ្រាមក្នុងរដ្ឋការរបស់ប្រធានាធិបតីប៊ីល គ្លីនតុន និងបច្ចុប្បន្នជាអ្នកតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**



# សាច់រឿងពាក់កណ្ដាល ឬកប់ភ័ស្តុតាងចោល? ការទទួលស្គាល់ភ័ស្តុតាងបណ្ដោះអាសន្នបន្ថែម

សាស្ត្រាចារ្យ ដេវីដ ឆេនដល័រ បាននិយាយថា “ការឡើងគ្រប់គ្រងអំណាចរបស់ខ្មែរក្រហមកើតឡើងដោយព្រឹត្តិការណ៍ខាងក្រៅដែលចាប់ផ្ដើមកើតឡើងតាំងពីខែមីនា ឆ្នាំ១៩៨៥ និងដោយសង្គ្រាមត្រជាក់ជាដាងព្រឹត្តិការណ៍ផ្សេងៗទៀត” ។ ដំណើរការកាត់ក្ដីរបស់តុលាការ ណូរីមប៊ឺក បានបង្កើតគោលការណ៍ដែលថា ជនម្នាក់អាចនឹងត្រូវបានកាត់ទោសឲ្យទទួលខុសត្រូវតាមច្បាប់អន្តរជាតិចំពោះការរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ។ នេះគឺជាគោលការណ៍មួយដែលអនុញ្ញាតឲ្យតុលាការផ្សេងៗ ក៏ដូចជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានាំជនដែលមកកាត់ទោស ។ ស្របពេលដែលការយល់ដឹងពីបរិបទប្រវត្តិសាស្ត្រមានសារសំខាន់ក្នុងការយល់ដឹងពីអំពើសាហាវឃោរឃៅដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមវាក៏មានសារសំខាន់ក្នុងការអនុញ្ញាតឲ្យមានការធ្វើឲ្យទទួលខុសត្រូវរបស់បុគ្គលនិងមិនអនុញ្ញាតឲ្យបរិបទប្រវត្តិសាស្ត្ររារាំងដល់សមត្ថភាពរបស់តុលាការក្នុងដំណើរការកាត់ក្ដីឲ្យបានត្រឹមត្រូវនិងយុត្តិធម៌និងក្នុងការពង្រឹងការដាក់ទណ្ឌកម្មបានឡើយ ។ នេះគឺជាប្រយោជន៍ដល់វិស័យយុត្តិធម៌ក្នុងការប្រឈមមុខនឹងតុល្យភាពមួយរវាងគំនាបនៃបញ្ហាពីរនេះ ។

### យុត្តាធិការ

ដោយសារតែតុលាការមានហិរញ្ញវត្ថុនិងធនធានមនុស្សដ៏មានកម្រិត វាពិតជាមានសារសំខាន់សម្រាប់អ្នកតាក់តែងច្បាប់ក្នុងការដាក់កម្រិតថាតើជនណាគួរតែនាំមកកាត់ទោស ។ មានមធ្យោបាយមួយចំនួនដែលនឹងដាក់កម្រិតលើយុត្តាធិការបុស្សិទ្ធិ




ស្ត្រីម្នាក់កំពុងមើលរូបថត និងព័ត៌មានទាក់ទងនឹងមេដឹកនាំខ្មែរក្រហម

អំណាចរបស់តុលាការ ។ តុលាការអាចដាក់កម្រិតលើជនទាំងឡាយណាដែលអាចមកបង្ហាញខ្លួននៅចំពោះមុខចៅក្រម ហើយក៏អាចដាក់កម្រិតលើយុត្តាធិការផ្នែកបុគ្គលបញ្ហាទាំងឡាយដែលនៅចំពោះមុខតុលាការយុត្តាធិការតាមសាច់រឿងរយៈពេលដែលតុលាការនឹងធ្វើការកាត់សេចក្តីលើសំណុំរឿងនិងយុត្តាធិការបណ្តោះអាសន្ន ។ ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាធ្វើការកំណត់យុត្តាធិការបណ្តោះអាសន្នរបស់តុលាការដើម្បីអនុវត្តលើ «ឧក្រិដ្ឋកម្ម និងការរំលោភធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជាទំនៀមទម្លាប់ច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយប្រទេសកម្ពុជាដែលបទឧក្រិដ្ឋ និងការរំលោភទាំងឡាយណាត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩» ។ កាលបរិច្ឆេទទាំងពីរនេះគឺស្របទៅតាមកាលបរិច្ឆេទដែលទទួលស្គាល់ជាទូទៅថាជាការចាប់កំណើតនិងការបញ្ចប់ទៅវិញនៃរបប ប៉ុល ពត (របបកម្ពុជាប្រជាធិបតេយ្យ) ដោយឆ្លុះបញ្ចាំងពីស្ថានភាពរបស់ប្រទេសកម្ពុជានិងឆន្ទៈរបស់សហគមន៍អន្តរជាតិក្នុងការផ្តោតទៅលើដំណើរការកាត់ទោសលើជនដែលដល់ «ដ៏សាហាវឃោរឃៅ» ។

យុត្តាធិការដ៏មានកម្រិតរបស់តុលាការបានបង្ហាញឲ្យឃើញពីការព្រួយបារម្ភពីបញ្ហាអនុវត្ត និងបញ្ហានយោបាយ ។ ការដាក់កម្រិតលើយុត្តាធិការបណ្តោះអាសន្នស្រដៀងគ្នានេះ ក៏មានឃើញនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ដែលធ្វើការគូសបញ្ជាក់ពីយុត្តាធិការដាច់ដោយឡែករបស់តុលាការទាក់ទងនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនិងនយោបាយ ។ ការដាក់កម្រិតលើយុត្តាធិការទាំងនេះឆ្លុះបញ្ចាំងពីគោលដៅមួយ នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិក្នុងការយកចិត្តទុកដាក់នឹងតុលាការកូនកាត់ដែលធ្វើការកាត់ទោសជនដែលទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរជាជាងតុលាការដែលគ្រាន់តែដំណើរការកាត់ទោសដើម្បីស៊ើបអង្កេតបរិបទប្រវត្តិសាស្ត្រដ៏ធំមួយដែលការរំលោភសិទ្ធិមនុស្សបានកើតមានឡើងប៉ុណ្ណោះ ។ នេះគឺជាវិធីសាស្ត្រមួយដែលអាចធ្វើឲ្យតុលាការនោះមានដាច់ពាក់ព័ន្ធបញ្ហានយោបាយ ។ យ៉ាងណាមិញ បើទោះបីជាវាមានសារសំខាន់ក្នុងការកំណត់វិសាលភាពរបស់តុលាការដូចជាតុលាការខ្មែរក្រហមក៏ដោយ ក៏វាមានសារសំខាន់ដូចគ្នាដែរក្នុងការទទួលស្គាល់ថា ព្រឹត្តិការណ៍ទាំងនេះមិនបានកើតឡើងនៅក្នុងរយៈពេលនៃប្រវត្តិសាស្ត្រហើយការពិភាក្សាលើព្រឹត្តិការណ៍ដែលកើតឡើងមុនឆ្នាំ១៩៧៥ និងក្រោយឆ្នាំ១៩៧៩ អាចនឹងមានសារសំខាន់ក្នុងការដំណើរការកាត់ក្តីដែលត្រឹមត្រូវ និងយុត្តិធម៌ ។ ជាញឹកញាប់ ព្រឹត្តិការណ៍ដែលបានកើតឡើងក្រៅអំឡុងពេលទាំងពីរខាងលើនេះមានសារសំខាន់សម្រាប់សេចក្តីសម្រេចថាតើធាតុផ្សំសំខាន់ៗរបស់ឧក្រិដ្ឋកម្មគួរតែត្រូវបានយកមកបង្ហាញឬយ៉ាងណា ។ ជាឧទាហរណ៍ ឧក្រិដ្ឋកម្មស្តីពីការសមគំនិតអាចទាមទារឲ្យមានការពិនិត្យពិច័យលើគម្រោងការដែលបានកើតឡើងមុនឆ្នាំ១៩៧៥ឬក៏ថាព្រឹត្តិការណ៍មុនឆ្នាំ១៩៧៥ អាចលាតត្រដាងពីធាតុផ្សំផ្នែកសតិអារម្មណ៍របស់ឧក្រិដ្ឋកម្មដូចជាឧក្រិដ្ឋកម្មដោយចេតនា ។ គួរឲ្យចាប់អារម្មណ៍នៅក្នុងអំឡុងកិច្ចចរចារដ្ឋាភិបាលកម្ពុជាបានចូលរួមនៅក្នុងការគាំទ្រឲ្យមានយុត្តាធិការបណ្តោះអាសន្នដែលអាចនឹងពង្រីកបានដើម្បីប្រមូលផ្តុំព្រឹត្តិការណ៍ផ្សេងៗទុកជាទស្សនៈប្រវត្តិសាស្ត្រ ។ ភាពតានតឹងនៃការចរចានេះជំរុញឲ្យតុលាការមានសក្តានុពលភាពខ្ពស់ដោយសម្រេចបានជោគជ័យក្នុងការស្វែងរកការពិតនៃប្រវត្តិសាស្ត្រ ។

### ការកំណត់យុត្តាធិការបណ្តោះអាសន្នរបស់សាលាក្តីខ្មែរក្រហម

ដំណើរការដើម្បីបង្កើតសាលាក្តីខ្មែរក្រហមបានចាប់ផ្តើមនៅខែមិថុនា ឆ្នាំ១៩៩៧ នៅពេលដែលសហនាយករដ្ឋមន្ត្រីកម្ពុជាទាំងពីរបានផ្ញើសារលិខិតមួយច្បាប់ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិដោយស្នើសុំជំនួយពីអង្គការសហប្រជាជាតិ «ដើម្បីនាំជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងអំឡុងពេលគ្រប់គ្រងរបស់ខ្មែរក្រហមចាប់ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩មកកាត់ទោស» ។

អង្គសន្និបាតរបស់អង្គការសហប្រជាជាតិបានទទួលយកសំណើរបស់ប្រទេសកម្ពុជា ហើយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានតែងតាំងក្រុមអ្នកជំនាញមួយដើម្បីស្ទាបស្ទង់លទ្ធភាពនៃការបង្កើតតុលាការ ។ គោលការណ៍ចម្បងរបស់ក្រុមអ្នកជំនាញនេះគឺ «ដើម្បីកំណត់លក្ខណៈនៃឧក្រិដ្ឋកម្មដែលត្រូវបាន

ប្រព្រឹត្តឡើងដោយមេដឹកនាំខ្មែរក្រហមនៅអំឡុងឆ្នាំ១៩៧៥-១៩៧៩» «ដើម្បីស្វាបស្ទង់លទ្ធភាពក្នុងការនាំមេដឹកនាំទាំងនោះមកកាត់ទោស» និង «ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមនៅចំពោះមុខយុត្តាធិការជាតិ ឬអន្តរជាតិមួយ» ។

គោលការណ៍របស់ក្រុមជំនាញនេះបានបង្គាប់ឲ្យអ្នកជំនាញធ្វើការពិចារណាលើការរំលោភសិទ្ធិមនុស្សដែលបានកើតឡើងនៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ ។ អ្នកទាំងអស់នេះយល់ថាគោលការណ៍នេះគឺសំដៅលើអំឡុងពេលគ្រប់គ្រងរបស់ខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជាជាពិសេសគឺចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ហើយក៏បានសម្រេចថាការរំលោភបំពានរបស់ខ្មែរក្រហមលើច្បាប់អន្តរជាតិដែលបានកើតឡើងខុសពីអំឡុងពេលខាងលើគឺហួសពីវិសាលភាពនៃការស៊ើបអង្កេតលុះត្រាតែវាមិនមានសារសំខាន់អ្វីក្នុងការពិភាក្សាពីគោលការណ៍របស់ក្រុមអ្នកជំនាញនេះ ។ នៅក្នុងការពិភាក្សាពីបញ្ហាថាតើជនណាខ្លះដែលគួរតែត្រូវនាំមកកាត់ទោសដោយតុលាការ ក្រុមអ្នកជំនាញបានពន្យល់បកស្រាយថាការកាត់ទោសជនទាំងឡាយណាពីបទរំលោភសិទ្ធិមនុស្សដែលកើតឡើងខុសពីអំឡុងពេលគ្រប់គ្រងនៃរបបកម្ពុជាប្រជាធិបតេយ្យអាច «ប៉ះពាល់ដល់លក្ខណៈឧក្រិដ្ឋកម្មប្លែកគេតែមួយគត់នេះដែលបានប្រព្រឹត្តដោយមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ» ប៉ុន្តែក្រុមអ្នកជំនាញបានទុកឲ្យភាគីដែលចូលរួមបង្កើតតុលាការធ្វើការសម្រេចចិត្តចុងក្រោយពីបញ្ហាយុត្តាធិការបណ្តោះអាសន្នរបស់តុលាការ ។ ឆន្ទៈដែលបានបង្ហាញនៅក្នុងសារលិខិតរបស់រដ្ឋាភិបាលកម្ពុជាទៅកាន់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិក្នុងការស្នើសុំឲ្យមានការបង្កើតតុលាការត្រូវបានប្រឈមមុខនឹងព្រឹត្តិការណ៍ក្នុងស្រុកមួយចំនួន ដូចជា ការតស៊ូប្រឆាំងដណ្តើមអំណាចផ្ទៃក្នុង ការស្លាប់របស់ ប៉ុល ពត និងឱកាសក្នុងការជំរុញលើកទឹកចិត្តឲ្យមានការចុះចូលជាមួយនឹងរដ្ឋាភិបាលរបស់ក្រុមខ្មែរក្រហមដូចជា អៀង សារី ជាដើម ។ ខណៈពេលដែលក្រុមអ្នកជំនាញខិតខំផ្តល់សេចក្តីណែនាំ មេដឹកនាំខ្មែរក្រហមជាច្រើនដូចជា នួន ជា ខៀវ សំផន បានចុះចូលជាមួយនឹងរដ្ឋាភិបាលដែលបានជំរុញឲ្យនាយករដ្ឋមន្ត្រី ហ៊ុន សែន និយាយថា «ពេលវេលាដែលយើងត្រូវជីករណ្តៅកប់អតីតកាលបានមកដល់ហើយ» ។ នេះគឺជាឆន្ទៈមួយដែលប្រឆាំងនឹងឆន្ទៈបង្កើតតុលាការដើម្បីកាត់ទោសឧក្រិដ្ឋកម្មសង្គ្រាម ។ នៅខែមករា ឆ្នាំ១៩៩៩ សម្តេច ហ៊ុន សែន បានប្រគល់អនុស្សរណៈមួយទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិដោយស្នើថា ការបង្កើតតុលាការអាចប៉ះពាល់ដល់ស្ថិរភាពប្រទេស ហើយបានណែនាំថាប្រសិនបើមានការបង្កើតតុលាការនោះគួរតែធ្វើការកាត់ទោសឧក្រិដ្ឋកម្ម ដែលកើតឡើងមុនឆ្នាំ១៩៧៥ និងក្រោយឆ្នាំ១៩៧៩ ។ បន្ទាប់មក សម្តេច ហ៊ុន សែន បានផ្ញើសារលិខិតមួយទៀតឆ្លើយតបនឹងរបាយការណ៍របស់ក្រុមអ្នកជំនាញដែលសម្តេចបានបង្ហាញក្តីបារម្ភថា ការបង្កើតឲ្យមានតុលាការអាចបង្កជាសង្គ្រាមឈ្លបនៅក្នុងប្រទេសកម្ពុជា ហេតុដូច្នេះរដ្ឋាភិបាលសុំស្នើឲ្យមានជាគណៈកម្មាធិការស្វែងរកការពិតនិងការផ្សះផ្សា ដូចគ្នានឹងប្រទេសអាហ្វ្រិកខាងត្បូងវិញ ។ ក្រោយមកទៀត រដ្ឋាភិបាលកម្ពុជាបានងាកមកគាំទ្រការបង្កើតតុលាការវិញនៅពេលដែល តាម៉ុក ជាមេដឹកនាំខ្មែរក្រហមម្នាក់ត្រូវបានចាប់ខ្លួននៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៩ ។ សម្តេច ហ៊ុន សែន បានបង្ហាញនូវចំណាប់អារម្មណ៍ថ្មីលើការបង្កើតឲ្យមានតុលាការមួយដើម្បីធ្វើការកាត់ទោសជនជាប់ចោទម្នាក់ដែលមិនព្រមចុះចាញ់គឺ តាម៉ុក ។ លោក ថូម៉ាស់ ហាម៉ាប៊ឺក តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកច្បាប់បានកត់សម្គាល់ថា «វាទំនងជាថាការបង្កើតតុលាការត្រូវបានចាត់ទុកជាមធ្យោបាយមួយដើម្បីធ្វើឲ្យខ្មែរក្រហមទទួលបរាជ័យទាំងស្រុង» ។

នៅក្នុងសារលិខិតដំបូង បើទោះបីជារដ្ឋាភិបាលកម្ពុជាបានដាក់លើកឡើងពីយុត្តាធិការថិរវេលានៃឆ្នាំ១៩៧៥និង១៩៧៩ក៏ដោយ ក៏រដ្ឋាភិបាលកម្ពុជាបានប្រើប្រាស់យុត្តាធិការថិរវេលារបស់តុលាការជាការទាមទារនៅក្នុងអំឡុងពេលចរចាដោយស្នើឲ្យមានការចោទប្រកាន់នៅពេលដែលអង្គការសហប្រជាជាតិដាក់ជូនបទបញ្ញត្តិដែលរដ្ឋាភិបាលកម្ពុជាមិនយល់ស្របជាមួយ ។ បញ្ហាចម្បងជាងគេថា តើព្រះរាជអាជ្ញាអន្តរជាតិអាចអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការចោទប្រកាន់ដោយគ្មានការយល់ស្របពីសហព្រះរាជអាជ្ញាជាតិរបស់ខ្លួនបានដែរឬទេនោះបានជំរុញឲ្យ

សម្តេច ហ៊ុន សែន គួសបញ្ជាក់ប្រាប់អគ្គលេខាធិការអង្គការសហប្រជាជាតិនៅខែមេសាឆ្នាំ២០០០ថា ប្រសិនបើព្រះរាជអាជ្ញាអន្តរជាតិត្រូវបានអនុញ្ញាតឲ្យអនុវត្តសិទ្ធិដោយឯករាជ្យនោះមានន័យថាច្បាប់បង្កើតតុលាការអាចនឹងអនុញ្ញាតឲ្យមានការកាត់ទោសឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងចាប់ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៩៩ ។

រដ្ឋាភិបាលកម្ពុជាមិនមែនជាភាគីមួយដែលមានចំណាប់អារម្មណ៍ក្នុងការដាក់កម្រិតលើយុត្តាធិការថិរវេលារបស់សាលាក្តីខ្មែរក្រហមឡើយ ។ សេចក្តីជំទាស់ពីប្រទេសចិនដែលជាប្រទេសដែលខ្មែរក្រហមពឹងផ្អែកដើម្បីជំនួយឧបត្ថម្ភនៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ក៏បានធ្វើឲ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិមួយប្រភេទដែលត្រូវបានណែនាំដោយក្រុមអ្នកជំនាញរបស់អង្គការសហប្រជាជាតិសម្រាប់ប្រទេសកម្ពុជាដែរ ។ បន្ទាប់ពីរបាយការណ៍របស់ក្រុមអ្នកជំនាញត្រូវបានផ្សព្វផ្សាយ ប្រទេសចិនបានប្រាប់ដល់សហរដ្ឋអាមេរិកថាខ្លួននឹងជំទាស់សំណើសុំឲ្យមានការបង្កើតតុលាការនៅចំពោះមុខក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ ។ នៅពេលដែលសម្តេច ហ៊ុន សែន បានឆ្លើយតបនឹងរបាយការណ៍របស់ក្រុមអ្នកជំនាញដោយព្យាយាមពង្រីកយុត្តាធិការថិរវេលាពីឆ្នាំ១៩៧០រហូតដល់ឆ្នាំ១៩៩៨សហរដ្ឋអាមេរិកបានបដិសេធច្រានចោលសំណើនេះ ពីព្រោះវាអាចនឹងរាប់បញ្ចូលទាំងព្រឹត្តិការណ៍នៃយុទ្ធនាការទម្លាក់គ្រាប់បែកកាលពីឆ្នាំ១៩៧០របស់អាមេរិកនៅប្រទេសកម្ពុជា ។ នៅចុងបញ្ចប់ ច្បាប់បង្កើតសាលាក្តីខ្មែរក្រហមបានកំណត់យុត្តាធិការថេរវេលាដែលត្រូវបានយល់ស្របតាំងពីដើមមក ។

## ប្រធានបទដែលបានស្នើឡើងសម្រាប់អង្គជំនុំជម្រះក្តី

នៅក្នុងអង្គប្រជុំរបស់ក្រុមគ្រប់គ្រងអង្គជំនុំជម្រះកាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងរបស់សាលាក្តីខ្មែរក្រហមបានប្រកាសថាអង្គជំនុំជម្រះសាលាដំបូងមានគោលបំណងចាប់ផ្តើមជំនុំជម្រះក្តីដោយដដែកពិភាក្សាដំបូងលើប្រធានបទចំនួនបួនសម្រាប់សំណុំរឿង០០២ដើម្បីលាតត្រដាងពីរចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យតួនាទីរបស់ជនជាប់ចោទនីមួយៗនៅក្នុងអំឡុងមុនរបបគ្រប់គ្រងនៃរបបកម្ពុជាប្រជាធិបតេយ្យ និងគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យស្តីពីបញ្ហាដែលបានលើកឡើងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ ជាការឆ្លើយតប ជនជាប់ចោទ អៀង សារី និង នួន ជា បានលើកឡើងប្រធានបទនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដោយស្នើសុំឲ្យមានការដាក់បញ្ចូលប្រធានបទមុនឆ្នាំ១៩៧៥និងក្រោយឆ្នាំ១៩៧៩ ។ ប្រធានបទរបស់មេដឹកនាំទាំងនេះ "មានជាប់ពាក់ព័ន្ធនឹងការចោទប្រកាន់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ហើយ "មានសារសំខាន់ក្នុងការកំណត់ដ៏សមស្រប



អ្នកភូមិចូលរួមសវនាការកាត់ទោសមេដឹកនាំ

មួយលើបទចោទប្រកាន់" ។

ប្រធានបទដែលស្នើសុំដោយ អៀង សារី រួមមាន ៖ វប្បធម៌និងប្រជាសាស្ត្ររបស់ប្រទេសកម្ពុជាចាប់ពីអំឡុងពេលមុនអាណានិគមរហូតដល់ឆ្នាំ១៩៧៥ ប្រវត្តិសង្ខេបនៃការកកើតនិងគោលដៅរបស់កម្ពុជាឆ្វេងនិយម បរិបទនៃឥរិយាបថចំពោះសាសនាព្រះពុទ្ធនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បរិបទនៃឥរិយាបថចំពោះជនជាតិចាមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បរិបទនៃឥរិយាបថចំពោះជនជាតិវៀតណាមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការទទួលស្គាល់របបកម្ពុជាប្រជាធិបតេយ្យ

ដោយអង្គការសហប្រជាជាតិថាជារដ្ឋាភិបាលស្របច្បាប់របស់កម្ពុជា រួចនាសម័យរដ្ឋាភិបាលនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជានិងទីតាំងប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យដែលទាំងអស់នេះជាប្រធានបទរួមរបស់“អៀង សារី”) ។

នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១ ក្រុមមេធាវីការពារក្តីរបស់ នួន ជា បានដាក់ប្រធានបទមួយដែលគាំទ្រការស្នើសុំរបស់ អៀង សារី ដើម្បីបន្ថែមប្រធានបទ ហើយបានស្នើថាប្រធានបទដែលបន្ថែមនោះគួរតែដាក់បញ្ចូលនៅក្នុងកាលវិភាគរបស់អង្គជំនុំជម្រះ ។ ដោយប្រកាន់ស្របតាមភាពសមហេតុផលនៃប្រធានបទរបស់ អៀង សារី ក្រុមមេធាវីការពារក្តីរបស់ នួន ជា បានលើកឡើងពីប្រធានបទដែលគួរដាក់បញ្ចូលក្នុងកាលវិភាគរបស់អង្គជំនុំជម្រះដូចតទៅៈ



**សមាសធាតុបរិបទជាប់ពាក់ព័ន្ធ** ៖ ស្ថានភាព និងស្ថាប័នប្រវត្តិសាស្ត្រ នយោបាយភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម ប្រជាសាស្ត្រយោធា និងច្បាប់ ដែលក្នុងនោះរួមមានស្ថានភាពទាំងឡាយណានៃបក្សកុម្មុយនីស្តកម្ពុជានិងស្ថានភាពទាំងឡាយណាដែលកើតឡើងនៅក្នុង និងប្រព្រឹត្តឡើងនៅក្រៅទឹកដីកម្ពុជាដែលបង្កផលប៉ះពាល់ដោយផ្ទាល់ និងប្រយោលដល់កម្ពុជាមុន ក្នុងអំឡុង និងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ។

មេធាវីរបស់ នួន ជា បានអះអាងថា អង្គជំនុំជម្រះក្តីដែលធ្វើឡើងដោយមិនបានវិភាគលើបរិបទនៃឧក្រិដ្ឋកម្មដែលកូនក្តីរបស់ខ្លួនត្រូវបានចោទប្រកាន់អាចនឹងប៉ះពាល់ដល់សិទ្ធិរបស់កូនក្តីខ្លួនក្នុងការទទួលបានអង្គជំនុំជម្រះក្តីដែលត្រឹមត្រូវ និងយុត្តិធម៌ ។

**ការឆ្លើយតបនឹងប្រធានបទដែលបានស្នើឡើង**

អង្គជំនុំជម្រះសាលាដំបូងរបស់សាលាក្តីខ្មែរក្រហមបានឆ្លើយតបទៅនឹងប្រធានបទរបស់ អៀង សារី និង នួន ជា នៅក្នុងសេចក្តីបង្គាប់ទុកជាមុនរបស់សវនាការបឋមទាក់ទងនឹងសាក្សីស្នើសុំ ។ អង្គជំនុំជម្រះបានប្រកាសថា នៅក្នុងដំណាក់កាលនេះ ចៅក្រមនឹងបដិសេធច្រានចោលប្រធានបទទាំងអស់នេះដែលមានបំណងដាក់បញ្ចូលព្រឹត្តិការណ៍មុនឆ្នាំ១៩៧៥និងក្រោយឆ្នាំ១៩៧៩ទៅក្នុងបញ្ជីប្រធានបទដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចក្នុងការដំណើរការអង្គសវនាការ ។ ចៅក្រមបានបន្តណែនាំនូវបទដ្ឋានថ្មីមួយសម្រាប់ករណីដែលត្រូវតែពិចារណាលើបញ្ហានិងព្រឹត្តិការណ៍បរិបទប្រវត្តិសាស្ត្រដែលឋិតនៅក្រៅយុត្តាធិការថិរវេលារបស់សាលាក្តីខ្មែរក្រហមដូចជាករណីៈ “នៅពេលដែលបញ្ហានោះមានជាប់ពាក់ព័ន្ធយ៉ាងច្បាស់នឹងបញ្ហាយុត្តាធិការរបស់សាលាក្តីខ្មែរក្រហមនិងវិសាលភាពរបស់អង្គជំនុំជម្រះក្តីដូចដែលបានសម្រេចដោយចៅក្រម” ។

បើទោះបីជាចៅក្រមមិនបានបកស្រាយពីមូលហេតុដែលចៅក្រមសម្រេចថាភស្តុតាងត្រូវតែ “ជាប់ពាក់ព័ន្ធយ៉ាងច្បាស់”ក៏ដោយ ក៏សាលាក្តីខ្មែរក្រហមអាចអនុម័តច្បាប់បន្ថែមទៀតនៅក្នុងករណីដែលនីតិវិធីមុនមិនអាចដោះស្រាយបញ្ហាជាក់លាក់ណាមួយបាន ឬនៅពេលដែលគ្មានភាពច្បាស់លាស់ទាក់ទងនឹងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬនៅពេលដែលមានសំណួរចោទសួរទាក់ទងពីភាពស៊ីសង្វាក់គ្នានៃនីតិវិធីរបស់តុលាការជាមួយនឹងបទដ្ឋានអន្តរជាតិ” ។ ដោយសារតែវិធានផ្ទៃក្នុងនិងច្បាប់កម្ពុជាមិនបកស្រាយពីបញ្ហាការទទួលស្គាល់ប្រធានបទនៃថិរវេលាបន្ថែមសាលាក្តីខ្មែរក្រហមត្រូវបានអនុញ្ញាតឲ្យអនុវត្តតាមច្បាប់អន្តរជាតិដើម្បីការណែនាំ ។

**ភស្តុតាងថិរវេលាបន្ថែមនៅក្នុងតុលាការអន្តរជាតិ**

បើទោះបីជាតម្រូវការអនុវត្ត និងនយោបាយសម្រាប់ការកំណត់ថិរវេលាត្រូវបានដោះស្រាយរួចរាល់ក្តី តុលាការអន្តរជាតិបានអនុញ្ញាតទទួលយកភស្តុតាងដែលឋិតនៅក្រៅយុត្តាធិការថេរវេលាដើម្បីចាត់ចូលក្នុងកាលៈទេសៈមានកម្រិត ។ ជាឧទាហរណ៍នៅក្នុងរឿងក្តីរបស់ ចូសេហ្វ អាល់ ស្តូធី និងជនផ្សេងទៀតនៅចំពោះមុខតុលាការយោធារបស់សហរដ្ឋអាមេរិកកាលពីឆ្នាំ១៩៤៧ ចៅក្រមបានទទួលយកភស្តុតាងដែលហួសពីយុត្តាធិការថិរវេលា

របស់តុលាការពីព្រោះ "សកម្មភាពទាំងនោះជាប់ពាក់ព័ន្ធនឹងបទចោទប្រកាន់...ហើយសកម្មភាពមួយក្នុងចំណោមសកម្មភាពទាំងនោះត្រូវបានចោទប្រកាន់ថាជាបទល្មើសឯករាជ្យមួយ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ។

ដូចគ្នានេះ តុលាការព្រហ្មទណ្ឌកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនក៏បានសម្រេចឲ្យមានការទទួលយកភស្តុតាងដែលហួសពីយុត្តាធិការថិរវេលារបស់តុលាការនៅក្នុងកាលៈទេសៈដ៏មានកម្រិតមួយ នៅពេលដែលឧក្រិដ្ឋកម្មនោះបានកើតឡើងនៅក្នុងយុត្តាធិការថិរវេលារបស់តុលាការនិងនៅពេលដែលគោលបំណងរបស់ភស្តុតាងបម្រើប្រយោជន៍ដល់វិស័យយុត្តិធម៌មិនមែនគ្រាន់តែដើម្បីបង្កាច់បង្ខូចអត្តចរិករបស់ជនជាប់ចោទឬដើម្បីប្រែក្លាយអង្គជំនុំជម្រះក្តីនោះទៅជាការជជែកដេញដោលនយោបាយឡើយ ។

រឿងក្តីដើមរបស់ព្រះរាជអាជ្ញាប្រឆាំងនឹង ណាហ៊ីម៉ាណា ដែលត្រូវបានស្គាល់ថាជា "រឿងក្តីសារព័ត៌មាន" បានបង្កើតច្បាប់មួយសម្រាប់កាលៈទេសៈណាដែលតុលាការឧក្រិដ្ឋកម្មអន្តរជាតិត្រូវបានអនុញ្ញាតឲ្យដាក់ភស្តុតាងដែលឋិតនៅក្រោយយុត្តាធិការថិរវេលារបស់ខ្លួន ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនចៅក្រមសាលាឧទ្ធរណ៍បានកត់សម្គាល់ថា បើទោះបីវាគឺជាគោលដៅរបស់អ្នកតាក់តែងលក្ខន្តិកៈដែលថាតុលាការព្រហ្មទណ្ឌកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាមានត្រឹមតែយុត្តាធិការប្រឆាំងនឹងជនជាប់ចោទនៅពេលដែលធាតុផ្សំទាំងអស់ដែលត្រូវបានកំណត់ឲ្យដាក់បង្ហាញដើម្បីរកឃើញទោសកំហុសនោះកើតមាននៅក្នុងឆ្នាំ១៩៩៤ក៏ដោយ ក៏តុលាការបានសម្រេចយ៉ាងច្បាស់ណាស់ថា បទបញ្ញត្តិរបស់លក្ខន្តិកៈនោះមិនបានរារាំងដល់ការទទួលយកភស្តុតាងស្តីពីព្រឹត្តិការណ៍មុនឆ្នាំ១៩៩៤ឡើយ ។ ភស្តុតាងនោះអាចនឹងត្រូវបានទទួលស្គាល់ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចថា "ភស្តុតាងនោះ" អាច "ជាប់ពាក់ព័ន្ធ ហើយអាចជាខ្លឹមសារភស្តុតាងនោះគ្មានហេតុផលប្រឆាំងណាមួយ ដើម្បីមិនរាប់បញ្ចូលភស្តុតាងនេះឡើយ ។ ចៅក្រមសាលាឧទ្ធរណ៍បានលើកឡើងករណីបួនដែលភស្តុតាងបែបនោះអាចនឹងចាត់ទុកថាមានជាប់ពាក់ព័ន្ធនិងមានខ្លឹមសារជាភស្តុតាងៈ

◆ ការគូសបញ្ជាក់បរិបទដែលមានតាមផ្លូវច្បាប់និងការពិត

◆ ការសម្រេចដោយផ្អែកលើសេចក្តីយោងស្តីពីធាតុផ្សំនៃការប្រព្រឹត្តឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងយុត្តាធិការរបស់តុលាការ

◆ ការបង្ហាញពីប្រភេទចេតនានៃការប្រព្រឹត្តឧក្រិដ្ឋកម្ម

◆ ការបន្តប្រព្រឹត្តឧក្រិដ្ឋកម្ម

បើទោះបីជាវិធានផ្ទៃក្នុងរបស់សាលាក្តីខ្មែរក្រហមមិនរាប់បញ្ចូលបទដ្ឋានអប្បបរិមានៃភាពជាប់ពាក់ព័ន្ធសម្រាប់ការទទួលស្គាល់ភស្តុតាងដូចដែលបានសម្រេចដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាក៏ដោយ ក៏ច្បាប់ករណីរបស់សាលាក្តីខ្មែរក្រហមបានដាក់បញ្ចូលបទដ្ឋាននេះដែរ ។ ដូច្នេះ ដើម្បីឲ្យមានការទទួលស្គាល់ភស្តុតាងថិរវេលាបន្ថែមសាលាក្តីខ្មែរក្រហមចាំបាច់ ត្រូវតែគូសបញ្ជាក់ឲ្យច្បាស់ពីបរិបទចេញសេចក្តីសម្រេចដោយផ្អែកលើសេចក្តីយោងស្តីពីធាតុផ្សំនៃឧក្រិដ្ឋកម្មដែលជនជាប់ចោទ ត្រូវបានចោទប្រកាន់បង្ហាញឲ្យឃើញនូវប្រភេទចេតនានៃការប្រព្រឹត្តឧក្រិដ្ឋកម្មឬរកឲ្យឃើញឧក្រិដ្ឋកម្មដែលបន្តកើតមានឡើង ។ បើទោះបីជាភស្តុតាងបំពេញទៅតាមលក្ខន្តិកៈទាំងនេះក៏ដោយ ក៏ការសម្រេចទទួលយកភស្តុតាងគឺផ្អែកលើឆន្ទានុសិទ្ធិរបស់ចៅក្រម ។

## ការគូសបញ្ជាក់លើសេចក្តីជំទាស់ដែលមាន

នៅក្នុងសាលក្រមសម្រាប់សំណុំរឿង០០១ សាលាក្តីខ្មែរក្រហមបានសម្រេចពិចារណាលើព្រឹត្តិការណ៍កាលពីសតវត្សរ៍ទី១៥ ដើម្បីបង្កើតបរិបទនៃគោលនយោបាយរបស់ខ្មែរក្រហមនិងជម្លោះរបស់ខ្មែរក្រហមជាមួយនឹងវៀតណាម ។ ផ្នែកស្តីពី "បរិបទប្រវត្តិសាស្ត្រនិងជម្លោះប្រដាប់អាវុធ" ពិពណ៌នាពីការពង្រីកទឹកដីរបស់វៀតណាមតាមភូមិភាគខាងត្បូងនៅក្នុងសតវត្សរ៍ទី១៥ ដោយចាត់ទុកព្រឹត្តិការណ៍នេះថា "បានបណ្តាលឲ្យមានការតស៊ូដ៏រាំរ៉ៃរវាងកម្ពុជា និងវៀតណាម" ។ ក្រោយមកទៀតចៅក្រមសាលាដំបូងបានគូសបញ្ជាក់នៅក្នុងសាលក្រមរបស់ខ្លួនថាបរិបទនេះត្រូវបានចែងឡើងដើម្បីបំពេញតម្រូវការសមាសធាតុនៃការកកើតឡើងជម្លោះប្រដាប់អាវុធអន្តរជាតិដែលទាមទារឲ្យមានសម្រាប់ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុង

ហ្សីណែវ ឆ្នាំ១៩៤៩ ។

នៅក្នុងរឿងក្តីរបស់ ណាហ៊ីម៉ាណា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដាបានសម្រេចថាតួនាទីរបស់អ្នកប្តឹងឧទ្ធរណ៍នៅក្នុងការបង្កើតកម្មវិធីទូរទស្សន៍និងវិទ្យុ "ឡាប្រ៊ី ដឹស ម៉ាល់កូឡាញ" កាលពីឆ្នាំ១៩៩៣និងការគ្រប់គ្រងចាប់តាំងពីពេលបង្កើតកម្មវិធីនេះគួរតែយកមកពិចារណានៅក្នុងការវិនិច្ឆ័យរបស់តុលាការស្តីពីការទទួលខុសត្រូវពីបទឧក្រិដ្ឋរបស់ ណាហ៊ីម៉ាណា ក្រោយថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៤ ពីព្រោះវាបានផ្តល់ជាបរិបទមួយស្តីពីតួនាទីរបស់ជនជាប់ចោទនៅក្នុងកម្មវិធីទូរទស្សន៍និងវិទ្យុនោះ ដែលធ្វើការផ្សព្វផ្សាយនៅឆ្នាំ១៩៩៤ ដោយបំផុសបំផុលឲ្យមានការសម្លាប់លើជនជាតិទុតស៊ី ។ បទដ្ឋានភ័ស្តុតាងនេះត្រូវបានពិភាក្សាបន្ថែមទៀតនៅក្នុងរឿងក្តីរបស់ អាឡូយ ស៊ីមបា នៅពេលដែលជនជាប់ដែលប្តឹងឧទ្ធរណ៍បានស្នើសុំឲ្យមានដីកាមួយដើម្បីមិនរាប់បញ្ចូលបទចោទប្រកាន់មកលើខ្លួនដោយផ្អែកលើព្រឹត្តិការណ៍ដែលឋិតនៅក្រៅយុត្តាធិការថិរវេលារបស់តុលាការចេញពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ ចៅក្រមបានកត់សម្គាល់ឃើញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះគ្រាន់តែចោទប្រកាន់ជនជាប់ចោទ អាឡូយ ស៊ីមបា ពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងនៅចន្លោះថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៩៤ និងថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៩៤ ហើយសម្រេចថា ឯកសារយោងរបស់ព្រឹត្តិការណ៍មុនឆ្នាំ១៩៩៤ត្រូវបានកម្រិតមិនឲ្យផ្តល់បរិបទឬប្រវត្តិសង្ខេបសម្រាប់បទចោទប្រកាន់ឡើយ ។ វិសាលភាពនៃករណីលើកលែងនេះត្រូវបានពិភាក្សានៅក្នុងទស្សនៈដោយឡែករបស់ចៅក្រម សាហាប៊ូឌែន នៅក្នុងបណ្តឹងឧទ្ធរណ៍ជដែកជេញដោលរបស់ជនជាប់ចោទ ណាហ៊ីម៉ាណា ដែលត្រូវបានដកស្រង់ឡើងសម្រាប់រឿងក្តីរវាងព្រះរាជអាជ្ញា និងជនជាប់ចោទ ថេអូណីស្ទី បាហ្គូសូរ៉ា ។ នៅក្នុងរឿងក្តីនេះ លោកចៅក្រមបានចាត់ទុកបរិបទនេះ ថាជាព្រឹត្តិការណ៍មួយដែល "មានខ្លឹមសារ...មិនអាចពេញលេញនិងយល់បានឡើយ" ប្រសិនបើគ្មានព្រឹត្តិការណ៍មួយនេះ ។

ដូច្នេះ សាលាក្តីខ្មែរក្រហមអាចនឹងសម្រេចថាដើម្បីទទួលស្គាល់ប្រធានបទថិរវេលាបន្ថែមក្នុងករណីលើកលែងប្រធានបទទាំងអស់នេះអាចត្រូវការជាចាំបាច់ក្នុងការធ្វើជាគន្លឹះសម្រាប់រឿងក្តីដែលមិនបញ្ចូលប្រធានបទប្រភេទនេះនិងករណីដែលខ្លឹមសារនៃព្រឹត្តិការណ៍ទាំងនោះមិនមានខ្លឹមសារពេញលេញ ឬមិនអាចយកជាការបាន ។ វាអាស្រ័យលើចៅក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចថាតើប្រធានបទរបស់ជនជាប់ចោទ នួន ជា និង អៀង សារី មានលក្ខណៈត្រឹមត្រូវតាមបទដ្ឋាននេះដែរឬយ៉ាងណា ។

## សេចក្តីសម្រេចដោយផ្អែកលើសេចក្តីយោងនៃធាតុផ្សំរបស់ការប្រព្រឹត្តឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងអំឡុងយុត្តាធិការរបស់តុលាការ

បើទោះបីជាចៅក្រមអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ព្រឹត្តិការណ៍ទាក់ទងនឹងមន្ទីរម-១៣ដែលជាគុករបស់ខ្មែរក្រហមដែល ឌុច បានធ្វើការនៅទីនោះមុនរបបកម្ពុជាប្រជាធិបតេយ្យគឺឋិតនៅក្រៅយុត្តាធិការថិរវេលារបស់សាលាក្តីខ្មែរក្រហមក៏ដោយ ក៏ចៅក្រមបានស្តាប់សក្ខីកម្មទាក់ទងនឹងមន្ទីរម-១៣នេះ ពីព្រោះគុកនេះបានកើតឡើងមុនមន្ទីរស-២១ដែលជាគុកដែល ឌុច បានគ្រប់គ្រងនៅក្នុងអំឡុងពេលនៃយុត្តាធិការរបស់តុលាការនិងជាមូលដ្ឋាននៃបទចោទប្រកាន់ប្រឆាំងនឹង ឌុច ។ ចៅក្រមបានគូសបញ្ជាក់ថា បើទោះបីជាព្រឹត្តិការណ៍នៅមន្ទីរម-១៣មិនមាននៅក្នុងដីកាបញ្ជូនរឿងក្តីទៅជំនុំជម្រះ ដោយសារតែព្រឹត្តិការណ៍ទាំងនេះឋិតនៅក្រៅយុត្តាធិការថិរវេលារបស់តុលាការក៏ដោយ ក៏មន្ទីរម-១៣គឺជាគន្លឹះមួយក្នុងការស្វែងយល់ពី "បរិបទនៃមន្ទីរស-២១ទាក់ទងនឹងការគ្រប់គ្រងរចនាសម្ព័ន្ធដំណើរប្រតិបត្តិការ និងតួនាទីរបស់មន្ទីរស-២១ និងស្វែងយល់ពីបុព្វហេតុផ្សេងទៀតជាពិសេសគឺអត្តចរិករបស់ជនជាប់ចោទ" ។ ដូច្នេះ សហព្រះរាជអាជ្ញាបានចាត់ទុកមន្ទីរម-១៣ ជា "មូលដ្ឋានហ្វឹកហ្វឺនរបស់ជនជាប់ចោទ" ។

នៅក្នុងរឿងក្តីរបស់ ណាហ៊ីម៉ាណា ចៅក្រមសាលាឧទ្ធរណ៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដាបានសម្រេចថា ចៅក្រមអង្គជំនុំជម្រះសាលាដំបូងមិនបានប្រព្រឹត្តកំហុសឆ្គងក្នុងការទទួលស្គាល់ភ័ស្តុតាងនៃព្រឹត្តិការណ៍ដែលកើតឡើងមុនយុត្តាធិការថិរវេលារបស់តុលាការដើម្បីអះអាងពីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ បារ៉ាយ៉ាគវីហ្សា

ទេ ។ ភ័ស្តុតាងនេះបានរាប់បញ្ចូលទាំងវត្ថុមានរបស់ជនជាប់នៅក្នុង «បាតុកម្មនិងការបិទផ្លូវដែលបានបង្កើតជារចនាសម្ព័ន្ធមួយសម្រាប់បទចោទប្រកាន់ហើយដែលព្រឹត្តិការណ៍ទាំងនេះបានបណ្តាលឲ្យមានការសម្លាប់ប្រជាជនស៊ីវិលជាតិទុតស៊ី» ។ ចៅក្រមសាលាឧទ្ធរណ៍ក៏បានសម្រេចថា ភ័ស្តុតាងដែលឋិតនៅខាងក្រៅយុត្តាធិការថិរវេលារបស់តុលាការ «អាចក្លាយជាមូលដ្ឋានមួយសម្រាប់ការទាញយកសេចក្តីយោងពាក់ព័ន្ធនឹងចេតនាឬធាតុផ្សំផ្សេងៗរបស់ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងនៅក្នុងអំឡុងយុត្តាធិការថិរវេលា» ។ ចៅក្រមក៏បានផ្តល់ជាការបកស្រាយពីជនជាប់ចោទម្នាក់ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មមួយដែលបានប្រព្រឹត្តឡើងដោយមានកាលបរិច្ឆេទច្បាស់លាស់មួយ ។ ដូច្នេះ ព្រះរាជអាជ្ញាត្រូវតែអះអាងថា ចេតនាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានកើតឡើងដោយមានកាលបរិច្ឆេទគឺជាធាតុផ្សំនៃបទឧក្រិដ្ឋកម្ម ។ ភ័ស្តុតាងក្នុងការអះអាងខាងលើនេះមិនចាំបាច់ទាញចេញពីកាលបរិច្ឆេទរបស់ឧក្រិដ្ឋកម្មទេ ។ តុលាការអាចប្រើប្រាស់ព្រឹត្តិការណ៍ទាំងនេះចេញពីព្រឹត្តិការណ៍មុនដើម្បីធ្វើឲ្យសេចក្តីយោងដ៏សមហេតុផលមួយហើយអាចនឹងសម្រេចថាចេតនាដែលទំនងជាកើតឡើងក្នុងព្រឹត្តិការណ៍មុនក៏អាចកើតឡើងស្របពេលនឹងបទឧក្រិដ្ឋកម្មដែលត្រូវបានចោទ ប្រកាន់ដែរ ។

យ៉ាងណាមិញ ចៅក្រមនៅក្នុងរឿងក្តីរបស់ បាហ្គូសូរ៉ា បានលើកឡើងពីគោលការណ៍ចម្បងដ៏វែងមួយរបស់ច្បាប់ខំមិនឡដែលត្រូវបានអនុម័តដោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីដោយចែងថា «យោងតាមគោលការណ៍ទូទៅនៃច្បាប់ខំមិនឡភ័ស្តុតាងទាក់ទងនឹងអត្តចរិករបស់ជនជាប់ចោទគឺជាទូទៅមិនអាចទទួលយកដើម្បីបង្ហាញពីបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មឲ្យស្របទៅតាមគោលការណ៍នេះបានទេ» ។ ភ័ស្តុតាងថិរវេលាបន្ថែមនៃការប្រព្រឹត្តពីមុនរបស់ជនជាប់ចោទមិនអាចយកមកបង្ហាប់បង្ខូចអត្តចរិករបស់ជនជាប់ចោទបានទេ ។ ភ័ស្តុតាងបន្ថែមទាំងនោះត្រូវតែមានខ្លឹមសារជាភ័ស្តុតាង ។

ដើម្បីឲ្យប្រធានបទថិរវេលាបន្ថែមត្រូវបានទទួលយកក្នុងករណីលើកលែងនៃសេចក្តីសម្រេចដោយសេចក្តីយោងរបស់ធាតុផ្សំនៃការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងអំឡុងយុត្តាធិការថិរវេលាបានភាគីទាំងអស់របស់សាលាក្តីខ្មែរក្រហមអាចចាំបាច់ត្រូវតែបង្ហាញថាសេចក្តីយោងដ៏សមហេតុផលមួយដែលទាក់ទងនឹងឧក្រិដ្ឋកម្មដែលចោទប្រកាន់អាចនឹងទាញចេញពីភ័ស្តុតាងថិរវេលាបន្ថែម ។

## ការបង្ហាញពីប្រភេទចេតនានៃការប្រព្រឹត្តឧក្រិដ្ឋកម្មមួយ

សាលាក្តីខ្មែរក្រហមមិនទាន់បានបកស្រាយពីភាពជាប់ពាក់ព័ន្ធថិរវេលាក្នុងការអះអាងពីប្រភេទចេតនានៃការប្រព្រឹត្តឧក្រិដ្ឋកម្មនៅឡើយទេ ។ នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា វិធានសម្រាប់ទទួលស្គាល់ភ័ស្តុតាងស្តីពីប្រភេទដ៏ស៊ីសង្វាក់គ្នាមួយនៃការប្រព្រឹត្តឧក្រិដ្ឋកម្មត្រូវបានចែងនៅក្នុងវិធានរបស់តុលាការ ។ យោងតាមវិធាន៩៣ «ភ័ស្តុតាងស្តីពីប្រភេទនៃការប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ស៊ីសង្វាក់មួយដែលទាក់ទងនឹងការរំលោភដ៏ធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិតាមលក្ខន្តិកៈក្រុងរ៉ូមអាចនឹងទទួលស្គាល់ដើម្បីជាប្រយោជន៍ដល់ដំណើរការយុត្តិធម៌» ។ ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តីរបស់ ណាហ៊ីម៉ាណាបានចាត់ទុកវិធាននេះជាក្បួនអនុវត្តសម្រាប់ភ័ស្តុតាងដែលឋិតនៅក្រៅយុត្តាធិការថិរវេលារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាដោយមានលើកឡើងពីការសម្លាប់រង្គាលលើជនជាតិទុតស៊ីកាលពីឆ្នាំ១៩៩០,១៩៩១, និង១៩៩២ ដែលមានចែងយ៉ាងលម្អិតនៅក្នុងដីកាចោទប្រកាន់របស់ ណាហ៊ីម៉ាណាការធ្វើបុកទុក្ខម្នេញរបស់ជនជាប់ចោទមកលើជនជាតិទុតស៊ីដែលឋិតនៅក្រោមបង្គាប់របស់ជនជាប់ចោទក្នុងនាមជានាយកការិយាល័យព័ត៌មានផ្សព្វផ្សាយរ៉្វាន់ដា និងសេចក្តីសម្រេចរបស់ជនជាប់ចោទក្នុងការចាក់ផ្សាយសេចក្តីថ្លែងការណ៍មួយដែលបំផុសបំផុលប្រជាជនឲ្យប្រឆាំងនឹងជនជាតិទុតស៊ីដែលកត្តាទាំងអស់នេះបានបង្ហាញពីប្រភេទចេតនានៃការប្រព្រឹត្តឧក្រិដ្ឋកម្ម ។ នៅក្នុងរឿងក្តីរបស់ បាហ្គូសូរ៉ា ចៅក្រមបានចាត់ទុកភ័ស្តុតាងប្រភេទនេះថាជា «ភ័ស្តុតាងស្តីពីអង្គហេតុស្រដៀងគ្នា» និងជាសេចក្តីយោងដោយមានការទទួលស្គាល់លើមតិយោបល់របស់ហ្សាហាប៊ូដែន ក្នុងការគាំទ្រការទទួលយកភ័ស្តុតាងស្តីពីបទល្មើសកាលពីមុនដែល «ឆ្លុះបញ្ចាំងពីប្រភេទការគាត់តែង ឬអំឡុងពេលជា

ប្រព័ន្ធនៃការប្រព្រឹត្តឧក្រិដ្ឋកម្មដោយជនជាប់ចោទដែលធ្វើឲ្យការបកស្រាយរបស់ជនជាប់ចោទស្តីពីមូលដ្ឋាននៃការប្រព្រឹត្តឧក្រិដ្ឋកម្មអាចក្លាយជាការប្រមាថមើលងាយលើការយល់ឃើញជាទូទៅមួយនៃបទឧក្រិដ្ឋកម្ម" ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដាបានអនុវត្តតាមវិធីសាស្ត្ររបស់ប្រទេសកាណាដានៅក្នុងរឿងក្តីរបស់ ហេនឌី ក្នុងករណីដែលតុលាការធ្វើសេចក្តីសម្រេចថាតើករណីលើកលែងនៃភ័ស្តុតាងស្តីពីអង្គហេតុស្រដៀងគ្នានេះមានលក្ខណៈពេញលេញដែរឬយ៉ាងណា ។ បើយោងតាមតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដាដើម្បីធ្វើឲ្យករណីលើកលែងនេះមានលក្ខណៈពេញលេញ ភ័ស្តុតាងត្រូវតែបង្ហាញឲ្យឃើញពីៈ

១) ភាពជាប់ពាក់ព័ន្ធគ្នានៃពេលវេលាទាក់ទងពីការប្រព្រឹត្តឧក្រិដ្ឋកម្មស្រដៀងគ្នា

២) កម្រិតនៃភាពស្រដៀងគ្នានៃការប្រព្រឹត្តឧក្រិដ្ឋកម្មជាមួយនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់

៣) ចំនួននៃព្រឹត្តិការណ៍ប្រព្រឹត្តឧក្រិដ្ឋកម្មស្រដៀងគ្នា

៤) លក្ខណៈខុសប្លែកគ្នាផ្សេងៗដែលរួមផ្សំបានជាព្រឹត្តិការណ៍ប្រព្រឹត្តឧក្រិដ្ឋកម្ម

៥) ព្រឹត្តិការណ៍ដែលជាប់ពាក់ព័ន្ធគ្នា

៦) កត្តាផ្សេងៗទៀតដែលអាចនឹងគាំទ្រ ឬប្រឆាំងនឹងធាតុផ្សំរួមគ្នានៃការប្រព្រឹត្តឧក្រិដ្ឋកម្មស្រដៀងគ្នា ។

## ឧក្រិដ្ឋកម្មដែលបន្តកើតមានឡើង

តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានសម្រេចថាភ័ស្តុតាងថិរវេលាបន្ថែមអាចទទួលយកបានក្នុងករណីស្តីពីបទឧក្រិដ្ឋកម្មដែលបន្តកើតមានឡើងសម្រាប់ករណីដែលការប្រព្រឹត្តឧក្រិដ្ឋកម្មបានចាប់ផ្តើមឡើងមុនពេលយុត្តាធិការរបស់តុលាការ ហើយបានបន្តកើតឡើងនៅក្នុងអំឡុងពេលយុត្តាធិការ ។

យ៉ាងណាមិញ ការចោទប្រកាន់អាចនឹងផ្អែកលើផ្នែកនៃការប្រព្រឹត្តឧក្រិដ្ឋកម្មបែបនេះដែលកើតឡើងក្នុងអំឡុងយុត្តាធិការរបស់តុលាការ ។ ចៅក្រមអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ការសមគំនិតដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍និងការបំផុសបំផុលសាធារណជនឲ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ថាជាឧក្រិដ្ឋកម្មដែលអាចចាត់ទុកថាជាបទល្មើសដែលបន្តកើតមានឡើង ។

បើទោះបីជាបញ្ហានេះមិនទាន់បានកើតមានឡើងនៅក្នុងសាលាក្តីខ្មែរក្រហមក៏ដោយ ក៏វាអាចកើតមានឡើងនៅក្នុងបរិបទស្តីពីការលក្ខណៈខុសប្លែកនៃបទឧក្រិដ្ឋ ។ តុលាការអន្តរជាតិសិទ្ធិមនុស្សរបស់សហរដ្ឋអាមេរិកបានបែងចែកលក្ខណៈខុសប្លែកនៃបទឧក្រិដ្ឋជាឧក្រិដ្ឋកម្មដែលបន្តកើតឡើងហើយអង្គការសហប្រជាជាតិបានពង្រីកខ្លឹមសារនៃលក្ខណៈខុសប្លែកនៃបទឧក្រិដ្ឋថាជា "ការប្រព្រឹត្តឧក្រិដ្ឋកម្មប្រភេទដូចគ្នាជាបន្តបន្ទាប់" ដោយចាប់ផ្តើមឡើងនាអំឡុងពេលនៃការលុបបំបាត់និងការពន្យារពេលសម្រាប់អំឡុងពេលទាំងស្រុងរហូតដល់ឧក្រិដ្ឋកម្មនោះត្រូវបានបញ្ចប់ជាស្ថាពរ ។

## សេចក្តីសន្និដ្ឋាន

ទោះបីជាច្បាប់ករណី និងយុត្តាធិការអន្តរជាតិរបស់សាលាក្តីខ្មែរក្រហមបានបង្ហាញថាក្នុងករណីលើកលែងតុលាការអាចអនុញ្ញាតឲ្យទទួលស្គាល់ភ័ស្តុតាងថិរវេលាបន្ថែមក៏ដោយ ក៏វាអាស្រ័យនៅលើអង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចថាតើប្រធានបទទាំងអស់នេះដែលប្រគល់ឲ្យដោយជនជាប់ចោទ អៀង សារី និង នួន ជា មានលក្ខណៈសមស្របនឹងបទដ្ឋាន "ជាប់ពាក់ព័ន្ធ" របស់តុលាការដែរឬយ៉ាងណា ។ យុត្តាធិការអន្តរជាតិបានផ្តល់ជាសេចក្តីណែនាំក្នុងការសម្រេចថាតើក្នុងករណីណាដែលភ័ស្តុតាងបំពេញតាមបទដ្ឋាន "ជាប់ពាក់ព័ន្ធ" ដោយរួមមានៈ ករណីដែលយុត្តាធិការអន្តរជាតិនេះធ្វើការគូសបញ្ជាក់លើបរិបទដែលមានតាមផ្លូវច្បាប់និងតាមអង្គហេតុករណីដែលវាអនុញ្ញាតឲ្យតុលាការធ្វើសេចក្តីសម្រេចដោយផ្អែកលើសេចក្តីយោងស្តីពីធាតុផ្សំនៃការប្រព្រឹត្តឧក្រិដ្ឋកម្មដែលកើតមានឡើងនៅក្នុងយុត្តាធិការរបស់តុលាការករណីដែលវាបង្ហាញប្រភេទចេតនានៃការប្រព្រឹត្តឧក្រិដ្ឋកម្មឬករណីដែលវាជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបន្តកើតឡើងដូចជាលក្ខណៈខុសប្លែកគ្នានៃឧក្រិដ្ឋកម្មជាដើម ។ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០២មានឱកាសក្នុងការបន្តពន្យល់បកស្រាយលើប្រភេទភ័ស្តុតាងទាំងអស់នេះនិងធ្វើការគូសបញ្ជាក់លើភាពទទួលយកបាននៃកម្រិតភ័ស្តុតាងថិរវេលាបន្ថែម ។

**ហ្សាវីតា ហ្គ្រុប៊ីច**

# យុត្តិធម៌ជាមូលដ្ឋានគ្រឹះនៃការផ្សះផ្សា

បើនិយាយពីរបបខ្មែរក្រហមវិញ ប្រជាជនកម្ពុជាយល់ថា របបនេះបានដកហូតសិទ្ធិមូលដ្ឋាននិងសេរីភាពរបស់ប្រជាជនទាំងស្រុងតែម្តង ។ អ្នករស់រានមានជីវិតបានទទួលរងទុក្ខពីស្ថានភាពរស់នៅដ៏វេទនា ហើយប្រជាជនប្រមាណជិតពីរលាននាក់ត្រូវបានសម្លាប់នៅរវាងថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ មេដឹកនាំខ្មែរក្រហមបានប្រើប្រាស់អំណាចផ្តាច់ការដោយកម្ទេចរាល់ "សមាសធាតុខ្មាំងក្បត់នឹងបដិវត្តន៍" រួមទាំងកម្មាភិបាលនៅភូមិភាគ តំបន់ ស្រុក ឃុំ សហករណ៍ និងកង ។ ជនរងគ្រោះភាគច្រើនត្រូវបានចាប់ខ្លួន ធ្វើទារុណកម្ម សួរចម្លើយ និងសម្លាប់ដោយមិនដឹងមូលហេតុ ។ ចំណែកឯកម្មាភិបាលខ្មែរក្រហមថ្នាក់ទាបបានដឹងយ៉ាងច្បាស់ថា ខ្លួនត្រូវបានបង្ខំឲ្យប្រព្រឹត្តអំពើសាហាវព្រៃផ្សៃលើប្រជាជនខ្លួនឯង ។ ការសម្លាប់ដ៏សាហាវឃោរឃៅនេះ បានចាត់ទុកថាជាការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរបំផុតនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ។

លើសពីនេះ អវត្តមាននៃការអនុវត្តច្បាប់បានបណ្តាលឲ្យខ្មែរក្រហមបំផ្លាញប្រទេសជាតិខ្លួនឯង ហើយអវត្តមាននៃច្បាប់នេះក៏បានបង្កជាហានិភ័យដល់ប្រជាជនកម្ពុជារួមទាំងកម្មាភិបាលខ្មែរក្រហមខ្លួនឯងផង ។ ដោយសារតែនាពេលបច្ចុប្បន្ននេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងតែស្វែងរកយុត្តិធម៌ដល់ប្រជាជនកម្ពុជា យើងតែងតែនាំគ្នាចោទសួរថាតើដំណើរការស្វែងរកយុត្តិធម៌នេះនឹងជួយសម្រេចបាននូវភាពធូរស្បើយនិងការផ្សះផ្សាដែរឬយ៉ាងណា ។

**កង់យុត្តិធម៌**

តួនាទីរបស់តុលាការគឺធ្វើការកាត់សេចក្តី មិនមែនធ្វើការសម្រុះសម្រួលថាតើជនល្មើសណាម្នាក់ពិតជាបានប្រព្រឹត្តឧក្រិដ្ឋកម្មឡើយ ។ គោលការណ៍កាត់សេចក្តីនេះទាមទារឲ្យមានការបកស្រាយនិងការពិនិត្យពិច័យលើសក្ខីកម្មនិងភស្តុតាងនិងការដាក់ទណ្ឌកម្មលើជនល្មើសឲ្យស្របទៅតាមច្បាប់ ។ នាពេលនេះ សាលាក្តីខ្មែរក្រហមបាននាំយកមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់និងជនទាំងឡាយណាដែលមានការទទួលខុសត្រូវខ្ពស់សម្រាប់ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យមកកាត់ទោស ហើយសាលាក្តីខ្មែរក្រហមក៏នឹងសង្ឃឹមថា ដំណើរការកាត់ទោសនេះនឹងបន្សល់ទុកជាកេរតំណែលផ្លូវច្បាប់ដ៏មានតម្លៃមួយសម្រាប់ប្រព័ន្ធច្បាប់របស់កម្ពុជា ។

នៅក្នុងអំឡុងអង្គជំនុំជម្រះក្តីប្រឆាំងនឹង នួន ជា, អៀង សារី, និង ខៀវ សំផន សាធារណជនទូទៅបានតាមដានដំណើរការនីតិវិធីរបស់តុលាការដោយយកចិត្តទុកដាក់ ។ ស្របពេលដែលប្រជាជនកម្ពុជាភាគច្រើនចង់ស្តាប់ពាក្យការពិតខ្លះៗចេញពីមាត់របស់មេដឹកនាំទាំងនេះ ក៏មានការព្រួយបារម្ភថាសក្ខីកម្មដែលជាមនោគមន៍វិជ្ជារបស់មេដឹកនាំទាំងនេះអាចនឹងជះឥទ្ធិពលដល់ផ្នត់គំនិតរបស់យុវជនជំនាន់ក្រោយរបស់កម្ពុជា ។ ជាញឹកញាប់ប្រជាជនទូទៅរួមទាំងកម្មាភិបាលខ្មែរក្រហមថ្នាក់ទាបបានបង្ហាញពីអារម្មណ៍មិនពេញចិត្តចំពោះមេដឹកនាំខ្មែរក្រហមដែលនៅតែបដិសេធមិនទទួលស្គាល់ការចូលរួមរបស់ខ្លួននៅក្នុងដំណើរការ



អ្នកភូមិចូលរួមសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម

ចេញសេចក្តីសម្រេចផ្សេងៗនៃរបបគ្រប់គ្រងរបស់ខ្លួនឯង ជាពិសេសគឺសេចក្តីសម្រេចអនុវត្តផែនការជម្លៀសប្រជាជនចេញពីទីក្រុងនិងទីប្រជុំជន ។

ទាក់ទងនឹងផែនការជម្លៀសប្រជាជនយើងមានភស្តុតាងយ៉ាងច្បាស់ថា នួន ជា បានព្យាយាមសង្កត់ធ្ងន់ថាខ្លួនមិនបានដឹងពីផែនការជម្លៀសនេះទេ ហើយបែរជាទម្លាក់កំហុសឲ្យ ប៉ុល ពត ដែលជាលេខាបក្សនិងលេខាភូមិភាគទៅវិញ ។ យោងតាមសក្ខីកម្មរបស់ នួន ជា វាទំនងជាថា ប៉ុល ពត និងសមាជិកខ្លះៗនៃគណៈអចិន្ត្រៃយ៍បានដឹងពីផែនការជម្លៀសនេះ ហើយចំណែកឯ នួន ជា, អៀង សារី, និង ខៀវ សំផន បែរជាមិនបានដឹងឬមិនបានទទួលដំណឹងអ្វីទាក់ទងនឹងបញ្ហានេះទាល់តែសោះ ។ លើសពីនេះ នួន ជា ថែមទាំងអះអាងថា ខ្លួនមិនសូវដឹងពីតួនាទី និងការទទួលខុសត្រូវរបស់ អៀង សារី និង ខៀវ សំផន ទេ ដោយបកស្រាយថា ប៉ុល ពត បានបង្គាប់ឲ្យ នួន ជា មិនខ្វាយខ្វល់នឹងអ្នកចេះដឹងណាៗទាំងអស់ ហើយផ្តោតតែលើការអប់រំនិងវគ្គបណ្តុះបណ្តាលរបស់កម្មាភិបាលខ្មែរក្រហមតែប៉ុណ្ណោះ ។ នួន ជា បានអាងលើហេតុផលថា កាលណោះ អៀង សារី នៅទីក្រុងប៉េកាំងប្រទេសចិន ចំណែកឯ ខៀវ សំផន មានកិច្ចការផ្សេងត្រូវបំពេញ ។ លើសពីនេះ នួន ជា បានបកស្រាយប្រាប់ចៅក្រមថា «ខ្ញុំសូមគូសបញ្ជាក់បន្ថែមជូនលោកចៅក្រម ។ ទាក់ទិននឹងបញ្ហាផ្ទៃក្នុងរបស់បក្សសមាជិកគ្រប់គ្នាគិតតែពីកិច្ចការរបស់ខ្លួនតែប៉ុណ្ណោះ ។ សម្រាប់ខ្ញុំ ខ្ញុំគិតតែពីកិច្ចការរបស់ខ្ញុំទេ ហើយខ្ញុំក៏មិនដែលសួរនាំកិច្ចការឬបញ្ហារបស់អ្នកដទៃឡើយ ។ នេះគឺជាគោលការណ៍នៃការលាក់ការណ៍សម្ងាត់ ។ សូម្បីតែក្រោយពីថ្ងៃរំដោះមក ការលាក់ការណ៍សម្ងាត់របស់បក្សនៅតែបន្តអនុវត្តរហូតមក» ។

តាមទស្សនៈទូទៅ សេចក្តីបកស្រាយរបស់ នួន ជា ទំនងជាមិនមានខ្លឹមសារអ្វីឡើយ ពីព្រោះការបកស្រាយនេះបែរជាអះអាងថាមេដឹកនាំជាន់ខ្ពស់ទាំងបីរូបនេះគ្មានជាប់ពាក់ព័ន្ធអ្វីទាំងអស់ជាមួយនឹងផែនការជម្លៀសប្រជាជន ហើយមិនបានដឹងពីកិច្ចការរបស់គ្នាទៅវិញទៅមក ។ លោក ទុយ អោម អាយុ៧០ឆ្នាំ រស់នៅស្រុកម៉ាឡៃខេត្តបាត់ដំបងមិនត្រូវបានចោទប្រកាន់នៅក្នុងសក្ខីកម្មរបស់មេដឹកនាំខ្មែរក្រហមនៅចំពោះមុខសាលាក្តីខ្មែរក្រហមឡើយ ។ អោម បានធ្វើជាយោធាបំរើចលនាខ្មែរក្រហមតាំងពីធំដឹងក្តីមក ។ គាត់បានកត់សម្គាល់ឃើញថាចម្លើយរបស់មេដឹកនាំទាំងអស់នេះមានខ្លឹមសារដាច់ដោយឡែកពីគ្នា ។ មេដឹកនាំទាំងអស់នេះបានបដិសេធថាមិនបានធ្វើការទាក់ទងគ្នាឡើយ ។

តាមទស្សនៈរបស់គាត់ មេដឹកនាំទាំងអស់នេះគឺជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នកទាំងអស់នេះគឺឋិតនៅក្នុងរង្វង់តែមួយ ។ នៅពេលដែលការធ្វើជាយោធាខ្មែរក្រហម អោម ធ្លាប់បានធ្វើជាកងការពារមេដឹកនាំទាំងបីនាក់នេះ នៅពេលមេដឹកនាំទាំងអស់នេះបានទៅទស្សនកិច្ចជំរំភៀសខ្លួនកាលពីដើមឆ្នាំ ១៩៨០ នៅក្នុងព្រំប្រទល់ប្រទេសថៃ បើទោះបីជាមេដឹកនាំទាំងនេះព្យាយាមគេចវេះពីការពិតយ៉ាងណាក៏ដោយ ក៏ អោម ជឿថាមេដឹកនាំទាំងនេះពិតជាមិនអាចគេចវេះពីការពិតបានឡើយ ។ ការសម្លាប់រង្គាលនិងអំពើប្រល័យពូជសាសន៍ ដែលប្រព្រឹត្តលើប្រជាជនកម្ពុជាមានសភាពធ្ងន់ធ្ងរណាស់ដែលមិនអាចលាក់បាំងបានឡើយ ។

ដោយឡែក អៀង សារី សូមជ្រើសរើសមិនឆ្លើយនឹងសំណួរ ឬធ្វើសក្ខីកម្មដោយផ្ទាល់ឡើយ ។ ផ្ទុយទៅវិញ អៀង សារី បានផ្តល់សិទ្ធិឲ្យមេធាវីការពារក្តីរបស់ខ្លួនឡើងតតាំងនឹងសំណួរជំនួសវិញ ។ ចំណែកឯ ខៀវ សំផន បានឡើងថ្លែងដ៏វែងស្តីពីប្រវត្តិរូបពីមុនរបស់ខ្លួនដូចជាសេចក្តីសម្រេចដ៏ស្មុគស្មាញរបស់គាត់ក្នុងការចូលរួមក្នុងចលនាកុម្មុយនីស្តនៅប្រទេសបារាំង និងចលនាកុម្មុយនីស្តនៅប្រទេសកម្ពុជានិងពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួននៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ ខៀវ សំផន បាននិយាយថា ប្រវត្តិដើមនៃការចូលរួមរបស់ខ្លួននៅក្នុងចលនាកុម្មុយនីស្តនៅប្រទេសបារាំងត្រូវបានជ្រោមជ្រែងដោយឆន្ទៈដើម្បីឯករាជ្យភាពសម្រាប់ប្រទេសកម្ពុជា ។ នៅក្នុងអំឡុងរបបសង្គមរាស្ត្រនិយម ដែលមានសម្តេច សីហនុ ជាអ្នកដឹកនាំ ខៀវ សំផន ត្រូវបានតែងតាំងឲ្យមានមុខតំណែងជាច្រើននៅក្នុងជួររដ្ឋាភិបាលជាពិសេសគឺមុខតំណែងជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ។ យ៉ាងណាមិញ ខៀវ សំផន បាននិយាយថា គាត់មិនដែលបំភ្លេចចោលនូវគោលបំណងរបស់ខ្លួនក្នុងការធ្វើកំណែទម្រង់សេដ្ឋកិច្ចរបស់ប្រទេស

កម្ពុជាឡើយ ។ ប៉ុន្មានឆ្នាំក្រោយមក គាត់ត្រូវបានបណ្តេញចេញពីមុខតំណែងដោយសារតែភាពស្រេកឃ្លាននៃអំណាចរបស់សម្តេចសីហនុ ។ ក្រោយមកទៀត គាត់បានរត់ចូលព្រៃដោយភ័យខ្លាចរដ្ឋាភិបាលចាប់ខ្លួន ដោយសារតែការបំផុសបំផុលឲ្យមានភាពចលាចលនៅសំឡូត ។ នៅក្នុងវង្វង់បក្សកុម្មុយនីស្តកម្ពុជា ខៀវ សំផន បាននិយាយថា ប៉ុល ពត ដែលជាលេខាបក្សកុម្មុយនីស្តកម្ពុជាបានតែងតាំងគាត់ជានាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិនិងជាអគ្គមេបញ្ជាការកងទ័ព ។ ខៀវ សំផន បាននិយាយបន្ថែមថា ខ្លួនមិនមានសិទ្ធិអំណាចលើកងយោធាណាមួយឡើយ ។ ជាក់ស្តែង អ្វីដែល ខៀវ សំផន ចង់គូសបញ្ជាក់គឺថា គាត់មានតែមុខតំណែងខ្ពស់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជាតែគ្មានអំណាចអ្វីទាំងអស់ ។ អាស្រ័យហេតុនេះ គាត់បានជំទាស់ថាគាត់មិនបានប្រព្រឹត្តអំពើឧក្រិដ្ឋអ្វីឡើយ ។

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមភាគច្រើនជឿថា សក្ខីកម្មរបស់មេដឹកនាំទាំងអស់នេះគឺគ្រាន់តែចង់បង្ហាញថាមេដឹកនាំទាំងនេះជាមនុស្សស្អាតស្អំ ហើយព្រួយបារម្ភថា យុវជនកម្ពុជាជំនាន់ក្រោយអាចនឹងទទួលយកឥទ្ធិពលពីសក្ខីកម្មស្តីពីជាតិនិយមនេះ ។ វាជាការពិតណាស់ថាកាលពីឆ្នាំ១៩៩៨ របទាសម្ព័ន្ធនយោបាយនិងយោធារបស់ខ្មែរក្រហមត្រូវបានរំលាយនិងចុះចូលជាមួយនឹងរដ្ឋាភិបាលថ្មី ។ ប៉ុន្តែ យើងមិនគួរបំភ្លេចនូវស្ថានភាពបំផ្លិចបំផ្លាញនៅក្នុងអំឡុងរបបខ្មែរក្រហមឡើយ ។

យ៉ាងណាមិញ សាធារណជនគួរតែដឹងពីលក្ខណៈនៃដំណើរនីតិវិធីតាមផ្លូវច្បាប់ ។ នាពេលបច្ចុប្បន្ននេះ មេដឹកនាំទាំងអស់នេះទទួលបានឱកាសបង្ហាញនិងលាតត្រដាងពីទិដ្ឋភាពប្រវត្តិសាស្ត្រជូនដល់សាធារណជនទូទៅបានដឹងៗ ។ កាលដែលថាតើសក្ខីកម្មរបស់មេដឹកនាំទាំងអស់នេះនឹងឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យដែរឬយ៉ាងណានោះ គឺទាមទារឲ្យមានការពិនិត្យពិច័យជាបន្តបន្ទាប់ថែមទៀតដោយសហព្រះរាជអាជ្ញា មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តីផងដែរ ។ ការធ្វើដូច្នេះនឹងជំរុញឲ្យមានការលាតត្រដាងពីខ្សែបណ្តាញនៃការបញ្ជាតាមរយៈឯកសារសាធារណៈឬឯកសារសរសេរដោយដៃជាដើម ។ អ្នកជំនាញផ្នែកច្បាប់ទាំងអស់នេះនឹងពិនិត្យសារឡើងវិញរាល់ភ័ស្តុតាងដែលមានទាំងអស់ ហើយនឹងសន្និដ្ឋានសម្រេចសាលក្រមដើម្បីបង្ហាញថាតើជនជាប់ចោទមានទោសឬក៏គ្មានទោស ។ នៅក្នុងអំឡុងអង្គជំនុំជម្រះក្តីដែលធ្វើឡើងកាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១១ មនុស្សចំនួនប្រាំបួននាក់ដែលមានប្រវត្តិខុសៗគ្នាបានលើកឡើងនូវអំណះអំណាងដ៏ស៊ីសង្វាក់គ្នាមួយសម្រាប់ការអនុវត្តច្បាប់ដែលមានន័យជា "គោលការណ៍ដែលបុគ្គលគ្រប់រូបត្រូវតែប្រកាន់ខ្ជាប់នូវច្បាប់ដែលឋិតនៅក្នុងយុត្តាធិការ" ។ ដូច្នេះ មេដឹកនាំជាន់ខ្ពស់ទាំងអស់នេះនឹងត្រូវបានកាត់ទោស ហើយទទួលទណ្ឌកម្ម ប្រសិនបើមេដឹកនាំទាំងអស់នេះត្រូវបានរកឃើញថាមានទោស ។ សំណុំឯកសារទាំងអស់នឹងផ្តល់ជូនសាធារណជន អ្នកស្រាវជ្រាវ សិស្សនិស្សិត និងជនដែលជាប់ពាក់ព័ន្ធជាមួយនឹងផលប៉ះពាល់ដោយសារតែការដឹកនាំប្រទេសដ៏សាហាវព្រៃផ្សៃរបស់មេដឹកនាំខ្មែរក្រហម ។

## យុត្តិធម៌ៈ តើការផ្សះផ្សាអាចសម្រេចបានដែរឬទេ?

ដូចដែលបានពិភាក្សាខាងដើម របទាសម្ព័ន្ធរបស់តុលាការនេះត្រូវបានតាក់តែងឡើងដើម្បីដាក់ទណ្ឌកម្មជនល្មើស ។ ប្រជាជនកម្ពុជាភាគច្រើនជឿថា វិធីសាស្ត្រដាក់ទណ្ឌកម្មអាចនឹងបណ្តាលឲ្យមានភាពធូរស្បើយមួយកម្រិតដែរ ។ ដូច្នេះ ដោយពន្យល់បកស្រាយថាតើការផ្សះផ្សាអាចនឹងសម្រេចបានទេ លោក ចនផល លេជឺពច បានសរសេរថា "ការផ្សះផ្សាទទួលស្គាល់តម្រូវការពេលវេលានិងទីកន្លែងដើម្បីសម្រេចបាននូវយុត្តិធម៌និងសន្តិភាពនៅពេលដែលគោលការណ៍កែប្រែជនល្មើសត្រូវបានយកមកអនុវត្តដើម្បីប្រែក្លាយអនាគតរួមគ្នាតែមួយ" ។ វិធីសាស្ត្រដើម្បីយុត្តិធម៌គួរតែយកមកអនុវត្តនៅក្នុងសង្គមក្រោយជម្លោះក្នុងករណីដែលសន្តិភាពនិងស្ថេរភាពកំពុងតែប្រឈមមុខនឹងហានិភ័យខ្ពស់ ។ បើទោះបីជាមានការព្រួយបារម្ភពីការផ្ទុះឡើងនូវសង្គ្រាមស៊ីវិលសារជាថ្មីម្តងទៀត ប្រសិនបើសាលាក្តីខ្មែរក្រហមបន្តបំពេញកិច្ចការស្វែងរកយុត្តិធម៌របស់ខ្លួនក៏ដោយ ក៏ប្រជាជនកម្ពុជានឹងនៅតែគាំទ្រចំពោះដំណើរការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមជានិច្ច ។

អ៊ី ជុន មកពីខេត្តសៀមរាបបាននិយាយថា "ប្រសិនបើបុគ្គលណាម្នាក់បានប្រព្រឹត្តខុសនោះ តុលាការកាត់ទោសតាមផ្លូវ

ច្បាប់គឺជាដំណោះស្រាយល្អបំផុត ។ យើងមិនអាចផ្សះផ្សា ឬស្រុះស្រួលគ្នាឡើយចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរដូចជាអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាដើម» ។ ស្រដៀងគ្នានេះ មាស ចាន់ណា អាយុ៥០ឆ្នាំ មកពីខេត្តកំពត បាននិយាយថា យុត្តិធម៌គឺមានសារសំខាន់បំផុតសម្រាប់សាមគ្គីភាព និងភាពរួបរួមគ្នា ពីព្រោះបុគ្គលគ្រប់គ្នាគឺមានសិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់ ។ ប៉ុន្តែ រញ៉ាញ់ បូរ៉ា ដែលជាជនជាតិភ្នង មកពីខេត្តមណ្ឌលគិរីបានសង្កត់ធ្ងន់ថា ការផ្សះផ្សាមិនអាចសម្រេចបានតែរហូតនោះទេ បើទោះបីជាតុលាការបានកាត់សេចក្តីដោយជោគជ័យក៏ដោយ ។ ខណៈពេលដែលអ្នករស់រានមានជីវិតមានទស្សនៈខុសប្លែកគ្នាទាក់ទងនឹងយុត្តិធម៌ នោះអង្គជំនុំជម្រះក្តីរបស់តុលាការអាចនឹងផ្តល់ជាគំរូផ្លូវច្បាប់ដ៏ល្អមួយសម្រាប់សង្គមកម្ពុជា ។

ដោយឡែក ហេង គាក់ ដែលជាអតីតកម្មាភិបាលខ្មែរក្រហមបានគាំទ្រវិធីសាស្ត្រយុត្តិធម៌តាមរយៈការជំនុំជម្រះក្តីប្រឆាំងមេដឹកនាំខ្មែរក្រហមដោយក្តីសង្ឃឹមថាយុវជនជំនាន់ក្រោយនឹងបានយល់ដឹងពីឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។ គាត់បាននិយាយទៀតថា ប្រសិនបើមេដឹកនាំខ្មែរក្រហមមិនព្រមនិយាយការពិត នោះសង្គមកម្ពុជានឹងទទួលរងនូវឥទ្ធិពលប៉ះពាល់បន្ថែមទៀត ។

គួរឲ្យកត់សម្គាល់ផងដែរថា ហេង គាក់ ធ្លាប់បានស្នាក់នៅផ្ទះតាម៉ុកនៅឯខេត្តតាកែវ និងបានឃើញ ខៀវ សំផន នៅទស្សនកិច្ចមន្ទីរក-៦ នៅក្បែរស្តាតអូឡាំពិកនៅទីក្រុងភ្នំពេញ ។ ទោះបីជាយ៉ាងណាក្តី គាត់សូមស្នើសុំឲ្យមេដឹកនាំខ្មែរក្រហមលាតត្រដាងពីការពិត ។ អ៊ុក ហ៊ីម ដែលមានប្តីស្លាប់នៅក្នុងរបបខ្មែរក្រហមបាននិយាយថា «ខ្ញុំចង់ឲ្យមេដឹកនាំខ្មែរក្រហមឆ្លើយនូវចម្លើយដែលស្មោះត្រង់» ។

ទស្សនៈទាំងអស់នេះបានក្រើនរំឭកដល់សាធារណជនថា អង្គជំនុំជម្រះក្តីរបស់តុលាការមិនមែនជាមជ្ឈមណ្ឌលអប់រំដែលផ្តល់ព័ត៌មានស្តីពីព្រឹត្តិការណ៍នយោបាយនិងសង្គមរបស់ប្រទេសកម្ពុជាឡើយ ។ ប៉ុន្តែអង្គជំនុំជម្រះក្តីនេះ គួរតែត្រូវបានចាត់ទុកថាជាសំណុំរឿងមួយដែលអាចលាតត្រដាងព្រឹត្តិការណ៍ច្បាប់និងប្រវត្តិសាស្ត្រល្អជាង ។ ដូច្នេះសេចក្តីថ្លែងរបស់មេដឹកនាំខ្មែរក្រហមទាំងអស់នេះបានជំរុញឲ្យសាធារណជនតាមដានដំណើរការកាត់ទោសនេះឲ្យបានជិតដល់ ។ តាមរយៈការធ្វើដូច្នេះ សាធារណជនទាំងអស់នឹងបានយល់ថាតើមេដឹកនាំខ្មែរក្រហមបានធ្វើសកម្មខុស ឬក៏ត្រូវ ។

## សេចក្តីសន្និដ្ឋាន

អង្គជំនុំជម្រះក្តីរបស់មេដឹកនាំខ្មែរក្រហមនៅតែជាតម្រូវការដ៏ចាំបាច់មួយក្នុងរយៈពេលប៉ុន្មានទសវត្សរ៍មកនេះដើម្បីលាតត្រដាងពីលក្ខណៈឧក្រិដ្ឋកម្មរបស់របបខ្មែរក្រហម ។ ប្រជាជនកម្ពុជាភាគច្រើនសង្ឃឹមថានឹងទទួលបានចម្លើយដ៏ពិតប្រាកដមួយថាតើហេតុអ្វីបានជារបបខ្មែរក្រហមបានបង្កើតគោលនយោបាយមនោគមន៍វិជ្ជានិងរចនាសម្ព័ន្ធគ្រប់គ្រងដែលបណ្តាលឲ្យមានការស្លាប់បាត់បង់ជីវិតអស់ប្រជាជនប្រមាណជិតពីរលាននាក់ ។ ចាប់តាំងពីថ្ងៃដំណើរការអង្គនីតិវិធីកាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១មក ប្រជាជនកម្ពុជាមិនទាន់បានស្តាប់នូវអ្វីដែលអ្នកទាំងអស់គ្នានេះបានរង់ចាំអស់រយៈពេលជាងបីទសវត្សរ៍នៅឡើយទេ ។ ផ្ទុយទៅវិញ មេដឹកនាំខ្មែរក្រហមទាំងបីនាក់នេះបានលើកឡើងពីប្រធានបទផ្សេងៗពីនេះ ហើយបានព្យាយាមបង្ហាញពីភាពស្អាតស្អំគោលការណ៍ជាតិនិយមនិងមាតុភូមិនិយមរបស់ខ្លួន ។ ខណៈពេលដែលមានប្រជាជនខ្លះបានព្រួយបារម្ភថា យុវជនកម្ពុជាជំនាន់ក្រោយអាចនឹងងាយទទួលយកឥទ្ធិពលដោយសីលវិធីក្នុងការនិយាយនិងមនោគមន៍វិជ្ជារបស់មេដឹកនាំខ្មែរក្រហម ប្រជាជនមួយភាគធំជឿជាក់ថាសាលាក្តីខ្មែរក្រហមមានគោលការណ៍ច្បាស់លាស់ក្នុងការបង្ហាញព្រឹត្តិការណ៍ទាំងឡាយ ដើម្បីធ្វើឲ្យជនជាប់ចោទទទួលស្គាល់កំហុសរបស់ខ្លួនដើម្បីឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមសប់អារម្មណ៍ដោយសារកង់នៃយុត្តិធម៌នេះ ។ ស្របពេលជាមួយគ្នានេះ សាលាក្តីខ្មែរក្រហមមិនមែនជាមជ្ឈមណ្ឌលអប់រំបុព្យាបាលដែលមនុស្សគ្រប់រូបគួរតែទទួលបាន ឬទទួលស្គាល់ដោយសក្ខីកម្មជាបន្តបន្ទាប់របស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទាំងអស់នោះទេ ។ ខណៈពេលដែលសាលាក្តីខ្មែរក្រហមត្រូវបានតាក់តែងឡើងដើម្បីធានាថាច្បាប់ត្រូវបានអនុវត្តតាមដោយពេញលេញសាលាក្តីខ្មែរក្រហមនេះក៏អាចនឹងផ្តល់ជាមូលដ្ឋានគ្រឹះដ៏មាំមួយសម្រាប់ការផ្សះផ្សា ។

**លី សុខឃាង**

# ការពិនិត្យមើលសារឡើងវិញលើការចរចារឆ្ពោះទៅរកការបង្កើតយុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

***(តពីលេខមុន)***

***អ្នកជំនាញមួយក្រុមនិងការចូលរួមពាក់ព័ន្ធរបស់សហរដ្ឋអាមេរិក***

*នៅពេលដែលអ្នកជំនាញមួយក្រុម និងសហរដ្ឋអាមេរិក ចូលរួមពាក់ព័ន្ធក្នុងការសិក្សាលើគោលបំណងក្នុងការបង្កើតតុលាការខ្មែរក្រហមនេះ យន្តការអង្គការសហប្រជាជាតិដែលចាប់ផ្តើមដំណើរការក្រោយពីលិខិតមួយរបស់សហនាយករដ្ឋមន្ត្រីទាំងពីរផ្ញើទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ កំពុងតែដំណើរការទៅមុខ និងដើម្បីរកដំណោះស្រាយទៅនឹងបញ្ហាពីរដែលបង្កឡើងដោយព្រឹត្តិការណ៍ជាច្រើននៅកម្ពុជាដូចជា តើនរណានឹងត្រូវយកមកកាត់ទោស ហើយបើយកមកកាត់ទោសតើនឹងត្រូវប្រើប្រាស់យុត្តាធិការអ្វី? ទាក់ទងទៅនឹងយុត្តាធិការបុគ្គល មានសំណួរជាច្រើននឹងសួរថាតើនរណាជាមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ តើ ម៉ុក និងត្រូវយកមកកាត់ទោសដែរឬទេ? ហើយថាតើ ឌុច និងអ្នកផ្សេងទៀតដែលមិនត្រូវបានចាត់ទុកជាមេដឹកនាំអាចយកមកទទួលខុសត្រូវតាមផ្លូវច្បាប់បានដែរឬទេ?*

*ទាក់ទងទៅនឹងទីកន្លែងរបស់តុលាការ សំណួរគឺថាតើសម្តេច ហ៊ុន សែន នៅតែត្រៀមរកមើលនៅតុលាការអន្តរជាតិ ឬថាតើគាត់បានប្តូរតុលាការនេះទៅតុលាការកម្ពុជាវិញ ឬតុលាការចម្រុះ ។ ទាក់ទងនឹងតុលាការកម្ពុជា យើងអាចនិយាយបានថាសម្តេច ហ៊ុន សែន បានបោះបង់ចោលគោលជំហរដើម្បីបំពេញតម្រូវការតុលាការអន្តរជាតិដូចដែលត្រូវបានជម្រុញដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា របបរដ្ឋកម្ពុជា និងរបបក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ រហូតដល់ឆ្នាំ១៩៩៨ ។ ប៉ុន្តែ បើតាមអ្វីដែល នួន ជា និង ខៀវ សំផន បានស្នើទៅរាជរដ្ឋាភិបាលកម្ពុជា ជំហរដែលបានបញ្ជាក់ជា សាធារណៈ នោះហាក់ដូចជាស៊ីគ្នាត្រង់ថា តុលាការត្រូវតែជាតុលាការកម្ពុជា ដែលអាចមានការចូលរួមពីអន្តរជាតិ ។ ទីបញ្ចប់ ជាលទ្ធផលគឺបង្កើតឲ្យមានកិច្ចព្រមព្រៀងមួយដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលមានជំនួយពីអង្គការសហប្រជាជាតិ ។ ប្រាសមកវិញ នាយករដ្ឋមន្ត្រី ហ៊ុន សែន មានការស្ទាក់ស្ទើរក្នុងការកាត់ទោស អៀង សារី, អៀង ធីរិទ្ធ, នួន ជា, ខៀវ សំផន, កែ ពក និង ម៉ុក និងមន្ត្រីរដ្ឋាភិបាលកម្ពុជាផ្សេងទៀតដែលមានតំណែងនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។*

*មិនមានការជំទាស់ទៅនិងការយក ឌុច មកកាត់ទោសទេ ។ ហេតុការណ៍នោះប្រែជាក្រឡាប់ចាក់មកវិញថា មានបញ្ហាចម្រូងចម្រាសច្រើនជាងមុនត្រង់ថាក្រៅពី ឌុច គឺមានអ្នកផ្សេងដែលមានឈ្មោះនៅក្នុងបញ្ជីដើមរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ទាំងប្រាំបីនាក់ដែលជាមេក្លោងសំខាន់ ។ បញ្ហាត្រង់ថា តើមេក្លោងទាំងអស់នោះអាចចាត់ថ្នាក់ចូលទៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬអត់ហើយចំពោះអ្នកដែលជាមេដឹកនាំខ្មែរក្រហមថ្នាក់កណ្តាលក្រោយឆ្នាំ១៩៧៩ អាចយកមកកាត់ទោសបានដែរឬទេ ។ តាមខ្លឹមសារនៅក្នុងលិខិតរបស់សហនាយករដ្ឋមន្ត្រីទាំងពីរកាលពីខែមិថុនា ឆ្នាំ១៩៩៧ តំណាងពិសេសរបស់អង្គការសហប្រជាជាតិ ថូម៉ាស់ ហាំម៉ាបើក បានផ្តល់អនុសាសន៍ទៅកាន់សភាអង្គការសហប្រជាជាតិថា អគ្គលេខាធិការអង្គការសហប្រជាជាតិបានតែងតាំងអ្នកជំនាញមួយក្រុមដើម្បីវាយតម្លៃភ័ស្តុតាងដែលមានទាក់ទងនិងការទទួលខុសត្រូវចំពោះការរំលោភបំពានសិទ្ធិមនុស្សរបស់ខ្មែរក្រហម ។ សេចក្តីសម្រេចរបស់សភាអង្គការសហប្រជាជាតិថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩៧ គឺដើម្បីឆ្លើយតបទៅនឹងលិខិតរបស់កម្ពុជានិងគាំទ្រដល់អនុសាសន៍របស់ ថូម៉ាស់ ហាំម៉ាបើក ។ សេចក្តីសម្រេចនោះសម្រេចថា ការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរបំផុតនៅក្នុងប្រទេសកម្ពុជានៅក្នុងប្រវត្តិសាស្ត្រថ្មីៗនេះត្រូវបានប្រព្រឹត្តឡើងដោយ*

ខ្មែរក្រហម ហើយសេចក្តីសម្រេចនោះក៏សម្តែងការព្រួយបារម្ភថា គ្មានមេដឹកនាំខ្មែរក្រហមណាម្នាក់ត្រូវបាននាំទៅរកការទទួលខុសត្រូវពីបទឧក្រិដ្ឋទាំងអស់នេះនៅឡើយទេ ។ សេចក្តីសម្រេចនោះដែរបានប្រកាសថា ត្រូវតែមានតម្រូវការចាំបាច់ដើម្បីដោះស្រាយបញ្ហានេះ គឺការទទួលខុសត្រូវបុគ្គលសម្រាប់មេដឹកនាំទាំងអស់ ។

ក្នុងការណែនាំអំពីទស្សនៈទូលំទូលាយរបស់មេដឹកនាំចូលទៅក្នុងលក្ខណៈច្បាប់ដោយគ្មានបញ្ជាក់អំពីអត្ថន័យនៃពាក្យនោះ សេចក្តីសម្រេចនោះបានអះអាងថា ការផ្តោតទៅលើក្រុមអ្នកជំនាញដែលបានស្នើនោះគឺគួរតែឋិតនៅក្នុងឋានៈនៃកម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ។ នៅក្នុងរបាយការណ៍កាលពីខែធ្នូ ឆ្នាំ១៩៩៨ ផ្ញើទៅកាន់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ លោក ថូម៉ាស់ ហាំម៉ារប៊ើក បានសង្កត់ធ្ងន់ថា វិសាលភាពនៃការទទួលខុសត្រូវរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាត្រូវតែបញ្ជាក់ឲ្យច្បាស់តាមផ្លូវច្បាប់ដើម្បីឲ្យដឹងថាតើមេដឹកនាំទាំងនោះគឺជាអ្នកដែលទទួលខុសត្រូវនៃអំពើរំលោភជាទូទៅដែរឬទេ ។ ដូច្នេះ ការបញ្ជាក់ឲ្យច្បាស់ពីទស្សនៈដ៏ទូលំទូលាយនៃថ្នាក់ដឹកនាំឲ្យចូលទៅក្នុងផ្នែកច្បាប់ដោយមិនបានបញ្ជាក់ពីអត្ថន័យនៃពាក្យនេះ ។ សេចក្តីសម្រេចបានស្នើថា ការផ្តោតរបស់ក្រុមអ្នកជំនាញដែលបានស្នើគឺថា មេដឹកនាំជាន់ខ្ពស់គួរតែជាជនដៃដល់របស់បក្សកុម្មុយនីស្តកម្ពុជា ។ នៅក្នុងរបាយការណ៍កាលពីខែកុម្ភៈ ឆ្នាំ១៩៩៨ ទៅកាន់គណៈកម្មាធិការសិទ្ធិរបស់អង្គការសហប្រជាជាតិ លោក ថូម៉ាស ហាំម៉ារប៊ើក បានសង្កត់ធ្ងន់ថា និយមន័យនៃការទទួលខុសត្រូវរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាត្រូវតែបញ្ជាក់ឲ្យច្បាស់តាមផ្លូវច្បាប់ដើម្បីធ្វើឲ្យប្រាកដថាអ្នកទាំងនោះគឺជាអ្នកទទួលខុសត្រូវក្នុងអំពើរំលោភសិទ្ធិមនុស្សទូទាំងប្រទេសកម្ពុជាដែរឬទេ ។ ពេលជាមួយគ្នានោះដែរ ក៏ត្រូវមានការស៊ើបអង្កេតបន្ថែមទៀតអំពីអំពើឃោរឃៅដែលអ្នកទាំងអស់នោះបានធ្វើគឺជនដែលរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុតដើម្បីយកមកកាត់ទោស ។ នៅក្នុងរបាយការណ៍នោះដែរ ថូម៉ាស់ ហាំម៉ារប៊ើក បានបន្ថែមថា គាត់មានជំនឿថា មេដឹកនាំខ្មែរក្រហមកាលពីអតីតកាល ឬមេដឹកនាំខ្មែរក្រហមនាពេលបច្ចុប្បន្ននេះមិនគួរត្រូវបានអនុញ្ញាតឲ្យចូលប្រឡូកក្នុងជួរនយោបាយទេ បើសិនជាមានភ័ស្តុតាងបង្ហាញថា អ្នកទាំងនោះមានជាប់ទាក់ទងនិងឧក្រិដ្ឋកម្មដ៏ធំណាមួយ ។ សេចក្តីសម្រេចរបស់រដ្ឋសភាជាតិកម្ពុជាដែលបានសម្រេចមួយសប្តាហ៍ក្រោយមកបាននិយាយភាសាស្រដៀងគ្នានេះដែរនៅខែធ្នូ ឆ្នាំ១៩៩៧ ដោយបានបញ្ជាក់ឡើងវិញម្តងទៀតថា គ្មានមេដឹកនាំណាម្នាក់នឹងត្រូវនាំទៅកាន់តុលាការពីបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទេ ខណៈពេលដែលមានការបញ្ជាក់ឡើងវិញនូវសំណើរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិដើម្បីឆ្លើយតបទៅនិងលិខិតកាលពីខែមិថុនា ឆ្នាំ១៩៩៧ ដោយតែងតាំងក្រុមអ្នកជំនាញមួយក្រុមដែលស្នើដោយ ថូម៉ាស់ ហាំម៉ារប៊ើក ដើម្បីវាយតម្លៃភ័ស្តុតាងដែលនៅមានរូបរាង និងដើម្បីស្នើឲ្យមានការចាត់វិធានការណ៍បន្ថែមទៀតដើម្បីដោះស្រាយទៅនឹងការទទួលខុសត្រូវតាមផ្លូវច្បាប់ជាលក្ខណៈបុគ្គល ។

ក្នុងខែមេសា ឆ្នាំ១៩៩៨ សហរដ្ឋអាមេរិកបានឈានជើងចូលក្នុងឈុតឆាកដោយភាពអង់អាចដោយស្នើឲ្យបង្កើតរូបមន្តថ្មីមួយទៀតដើម្បីជាវិធីដោះស្រាយតាមវិធីមួយទៀតដោយបញ្ជាក់ពីការកាត់ទោសនាពេលអនាគតនៅពេលដែលអាមេរិកពង្រាងកិច្ចព្រមព្រៀងរបស់ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិទាក់ទងទៅនឹងលទ្ធភាពក្នុងការបង្កើតតុលាការអន្តរជាតិមួយសម្រាប់ប្រទេសកម្ពុជា ដោយបញ្ជាក់អំពីទម្រង់ការទូតដែលថា គោលបំណងនៃការបង្កើតតុលាការអន្តរជាតិនេះគឺដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដោយមិនកំណត់ និងមិនបានបង្ហាញឈ្មោះដែលធ្លាប់មានគម្រោង និងធ្លាប់ប្រព្រឹត្តការរំលោភបទល្មើសធ្ងន់ធ្ងរចំពោះច្បាប់សិទ្ធិមនុស្សនិងច្បាប់អន្តរជាតិដែលបានប្រព្រឹត្តនៅប្រទេសកម្ពុជាចន្លោះខែមេសា ឆ្នាំ១៩៧៥ និងខែមករា ឆ្នាំ១៩៧៩ ដោយដាក់មេដឹកនាំទាំងអស់នេះចូលទៅក្នុងតុលាការអន្តរជាតិ ។ ច្បាប់នេះកំណត់ច្បាស់ថា មានតែមេដឹកនាំជាក់លាក់ណាមួយក្នុងចំណោមអ្នកដែលបានទទួលខុសត្រូវទាំងអស់នេះទេទើបនិងត្រូវយកមកកាត់ទោស ។ ច្បាប់ដែលបានពង្រាងនេះបានភ្ជាប់នូវលក្ខន្តិកៈដើម្បីឲ្យមានការបង្កើតតុលាការមួយដែលបានស្នើដោយបញ្ជាក់ម្តងទៀតពីអំណាចនៃការកាត់ទោស ។ ចំណុចនេះបង្កឲ្យមានការតវ៉ាប្រឆាំងពីក្រុមសិទ្ធិមនុស្សរបស់អង្គការក្រៅរដ្ឋាភិបាលដែលបានលើកឡើងថា គ្មានមូលដ្ឋាន

ក្នុងច្បាប់ឬការអនុវត្តជាអន្តរជាតិណាមួយសម្រាប់ដាក់កំណត់នៃការកាត់ទោសនៅក្នុងស្ថានភាពបែបនេះទេ ។ ក្រុមសិទ្ធិមនុស្សរបស់អង្គការក្រៅរដ្ឋាភិបាលបានប្រានចោលនូវការបង្កើតតុលាការសម្រាប់បុគ្គលដែលមិនឋិតនៅក្នុងជួរថ្នាក់ដឹកនាំ ប៉ុន្តែបានប្រព្រឹត្តបទល្មើសដ៏ធ្ងន់ធ្ងរ ។

ប៉ុន្តែ សហរដ្ឋអាមេរិកហាក់បីដូចជាមិនចង់ទទួលខុសត្រូវទាំងស្រុង ដូចដែលមាត្រា៨ដែលបានព្រាងបានបញ្ជាក់ថា អ្នកផ្សេងដែលមានគម្រោងបង្កើតបញ្ជា ប្រព្រឹត្តឬជួយ និងជួយនរណាម្នាក់ឲ្យប្រព្រឹត្តបទល្មើសនៅក្នុងគម្រោងការរៀបចំ ឬអំពើកាប់សម្លាប់នៃបទឧក្រិដ្ឋណាមួយអាចនឹងដាក់ឲ្យមានការទទួលខុសត្រូវជាលក្ខណៈបុគ្គល រួមទាំងអ្នករួមគំនិតដែលធ្វើតាមបញ្ជាមេដឹង ។ ស្រដៀងគ្នានោះដែរ ទោះបីជាមាត្រា១៧ និង១៩ អះអាងថា ព្រះរាជអាជ្ញាអាចនិងចោទប្រកាន់តែមេដឹកនាំជាន់ខ្ពស់ប៉ុណ្ណោះក៏ដោយ ក៏ព្រះរាជអាជ្ញាអាចស្នើររកការចោទប្រកាន់ដោយធ្វើការស៊ើបអង្កេតកម្មាភិបាលថ្នាក់ក្រោមបន្ថែមទៀតដើម្បីឲ្យដឹងពីការចូលពាក់ព័ន្ធរបស់កម្មាភិបាលថ្នាក់ក្រោមទាំងនោះ ។

ចំណែកឯអង្គការសហប្រជាជាតិ ក៏បានបកស្រាយពង្រាងនោះក្នុងអត្ថន័យថា តាមការអនុវត្ត សហរដ្ឋអាមេរិកប្រមើឃើញការកាត់ទោសនោះត្រឹមតែថ្នាក់ដឹកនាំជាន់ខ្ពស់របស់របបខ្មែរក្រហមប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀត សហរដ្ឋអាមេរិកក៏មានក្តីរំពឹងថា ការទទួលយករបស់ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិចំពោះភាសានេះគឺជាមូលដ្ឋាននៃវិសាលភាពនៃការកាត់ទោសយ៉ាងទូលំទូលាយមួយចំពោះខ្មែរក្រហមក្នុងជួរដឹកនាំ ។ សហរដ្ឋអាមេរិកបានពន្យល់ទៅអង្គការសហប្រជាជាតិ ដោយភាពឃើតយ៉ាវថា ខ្លួនមានជំនឿថា ការដែលនាយករដ្ឋមន្ត្រី ហ៊ុន សែន ព្យាយាមទប់ទល់ក្នុងការបង្កើតសាលាក្តីខ្មែរក្រហម ដោយសារតែក្តីបារម្ភខ្លាចបង្កអស្ថិរភាពផ្នែកនយោបាយធ្លាក់មកលើគាត់ បើសិនជាគាត់យល់ស្របឲ្យមានការបង្កើតតុលាការ ដោយស្ម័គ្រចិត្តជាការចាំបាច់សម្រាប់ក្រុមប្រឹក្សាសន្តិសុខដើម្បីមានសមត្ថភាពចំពោះរឿងនេះក្នុងគោលបំណងបង្ខំឲ្យមានការបង្កើតសាលាក្តីខ្មែរក្រហមដោយកាត់ទោសមេដឹកនាំកំពូលរបស់ខ្មែរក្រហម ។ ហើយពេលនោះ នាយករដ្ឋមន្ត្រី ហ៊ុន សែន និងអាចនិយាយថា គាត់គ្មានជម្រើសអ្វីទាំងអស់ គឺត្រូវតែបណ្តោយឲ្យមានការបង្កើតតុលាការនេះ ហើយចំណុចនេះ និងបង្កឲ្យមានការស៊ើបអង្កេតជាលក្ខណៈទូលំទូលាយមួយនៅក្នុងប្រទេស ។

នៅគ្រានោះដែរ បុព្វបទនៃកិច្ចសន្ទនាជាមួយ ថូម៉ាស់ ហាំម៉ាប៊ើក ក្នុងខែមេសា-ឧសភា ឆ្នាំ១៩៩៨ អំពីវិធានការដើម្បីឆ្លើយតបទៅនឹងលិខិតកាលពីខែមិថុនា ឆ្នាំ១៩៩៧ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានស្វាគមន៍គំនិតរបស់ក្រុមអ្នកជំនាញដោយបានបញ្ជាក់ថា ជាការចាំបាច់ណាស់ដែលមេដឹកនាំខ្មែរក្រហមត្រូវនាំទៅកាន់តុលាការយុត្តិធម៌នាទីបញ្ចប់ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយពីគម្រោងក្នុងការចាប់ខ្លួន "អ្នកទាំងបី" ដែល ថូម៉ាស់ ហាំម៉ាប៊ើក យល់ពីបំណងរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ថាគឺសំដៅទៅលើមេដឹកនាំបីនាក់ក្នុងចំណោមឈ្មោះទាំងប្រាំបីនាក់នៅក្នុងបញ្ជីរបស់គាត់គឺ នួន ជា, ម៉ុក និង ខៀវ សំផន ។ ចំពោះ អៀង សារី វិញ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានទទូចថា ការអភ័យទោស និងការលើកលែងទោសដែលបង្កើតឡើងមិនបានការពារខ្លួនគាត់ពីការកាត់ទោសពីអំពើប្រល័យពូជសាសន៍នាពេលអនាគតទេ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយដែរថា គាត់បានបញ្ចុះបញ្ចូល អៀង សារី ថា បើសិនជាតុលាការកើតឡើង គាត់នៅតែអាចយកទៅកាត់ទោសបាន ។ ចំណុចហាក់បីដូចជាបង្ហាញថា អៀង សារី គឺជាជនសង្ស័យទីបួនដែលឋិតនៅក្នុងជួរថ្នាក់ដឹកនាំ ឬមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមដូចទៅនឹងអ្វីដែលអង្គការសហប្រជាជាតិ និងសហរដ្ឋអាមេរិកបានបកស្រាយដែរ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានពន្យល់ថា គាត់ក៏មានក្តីបារម្ភដែរថា ខណៈពេលដែលគាត់កំពុងបញ្ចុះបញ្ចូលមេដឹកនាំឲ្យទម្លាក់អាវុធ និងពិភាក្សាអំពីការកាត់ទោសមេដឹកនាំខ្មែរក្រហមក៏អាចនិងបង្អាក់ទឹកចិត្តសមាជិករបស់ខ្មែរក្រហមផ្សេងទៀតក្នុងការចុះចូលជាមួយរដ្ឋាភិបាលដែរ ។ ចំណុចនេះហាក់បីដូចជាបើកទ្វាចំហក្នុងការពង្រីកវិសាលភាពនៃការកាត់ទោសក្រោយពេលគោលនយោបាយសមាហរណកម្មសម្រេចបាន ។ អំឡុងពេលនៃការពិភាក្សាពីបញ្ហានេះបន្តទៀតជាមួយនាយករដ្ឋមន្ត្រី ហ៊ុន សែន និងថ្នាក់ដឹកនាំកម្ពុជាដទៃទៀតនៅក្នុងប្រទេសកម្ពុជា ថូម៉ាស់ ហាំម៉ាប៊ើក បានកត់សម្គាល់ថា ហាក់បីដូចជាឈានដល់ដំណាក់កាល

យោគយល់គ្នាទូទៅមួយថា មានតែមេដឹកនាំជាន់ខ្ពស់ និងថ្នាក់ដឹកនាំដែលត្រូវបានដឹងជាទូទៅថាជាអ្នកសម្លាប់និងបានធ្វើទារុណកម្មដ៏សាហាវប៉ុណ្ណោះទើបយកមកកាត់ទោស ។

ផ្អែកពីគំនិតខាងលើនេះ ការិយាល័យកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិ និង ថូម៉ាស់ ហាំម៉ាប៊ើក បានចាត់ទុកថាអាណត្តិរបស់ក្រុមអ្នកជំនាញគួរតែនៅខែមិថុនា ឬ ខែកក្កដា ឆ្នាំ១៩៩៨នេះ ។ នៅក្នុងពង្រាងកិច្ចព្រមព្រៀងដំបូងបានបញ្ជាក់ថា កិច្ចព្រមព្រៀងនោះគឺបញ្ជាក់តែលើអត្តសញ្ញាណនិងទីកន្លែងដែលមេដឹកនាំខ្មែរក្រហមរស់នៅ ។ ក្រោយមក ក៏មានការអំពាវនាវដើម្បីវាយតម្លៃចំនួនមេដឹកនាំខ្មែរក្រហមដែលនឹងប្រឈមមុខនឹងការកាត់ទោស និងបង្ហាញពីអត្តសញ្ញាណរបស់មេដឹកនាំទាំងអស់នោះ ។ ចំណុចនេះក្លាយជាមានសារសំខាន់ពីព្រោះខណៈពេលដែលចំនួនពិតប្រាកដឬអត្តសញ្ញាណនៃអ្នកដែលនឹងទទួលខុសត្រូវចំពោះបទឧក្រិដ្ឋមិនអាចបង្ហាញជាមុន ចំនួនដែលបានប៉ាន់ប្រមាណ និងអត្តសញ្ញាណដែលប៉ាន់ស្មានទុកអាចជាកត្តាក្នុងការណែនាំក្នុងការកំណត់ប្រភេទនៃដូវច្បាប់ ។ ប៉ុន្តែ ក្តីបារម្ភក៏បានលើកឡើងដែលស្នើទៅអ្នកជំនាញឲ្យកំណត់ពីអត្តសញ្ញាណរបស់មេដឹកនាំខ្មែរក្រហមអាចនឹងបង្កឲ្យមានប្រតិកម្មពីរាជរដ្ឋាភិបាលកម្ពុជា ។ មានការស្នើថា អាណត្តិរបស់ក្រុមអ្នកជំនាញគ្រាន់តែដើម្បីបញ្ជាក់ពីចំនួនរបស់មេដឹកនាំខ្មែរក្រហមដែលនឹងត្រូវយកមកកាត់ទោសតែប៉ុណ្ណោះ នៅពេលដែលមានការបញ្ជាក់អំពីវិសាលភាពនៃការកំណត់ជនសង្ស័យនៅក្នុងជួរខ្មែរក្រហមតាមឋានន្តរសក្តិ ។ ក្រោយមក មានការផ្តល់ជាអនុសាសន៍មួយ ដើម្បីបញ្ឈប់នូវការតាំងបង្ហាញពីអត្តសញ្ញាណឬចំនួនរបស់ជនសង្ស័យដែលនិងត្រូវយកមកកាត់ទោសដើម្បីធ្វើឲ្យប្រាកដបន្ថែមទៀតថា មិនត្រូវបង្កឲ្យមានការប៉ះពាល់ស្ថេរភាពផ្នែកនយោបាយដល់រដ្ឋាភិបាលកម្ពុជាទេ ។ ដោយមិនគិតពីការប្រើប្រាស់ភាសាថាច្បាស់ឬយ៉ាងណាទេ ថូម៉ាស់ ហាំម៉ាប៊ើក បានធ្វើការប៉ាន់ប្រមាណថា នួនជា, ម៉ុក, អៀង សារី, ខៀវ សំផន និង ឌុច ទំនងជានឹងត្រូវយកមកកាត់ទោស ។

នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៨ អគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ បានបង្កើតរូបមន្តដែលប្រកបដោយភាពប្រយ័ត្នប្រយែងជាទីបំផុតដែលកំណត់អាណត្តិដល់ក្រុមអ្នកជំនាញៈ

១) ដើម្បីវាយតម្លៃភ័ស្តុតាងដែលមានស្រាប់ក្នុងទស្សនៈដើម្បីសិក្សាអំពីបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងដោយមេដឹកនាំខ្មែរក្រហមក្នុងអំឡុងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។

២) ដើម្បីធ្វើការវាយតម្លៃអំពីលទ្ធភាពក្នុងការនាំយកមេដឹកនាំខ្មែរក្រហមទៅរកយុត្តិធម៌ និងការចោទប្រកាន់ទោសការឃុំខ្លួន និងការធ្វើបត្យាប័ន ឬការចុះចាញ់ចំពោះយុត្តាធិការឧក្រិដ្ឋកម្មដែលបានបង្កើតឡើងក្រោយពីពិគ្រោះយោបល់ជាមួយរដ្ឋាភិបាលរួចហើយ ។

៣) ដើម្បីរកមើលជម្រើសផ្សេងទៀតក្នុងការនាំយកមេដឹកនាំខ្មែរក្រហមទៅរកភាពយុត្តិធម៌នៅចំពោះមុខយុត្តាធិការជាតិនិងអន្តរជាតិ ។

ក្រុមអ្នកជំនាញដែលក្នុងនោះរួមមានចៅក្រម ស៊ីនៀន ស្ទីហ៊ិន និងចៅក្រម រ៉ាចស៊ូមើ ឡាឡូះ និងសាស្ត្រាចារ្យច្បាប់ម្នាក់ ស៊ីវិន រ៉ាត់នើ ។ ក្រៅពីអ្នកទាំងបីខាងលើនេះ ក៏មានអ្នកជំនាញផ្សេងទៀត ជាច្រើនដែរមានដូចជាលោក ដេវីដ អាស្ហី ដែលធ្លាប់បម្រើការជាទីប្រឹក្សារបស់ក្រុមអ្នកជំនាញអំពីបញ្ហាកម្ពុជា និងបញ្ហាខ្មែរក្រហម ហើយគាត់ធ្លាប់ធ្វើការនៅក្នុងការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា ។ ដើម្បីត្រៀមក្នុងការធ្វើទស្សនកិច្ចមកកាន់ប្រទេសកម្ពុជារបស់ក្រុមអ្នកជំនាញនៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៩ សមាជិកក្រុមម្នាក់គឺ ស៊ីវិន រ៉ាត់នើ ដែលធ្លាប់ដឹងយ៉ាងច្រើនទាក់ទងនិងភ័ស្តុតាងបានបង្កើតអនុស្សរណៈមួយដែលមើលទៅហាក់បីដូចជាបកស្រាយទស្សនៈនៃមេដឹកនាំរួមគ្នាដោយមិនដឹងថាបានធ្វើខុស ។ រ៉ាត់នើ បានកត់សម្គាល់ឃើញថា អំពើឃោរឃៅរបស់ខ្មែរក្រហមត្រូវបានប្រព្រឹត្តឡើងដោយមនុស្សជាច្រើនគ្រប់ជំពូករបស់រដ្ឋាភិបាល ។ គាត់បានបញ្ជាក់ថា មេដឹកនាំដែលបញ្ជាឲ្យមានអំពើឃោរឃៅ ឬក៏ដឹងថាអំពើឃោរឃៅកំពុងកើតឡើងឬហៀបនឹងកើតឡើងដោយមនុស្សនៅក្រោមបង្គាប់ ហើយមិនបានធ្វើការទប់ស្កាត់បញ្ឈប់ ឬដាក់ទណ្ឌកម្មអ្នកដែលប្រព្រឹត្តនិងត្រូវយកមកកាត់ទោស ប៉ុន្តែលទ្ធភាពដែលអាចយកមកកាត់ទោសបាននោះមិនមែនធ្វើឡើងដោយស្មានៗទេ គឺត្រូវតែមានភ័ស្តុតាងច្បាស់លាស់ ។ រ៉ាត់នើ

បានសង្កត់ធ្ងន់ថា សម្រាប់អ្នកដែលនៅក្រោមបង្គាប់ មិនអាចនឹងធ្វើការការពារខ្លួនឯងដោយតវ៉ាថាអ្វីដែលអ្នកទាំងនោះធ្វើគឺធ្វើក្រោមការបង្ខិតបង្ខំទេ ឬក៏មិនបានយល់ពីការបញ្ជាក្នុងការប្រព្រឹត្តបទល្មើសនោះថាជារឿងមិនស្របច្បាប់នោះទេ ។ សហរដ្ឋអាមេរិកមានជំនឿថា អង្គការសហប្រជាជាតិចង់ឲ្យមានការកាត់ទោសលើសពីមេដឹកនាំជាន់ខ្ពស់និងកំណត់ទិសដៅដល់ថ្នាក់ដឹកនាំថ្នាក់កណ្តាលទៀត ឬក៏អ្វីមួយដែលសក្តិសមទៅនឹងទស្សនៈនៃគោលបំណងរបស់ខ្លួន ។ សញ្ញាណដ៏ទូលំទូលាយនៃអ្នកដឹកនាំគឺស្ថិតនៅក្នុងជួរជាមួយនិងការពិតថា នៅក្នុងការឆ្លើយតបទៅពេលនេះរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងទៅនឹងស្ថានភាពនយោបាយនាពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាដែលឲ្យនិយមន័យថាជាថ្នាក់ដឹកនាំនយោបាយរួមបញ្ចូលទាំងសមាជិកទាំងអស់របស់សភាជាតិ មិនថាអ្នកទាំងនោះមានតំណែងនៅក្នុងរដ្ឋបាលស៊ីវិលឬនៅក្នុងកងយោធារបស់ជាតិក៏ដោយ ។

ក្នុងអំឡុងពេលបេសកកម្មស្វែងរកការពិតនៅក្នុងប្រទេសកម្ពុជារបស់អ្នកជំនាញកាលពីខែវិច្ឆិកា ពាក្យថា "មេដឹកនាំ" និងភាសាដែលមានភាពខុសប្លែកគ្នារវាងកម្រិតរបស់កម្មាភិបាលនៅក្នុងជួរដឹកនាំបក្សកុម្មុយនីស្តកម្ពុជាគឺមិនទាន់ឈានដល់ការសម្រេចអំពីនិយមន័យឲ្យច្បាស់នៅឡើយទេ ប៉ុន្តែអង្គការសហប្រជាជាតិគឺជាអ្នកបង្កើតនូវភាពខុសប្លែកគ្នាជាលើកដំបូងចំពោះអត្ថន័យនៃពាក្យ "មេដឹកនាំ" នេះ ដោយបញ្ជាក់ថា មេដឹកនាំកម្រិតទីពីរបន្ទាប់ពីមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមគឺជាបេក្ខជនក្នុងការយកមកកាត់ទោស ។ នៅក្នុងវេទិការបស់រាជរដ្ឋាភិបាលកាលពីខែវិច្ឆិកា ឆ្នាំ១៩៩៨ បានបង្ហាញថា រដ្ឋាភិបាលមានគោលបំណងថា មេដឹកនាំដែលជាសមាជិករបស់ខ្មែរក្រហមនៅក្រោមច្បាប់នឹងត្រូវយកទៅកាត់ទោស ។ កិច្ចពិភាក្សារវាងក្រុមអ្នកជំនាញ និងនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺត្រូវនាំយកទៅកាន់យុត្តិធម៌នូវជនទាំងឡាយណាដែលជាមេដឹកនាំខ្មែរក្រហម ហើយនៅក្នុងចំណុចនេះនាយករដ្ឋមន្ត្រី ហ៊ុន សែន បញ្ជាក់ថា សំណួរដែលថានរណាខ្លះនឹងត្រូវចាប់ខ្លួននឹងត្រូវសម្រេចឡើងដោយតុលាការ ។ ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ខេណិត ឃ្វីន បានបញ្ជាក់ទៅកាន់ក្រុមអ្នកជំនាញថា ដើម្បីជៀសផុតពីភាពប្រថុយប្រថានក្នុងការវាយប្រយុទ្ធគ្នាឡើងវិញក្នុងទ្រង់ទ្រាយធំបើសិនជាការចាប់ខ្លួនក្នុងលក្ខណៈទ្រង់ទ្រាយធំកើតឡើង តុលាការគួរតែផ្តោតទៅលើចំនួនដ៏តិចតួចរបស់មេដឹកនាំត្រឹម៧-៩នាក់បានហើយ ដែលក្នុងចំណោមនោះក៏មានរួមចំណែកនៅក្នុងគណបក្សនយោបាយដែរ (តា ម៉ុក, ខៀវ សំផន និងមេដឹកនាំផ្សេងទៀត) ខណៈពេលដែលមានការចង្អុលបង្ហាញថា គណបក្សហ៊ុនស៊ិនប៉ិចចង់ឲ្យមានការនាំយកមេដឹកនាំច្រើននាក់ទៅកាន់តុលាការ ។ ឯកអគ្គរដ្ឋទូត ខេណិត ឃ្វីន បានអះអាងថា បើសិនជាដំណើរការកាត់ទោសមិនកំណត់ចំនួនរបស់មេដឹកនាំខ្មែរក្រហមទេ នោះទំនងនឹងមានផលប៉ះពាល់ដែល



អនុលេខាបក្សកុម្មុយនីស្តកម្ពុជា នួន ជា កំពុងដឹកនាំ

នាំទៅរកអស្ថិរភាពផ្នែកនយោបាយ ។ ឯកអគ្គរាជទូតប្រទេសជប៉ុន ម៉ាសាគី សៃតូ ក៏មានគោលបំណងក្នុងការបង្រួមចំនួនតូចរបស់មេដឹកនាំខ្មែរក្រហមដើម្បីយកមកកាត់ទោសដែរដោយធ្វើឲ្យករណីនេះទៅគ្រាន់តែជាមេដឹកនាំខ្មែរក្រហមដែលមិនបានចុះចូល និងចុះចាញ់ជាមួយរដ្ឋាភិបាល ឬមេដឹកនាំណាដែលត្រូវបានផ្តល់ការលើកលែងទោស និងមិនត្រូវកាត់ទោសនរណាដែលបានបញ្ចូលទៅក្នុងសង្គមកម្ពុជាទេ ។ ក្នុងករណីនេះ អៀង សារី និង កែ ពក មិនត្រូវបញ្ចូលទៅក្នុងមេដឹកនាំខ្មែរក្រហម ដែលនឹងត្រូវយក

មកកាត់ទោសទេ ។ ការអះអាងរបស់ឯកអគ្គរាជទូត ម៉ាសាគី សៃតូ គឺមានលក្ខណៈនយោបាយដោយបញ្ជាក់ថា មានតែមេដឹកនាំមួយចំនួនតូចប៉ុណ្ណោះដែលអាចធ្វើឲ្យប្រទេសមានអស្ថិរភាព និងជាឧបសគ្គក្នុងការរិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការលើកទឹកចិត្តខ្មែរក្រហមផ្សេងទៀត ដែលមិនទាន់ផ្តាច់ខ្លួនចូលពីតំបន់ដែលកាន់កាប់ដោយខ្មែរក្រហម ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស ខេង បានប្រកាសស្រដៀងគ្នានោះដែរថា អ្នកដែលត្រូវបានលើកលែងទោស ឬអ្នកដែលបានផ្តាច់ខ្លួនចូលជាមួយរដ្ឋាភិបាលមិនគួរនិងត្រូវកាត់ទោសទេ យ៉ាងហោចណាស់អ្នកនោះចុះចូលជាមួយ



ការអប់រំដល់សមាជិកបក្ស

រដ្ឋាភិបាលត្រឹមឆ្នាំ១៩៩៨ បើមិនដូច្នោះទេនិងមានអស្ថិរភាពនយោបាយបើសិនជាត្រូវកាត់ទោសចំនួនច្រើនហួស ។ ចៅក្រមឡាឡុះ បានឆ្លើយតបទៅវិញ ខណៈពេលដែលគាត់ក៏យល់អំពីសារសំខាន់ក្នុងការមិនកាត់ទោសមេដឹកនាំខ្មែរក្រហមដែលបានផ្តល់ការលើកលែងទោសរួចហើយ ឬមេដឹកនាំដែលបានផ្តាច់ខ្លួនចូលជាមួយរដ្ឋាភិបាល ក្នុងនោះក៏មានសារសំខាន់ដូចគ្នាដែរថា ឯករាជ្យភាពរបស់ព្រះរាជអាជ្ញានិងត្រូវរក្សាផងដែរទោះបីជាមានហេតុផលផ្នែកនយោបាយក៏ដោយ ។

នៅឯសន្និសីទសារព័ត៌មានមួយនាទីបញ្ចប់នៃដំណើរទស្សនកិច្ចរបស់ក្រុមអ្នកជំនាញ ប្រធានក្រុមការងារគឺ នីនៀន ស៊ីហ៊ិន បានគូសបញ្ជាក់អំពីអ្វីដែលគាត់ចង់បកស្រាយ ។ នីនៀន ស៊ីហ៊ិន បានបញ្ជាក់ថា ភ័ស្តុតាងបញ្ជាក់ថា មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមានចំនួនប្រហែលជា៥នាក់ ១០នាក់ ឬ ១៥នាក់ ប៉ុន្តែក្នុងនោះក៏មានមេដឹកនាំខ្មែរក្រហមរាប់រយរាប់ពាន់នាក់ផ្សេងទៀតដែលជាប់ពាក់ព័ន្ធនិងបទល្មើសដែរ ។ គាត់បានបញ្ជាក់ទៀតថា គម្រោងនៃការកាត់ទោសតាមចំនួនតិចតួចនេះ វាផ្ទុយទៅនិងករណីរបស់ប្រទេសរ៉្វាន់ដា ដែលការកាត់ទោសរួមបញ្ចូលទាំងត្រីតូចៗដែលបានទទួលបញ្ជា និងប្រព្រឹត្តបទល្មើសរំលោភច្បាប់ព្រហ្មទណ្ឌអន្តរជាតិ តែត្រូវបានឃុំខ្លួននៅក្នុងប្រទេស ។ ស៊ីហ៊ិន បានបញ្ជាក់ថា ការកាត់ទោសនៅក្នុងប្រទេសកម្ពុជានឹងមិនសំដៅទៅលើកម្មាភិបាលតូចតាច ហើយក៏នឹងមិនកាត់ទោសកម្មាភិបាលរាប់ពាន់នាក់ដែលកាន់តំណែងថ្នាក់កណ្តាលដែរ ។ គាត់ក៏បានបញ្ជាក់ដែរថា ការចោទប្រកាន់ទោសនិងផ្អែកទៅលើភ័ស្តុតាងដែលបានស៊ើបអង្កេត ។ ក្រុមអ្នកជំនាញបានគូសបញ្ជាក់ថា ការចម្រាញ់រកមើលបេក្ខជនដែលនិងត្រូវកាត់ទោសនៅតុលាការគឺផ្អែកទៅលើក្រុមស៊ើបអង្កេតឯករាជ្យពេញលេញដែលរាយការណ៍ទៅព្រះរាជអាជ្ញាឯករាជ្យ ព្រមទាំងចៅក្រមដែលមានឯករាជ្យភាពប្រាសចាកពីសម្ពាធនានា ។ អ្នកទាំងអស់នេះធ្វើការងារប្រកបដោយវិចារណញ្ញាណឲ្យឯករាជ្យភាពនិងភាពស្មោះត្រង់ ។

ស៊ីហ៊ិន បានចាត់ថ្នាក់កម្មាភិបាលខ្មែរក្រហមជាបីកម្រិត មិនខុសគ្នាទៅនិងការចាត់ប្រភេទដោយរណសិរ្សរំដោះជាតិក្នុងខែធ្នូ ឆ្នាំ១៩៧៨ ដោយរដ្ឋាភិបាលកម្ពុជា រដ្ឋកម្ពុជា នៅក្នុងការបង្កើតរដ្ឋាភិបាលថ្មីៗនេះដែលត្រូវបានទទួលស្គាល់ដោយការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ កាលពីខែវិច្ឆិកា ឆ្នាំ១៩៩៦ ។ ទស្សនៈរបស់ ស៊ីហ៊ិន ហាក់បីដូចជាប្រមូលទស្សនៈរួមមួយរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា រដ្ឋកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជានាពេលនោះ ដោយកាត់ទោសតែមេដឹកនាំជាន់ខ្ពស់ ហើយគាត់ក៏ប្រមូលទស្សនៈរបស់សហរដ្ឋអាមេរិកទាក់ទងទៅនឹងមេដឹកនាំជាន់ខ្ពស់ដែរ ។ ក្រោយមក ស៊ីហ៊ិន បានសម្រេចសន្និតយកមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់និងកម្មាភិបាលធម្មតា ដែលស្ថិត

ជំហានទីពីរ ។ ផ្នែកកិច្ចការផ្ទៃក្នុងរបស់ក្រុមអ្នកជំនាញវិញ ក្រុមនេះបាននិយាយអំពីរចនាសម្ព័ន្ធដែលរាប់ចាប់ពីកម្មាភិបាលកម្រិតខ្ពស់បំផុតថ្នាក់ដឹកនាំផ្នែកនយោបាយនិងយោធា ចុះទៅកម្មាភិបាលក្រោមបន្ទាប់ថ្នាក់ស្រុក និងចុះទៅរហូតដល់ថ្នាក់ភូមិផង ។

គំនូសព្រាងនៃគណៈអចិន្ត្រៃយ៍ដែលមានបីថ្នាក់ត្រូវបានអះអាងឡើងម្តងទៀតដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងខែមករា ឆ្នាំ១៩៩៩ នៅពេលដែលគាត់ចេញសេចក្តីថ្លែងការណ៍មួយដើម្បីធ្វើការពន្យល់ពីសេចក្តីសម្រេចរបស់គាត់ក្នុងការស្វាគមន៍អ្នកដែលបានផ្តាច់ខ្លួនចូលជាមួយរដ្ឋាភិបាល ហើយមិនបានស្វាគមន៍អ្នកដែលបានចាប់ខ្លួនទេ ហើយក៏និងមិនកាត់ទោសអ្នកដែលមានឋានៈតូចតាចដែរ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានចាត់ទុក នួន ជា និង ខៀវ សំផន ថាជាមេដឹកនាំកំពូល ។ នៅក្នុងបុព្វបទនេះ ហ៊ុន សែន បានសន្យាថា គាត់និងមិនចោទប្រកាន់អ្នកនេះឬអ្នកនោះជំនួសឲ្យព្រះរាជអាជ្ញារបស់តុលាការក្នុងការកាត់ទោសបទឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជាទេ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាក់បន្ថែមទៀតថា ការផ្តួចផ្តើមករណីនៃការចោទប្រកាន់គឺជាសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា មិនមែនជាកតព្វកិច្ចរបស់គាត់ទេ ហើយនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបន្តទៀតថាក្នុងនាមអ្នកនយោបាយ យើងគួរតែធ្វើកិច្ចការរបស់យើងតាមអ្វីដែលច្បាប់កំណត់ ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានបន្ថែមទៀតថា គាត់នឹងមិនហ៊ានធានាថានឹងមិនកាត់ទោសចំពោះនរណាម្នាក់ទេ មិនថាអ្នកនោះមានទំនាក់ទំនងជិតស្និទជាមួយគាត់យ៉ាងណាក៏ដោយ ។ ម្យ៉ាងវិញទៀត នៅក្នុងអនុស្សារណៈមួយផ្ញើជូនអង្គការសហប្រជាជាតិកាលពីថ្ងៃទី២១ ខែមករា នាយករដ្ឋមន្ត្រី ហ៊ុន សែន បាននិយាយអំពីការនាំត្រឹមតែមេដឹកនាំកំពូលប៉ុណ្ណោះដែលនិងត្រូវនាំទៅកាន់តុលាការ ។ ពេលនេះ សហរដ្ឋអាមេរិកកំពុងតែបន្តជាសាធារណៈចំពោះគំនិតក្នុងការចែកឲ្យដាច់រវាងមេដឹកនាំជាន់ខ្ពស់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា និងមេដឹកនាំផ្សេងទៀតដោយចាត់ថ្នាក់ នួន ជា, ម៉ុក និង ខៀវ សំផន ជាមេដឹកនាំថ្នាក់ខ្ពស់នៅក្នុងបក្ស ហើយបញ្ជាក់ទៀតថា ក្តីបារម្ភសំខាន់គឺសំដៅការកាត់ទោសនៅក្នុងកម្រិតខ្ពស់នោះ ។ ប៉ុន្តែ មន្ត្រីសហរដ្ឋអាមេរិកមួយរូបបានពង្រីករូបមន្តនៃការកាត់ទោសច្រើនជាងមុន នៅពេលដែលគាត់បញ្ជាក់ថា ការផ្តោតរបស់រដ្ឋាភិបាលរបស់គាត់គឺសំដៅទៅលើការនាំជនដែលទទួលខុសត្រូវខ្ពស់បំផុតពីបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលបានប្រព្រឹត្តបទល្មើសក្នុងទសវត្សរ៍៧០ ទៅកាន់តុលាការ ។ នៅកិច្ចប្រជុំជាមួយការិយាល័យច្បាប់របស់អង្គការសហប្រជាជាតិកាលពីខែកុម្ភៈ ឆ្នាំ១៩៩៩ សហរដ្ឋអាមេរិកបានពន្យល់ថា ខ្លួនពេញចិត្តនឹងការកាត់ទោសមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហម ប៉ុន្តែខ្លួនក៏ចង់ធ្វើការស៊ើបអង្កេតឲ្យបានទូលំទូលាយជាងនេះដែរទាក់ទងទៅនឹងដំណើរការកាត់ទោសនេះ ។ នេះសបញ្ជាក់ពីគោលជំហររបស់សហរដ្ឋអាមេរិក ទោះបីនេះគឺជាកិច្ចដំណើរការចាប់ផ្តើមក៏ដោយ តែជំហរនេះគឺជាគោលបំណងដ៏ជាក់លាក់មួយ ។ នៅក្នុងជំនួបជាមួយមន្ត្រីចិនម្នាក់ ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាម ដេវីឌ សេហ្វើ បានស្នើឲ្យមានការនាំខ្លួនមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមចំនួនប្រហែលជាដប់នាក់ទៅកាន់តុលាការដោយមានរាជរដ្ឋាភិបាលកម្ពុជាជាអ្នកស្នើឈ្មោះនោះទៅកាន់តុលាការ និងបន្ថែមឈ្មោះប្រហែលជាបួននាក់ទៀតដែលសហរដ្ឋអាមេរិកបន្ថែមទៅនិងចំនួននៅក្នុងបញ្ជីរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលមានចំនួនប្រាំបីនាក់ដែលនៅក្នុងនោះប្រាំមួយនាក់កំពុងរស់រានមានជីវិតនៅពេលនោះ ។

សេចក្តីថ្លែងការណ៍និងការផ្លាស់ប្តូរកិច្ចសន្យានេះស្របគ្នាទៅនិងរបាយការណ៍ដែលបានសរសេរដោយក្រុមអ្នកជំនាញ ដែលរបាយការណ៍នោះត្រូវបានបញ្ចប់និងបញ្ជូនទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ និងនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩៩ ក្រោយមក ទើបរបាយការណ៍នោះត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅខែមិនា ឆ្នាំ១៩៩៩ ។ ក្នុងការបកស្រាយហេតុការណ៍ពិត និងអំពីប្រវត្តិផ្លូវច្បាប់ របាយការណ៍នោះបានរៀបរាប់ថា រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជារួមមាន រដ្ឋាភិបាល យោធា និងការិយាល័យរដ្ឋបាលបក្ស ដែលដឹកនាំដោយមជ្ឈិមនៅក្នុងទីក្រុងភ្នំពេញ ហើយខាងក្រោមនោះទៀតមាន ភូមិភាគ តំបន់ ស្រុក ឃុំ និង សហករណ៍ ។ របាយការណ៍នោះក៏បានកត់សម្គាល់ឃើញថា នៅមិនទាន់មានភាពច្បាស់លាស់នៅឡើយត្រង់ថា

តើការគ្រប់គ្រងកម្មាភិបាលថ្នាក់ក្រោមរបស់មជ្ឈិមបក្ស មានប្រសិទ្ធភាពប៉ុណ្ណា ។ ដោយវិភាគទៅលើភាពលម្អិតទាំងអស់នេះ របាយការណ៍នោះបានបង្កើតនូវរូបភាពនៃរចនាសម្ព័ន្ធបីថ្នាក់នៃមេដឹកនាំកំពូលរបស់ខ្មែរក្រហម មេដឹកនាំផ្សេងទៀត និងជនប្រព្រឹត្តបទល្មើសផ្ទាល់ ។ របាយការណ៍នោះសំដៅទៅលើរបបមួយរួមមាន ថ្នាក់ដឹកនាំកំពូលដោយសំដៅទៅលើ ប៉ុល ពត ដែលបានស្លាប់ទៅហើយជាថ្នាក់ដឹកនាំរបស់របបនោះ ក្រោយមកមានមេដឹកនាំជាន់ខ្ពស់ ហើយចាត់ថ្នាក់ នួន ជា, ម៉ុក និង ខៀវ សំផនគឺជាសមាជិកជាន់ខ្ពស់របស់របបនោះដែរ រួមទាំងមេដឹកនាំជាន់ខ្ពស់ឬមន្ត្រីជាន់ខ្ពស់បំផុត ។

របាយការណ៍នោះបានបញ្ចូលមេដឹកនាំខាងលើនេះនៅក្នុងសញ្ញាណដែលមានភាពទូលាយមួយនៃថ្នាក់ដឹកនាំ ឬក៏មេដឹកនាំដែលជាប់ពាក់ព័ន្ធនិងបទឧក្រិដ្ឋជាច្រើន ។ បើនិយាយពីពាក្យថាថ្នាក់ដឹកនាំតំបន់ឬថ្នាក់ដឹកនាំឃុំរបាយការណ៍នោះបានរៀបរាប់ថាអង្គភាពនៅគ្រប់កម្រិតទាំងអស់សុទ្ធតែមានថ្នាក់ដឹកនាំរបស់ខ្លួនដែលរៀបចំជាគណៈកម្មាធិការដែលបង្កើតដោយបក្សកុម្មុយនីស្តកម្ពុជា ហើយរួមមានមេដឹកនាំជាច្រើននៅកម្រិតភូមិភាគ ។ របាយការណ៍នោះហាក់បីដូចជាដឹងថា រដ្ឋាភិបាលមជ្ឈិមរបស់កម្ពុជាប្រជាធិបតេយ្យ គឺជាអង្គភាពមួយដែលមានភាពប្រហាក់ប្រហែលគ្នាទៅនឹងគណៈមជ្ឈិមដែរ ដែលប្រហែលជាឋានៈក្រោមបំផុតក្នុងការយកមកកាត់ទោស ។ ក្នុងនោះដែរ ក៏មានការជជែកគ្នាទៅលើឃ្លាទាក់ទងទៅនឹងមេបញ្ជាការយោធាដែរ ព្រមទាំងថ្នាក់ដឹកនាំដែលមិនមែនជាយោធាដែលឃ្លានោះគឺសំដៅទៅលើថ្នាក់ដឹកនាំទាំងពីរថ្នាក់ខាងលើក្នុងការដែលអាចនឹងយកមកកាត់ទោសដែរ ។ របាយការណ៍នោះបានរៀបរាប់ពីកម្មាភិបាលរបស់ភូមិភាគបូព៌ាដែលបានគេចខ្លួនពីយុទ្ធនាការបោសសម្អាតហើយបានជ្រកកោននៅប្រទេសវៀតណាមក្រោយខែឧសភា ឆ្នាំ១៩៧៨ ថាជាថ្នាក់ដឹកនាំភូមិភាគ ។ ដោយសារតែឋានៈខ្ពស់បំផុតរបស់កម្មាភិបាលទាំងនោះគឺជាសមាជិករបស់គណៈកម្មាធិការភូមិភាគនិងគណៈកម្មាធិការតំបន់ ហើយក៏អាចជាគណៈកម្មាធិការស្រុកហើយក្រុមអ្នកជំនាញ ប្រហែលជាចាត់ថ្នាក់មេដឹកនាំទាំងអស់នេះជាកម្មាភិបាលដែលស្ថិតក្នុងឋានៈតែមួយគឺមេដឹកនាំភូមិភាគ ។ របាយការណ៍នោះក៏បង្ហាញពីចំណាប់អារម្មណ៍ចំពោះការដែលបង្កើតឲ្យមានមន្ទីរស-២១ ចុះទៅក្រោម រហូតដល់ថ្នាក់ស្រុកទៀត ហើយរបាយការណ៍នោះបានបញ្ជាក់ថាកម្មាភិបាលថ្នាក់មូលដ្ឋានគឺជាអ្នកសម្រេចពីអាយុជីវិតរបស់ប្រជាជន ។ នៅពេលជាមួយគ្នានោះដែរ របាយការណ៍នោះក៏បែងចែកគ្នា រវាងអ្នកដែលប្រព្រឹត្តបទល្មើសផ្ទាល់ និងអ្នកដែលបញ្ជាអ្នកទាំងនោះក្នុងការប្រព្រឹត្តបទល្មើស ។ បើតាមរូបមន្តបញ្ច្រាសមកវិញ រវាងថ្នាក់ដឹកនាំនិងកម្មាភិបាលថ្នាក់ទាបបំផុតដែលជាអ្នកប្រព្រឹត្តបទល្មើសតាមតែបញ្ជា ឬក៏បើមិនបញ្ជាក៏ដោយថ្នាក់ដឹកនាំក៏ដឹងពីរឿងនេះដែរ ។

ប៉ុន្តែ របាយការណ៍នោះក៏បានបញ្ជាក់ផងដែរថា មិនមែនមេដឹកនាំទាំងអស់ទេដែលមានភាពគ្រប់គ្រាន់ក្នុងការចោទប្រកាន់ពីបទឧក្រិដ្ឋដើម្បីនាំយកអ្នកទាំងនោះទៅកាត់ទោស ។ នៅក្នុងផ្នែក "ប្រវត្តិ" របស់របាយការណ៍នោះបានសន្និដ្ឋានថា អំពើឃោរឃៅរបស់ខ្មែរក្រហមដែលបានប្រព្រឹត្ត ដោយកម្មាភិបាលគ្រប់កម្រិតដែលមានអំណាចក្នុងការប្រព្រឹត្ត ។ របាយការណ៍នោះបានបញ្ចប់សេចក្តីសន្និដ្ឋានរបស់ខ្លួនថា តាមផ្លូវច្បាប់ការរកឃើញដ៏ច្បាស់លាស់ទាក់ទងទៅនឹងកំហុសរបស់បុគ្គលតម្រូវឲ្យមានការពិនិត្យពិច័យទៅលើភស្តុតាងលម្អិតទាំងអស់ ។ ច្បាប់អន្តរជាតិបញ្ជាក់ថាករណីនេះគឺជាការចាំបាច់ដែលត្រូវចាំថា ទាក់ទងទៅនិងមេដឹកនាំច្បាប់អន្តរជាតិបានទទួលស្គាល់មនុស្សដែលត្រូវទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនទោះបីអ្នកទាំងនោះមិនប្រព្រឹត្តផ្ទាល់ក៏ដោយ ហើយច្បាប់អន្តរជាតិបញ្ជាក់ទៀតថា ការទទួលខុសត្រូវលើបទឧក្រិដ្ឋកម្មមិនមែនគ្របដណ្តប់ត្រឹមតែ "មេបញ្ជាការយោធាឬមេដឹកនាំដែលមិនមែនជាយោធា" ដែលបញ្ជាឲ្យអ្នកផ្សេងប្រព្រឹត្តបទល្មើសប៉ុណ្ណោះទេ ប៉ុន្តែត្រូវតែទទួលខុសត្រូវផងដែរចំពោះជនណាដែល "បានដឹងឬអំពើឃោរឃៅត្រូវបានប្រព្រឹត្ត ឬក៏ហៀបនឹងប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់ ហើយមិនចាត់វិធានការដើម្បីទប់ស្កាត់បញ្ឈប់ និងក៏ដាក់ទណ្ឌកម្មអ្នកប្រព្រឹត្ត" ។ ចំណុចនេះហាក់បីជាចែកគ្នាដាច់រវាងមេដឹកនាំផ្ទាល់ដែលទទួលបទបញ្ជា និងមេដឹកនាំជាន់ខ្ពស់ ដែលជាមេរបស់ខ្លួន ។ តាមស្ថានភាពពិតនិងផ្លូវច្បាប់ កថាខណ្ឌមួយរបស់របាយការណ៍អំពីគោលដៅនៃការស៊ើបអង្កេតខិតខំប្រឹងប្រែងដើម្បីបំពេញគោលបំណងសំខាន់ ដែលមិន

បានបញ្ជាក់នៃការប្រើប្រាស់អំពីចំនួនមេដឹកនាំខ្មែរក្រហមដែលនិងត្រូវយកមកកាត់ទោសដើម្បីបញ្ជាក់ពីវិសាលភាពនៃជនសង្ស័យនិងជាគោលដៅនៅក្នុងដំណើរការបន្តពីការបរិច្ចេទនៃក្របខ័ណ្ឌ ខ្មែរក្រហម ។

ក្នុងការពិភាក្សាអំពីលទ្ធភាពនៃការនាំយកមេដឹកនាំខ្មែរក្រហមទៅកាត់ទោសហាក់បីដូចជាមើលឃើញថា អំពើឃោរឃៅក្នុងជំនាន់ខ្មែរក្រហមត្រូវបានប្រព្រឹត្តដោយបុគ្គលរាប់ពាន់នាក់ គ្រប់ឋានៈទាំងអស់ទូទាំងប្រទេស តែការពិភាក្សានោះនៅតែប្រកាន់ជំហរថា មេដឹកនាំនៅថ្នាក់ក្រោមដែលជាអ្នកប្រព្រឹត្តបទល្មើសនិងមិនត្រូវយកមកពិចារណាក្នុងការយកមកកាត់ទោសពីបទឧក្រិដ្ឋរបស់ខ្លួនទេ ។ ពេលងាកទៅពិភាក្សាអំពីមេដឹកនាំជាន់ខ្ពស់និងមេដឹកនាំទូទៅវិញ ការពិភាក្សានោះបានសន្មតថា ថ្នាក់ដឹកនាំទាំងពីរថ្នាក់នេះនឹងយកមកពិចារណាជាបេក្ខជនដែលនឹងត្រូវយកមកកាត់ទោស ប៉ុន្តែត្រូវមានសេចក្តីព្រមព្រៀងច្បាស់លាស់អំពីភាពជាក់លាក់ និងសារសំខាន់ដែលគ្មាននរណាម្នាក់មិនអាចយកមកកាត់ទោសដោយសារតែអ្នកនោះមានឋានៈ នៅក្នុងជួរដឹកនាំទេ ។ មានការព្រមានមកថា បញ្ជីឈ្មោះមន្ត្រីរដ្ឋាភិបាលនិងមន្ត្រីបក្សជាន់ខ្ពស់គឺមិនទាក់ទងទៅនិងបញ្ជីឈ្មោះមនុស្សដែលជាអ្នកទទួលខុសត្រូវបំផុត ចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ព្រោះថាមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលមិនត្រូវបានផ្តល់សិទ្ធិក្នុងការដឹងពត៌និងការសម្រេចចិត្តអ្វីមួយទេ ហើយអ្នកផ្សេងទៀតដែលមិនមានឈ្មោះនៅក្នុងបញ្ជីក៏មិនមែនជាអ្នកប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរដែរ ។ ចំណុចនេះមានលក្ខណៈពិតប្រាកដដោយសំដៅទៅលើថ្នាក់ដឹកនាំភូមិភាគ និងកម្មាភិបាលដែលទទួលបន្ទុកខាងការធ្វើទារុណកម្ម និងសួរចម្លើយដូចជាគុកទួលស្លែង (ស-២១) ជាដើម ។ ជាជាងការឈានទៅរកផ្លូវច្បាប់ជាផ្លូវការមួយ ការពិភាក្សានោះផ្តល់អនុសាសន៍ថា ៖

តុលាការផ្តោតតែទៅលើអ្នកណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរបំផុតក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ មេដឹកនាំទាំងនេះ រួមមានមេដឹកនាំខ្ពស់បំផុតដែលមានការទទួលខុសត្រូវទៅលើការរំលោភសិទ្ធិមនុស្សព្រមទាំងអ្នកដែលនៅថ្នាក់ក្រោមដែលធ្លាប់ប្រព្រឹត្តអំពើឃោរឃៅដោយផ្ទាល់ចំពោះបទល្មើសធ្ងន់ធ្ងរ ។ យើងមិនផ្តល់ទូរលេខអំពីចំនួននៃអ្នកដែលត្រូវយកមកកាត់ទោស ដែលជាគោលដៅក្នុងការស៊ើបអង្កេតទេ ។ ទោះបីជានៅក្នុងស្មារតីរបស់ក្រុមអ្នកជំនាញដែលកើតចេញពីការប្រឹក្សានិងការស្រាវជ្រាវរកឃើញចំនួនពីម្ភៃទៅសាមសិបនាក់ក៏ដោយ ។

អនុសាសន៍ខាងលើនេះគួរតែត្រូវបកស្រាយនៅក្នុងផ្នែក “ប្រវត្តិ” នៃរបាយការណ៍ និងនៅក្នុងបុព្វបទទូទៅ ។ ហាក់បីដូចជាមានភាពច្បាស់លាស់ថា អ្នកដែលជាគោលដៅក្នុងការកាត់ទោសគួរតែជាមេដឹកនាំជាន់ខ្ពស់និងមេដឹកនាំដែលទទួលខុសត្រូវខ្ពស់បំផុតពីបទឧក្រិដ្ឋ ។ មេដឹកនាំជាន់ខ្ពស់នោះច្បាស់ណាស់ថាគឺសំដៅទៅលើសមាជិករបស់គណៈអចិន្ត្រៃយ៍និងគណៈមជ្ឈិម ហើយមេដឹកនាំជាន់ខ្ពស់បំផុតគឺសំដៅទៅលើថ្នាក់ដឹកនាំផ្សេងទៀតដែលមិនចាំបាច់តែជាសមាជិករបស់គណៈកម្មាធិការនេះទេ តែជាប្រធានឬជាសមាជិកគណៈកម្មាធិការណាមួយ នៅក្នុងអង្គភាពផ្សេងតែមិនមែននៅក្នុងថ្នាក់ភូមិភាគទេ ក្នុងនោះរួមមានគណៈកម្មាធិការរបស់មន្ទីរស-២១ និងក្រសួងនានារបស់កម្ពុជាប្រជាធិបតេយ្យ ។ ម្យ៉ាងវិញទៀតអាចបកស្រាយបានថា ថ្នាក់ដឹកនាំដែលមានជាប់ពាក់ព័ន្ធនិងបទឧក្រិដ្ឋដែលបញ្ជាក់ពីថ្នាក់លើ តែមិនសំដៅទៅលើថ្នាក់ដឹកនាំថ្នាក់ក្រោមបំផុតទេ ។ ***(នៅមានត)*** **ស៊ីង ហេងឌី**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷
ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: truthsocheat@dccam.org*
*Home page: www.dccam.org*

# កំណាប់ឯកសារជីវិត

រយៈពេលប្រាំបួនខែដែលខ្ញុំបានធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជានេះ ខ្ញុំដឹងរឿងរ៉ាវជាច្រើនដែលកើតឡើងនៅក្នុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៥-១៩៧៩ តាមរយៈការអានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទស្សនាវដ្តីស្វែងរកការពិតនិងឯកសារផ្សេងៗទៀតដែលរៀបរាប់អំពីការបាត់បងប្អូនសាច់ញាតិនៅក្នុងរបបនេះ ។ នៅពេលដែលខ្ញុំអានឯកសារទាំងអស់នេះ វាបានធ្វើឲ្យខ្ញុំនឹកឃើញទៅដល់សម្តីម្តាយខ្ញុំនិយាយប្រាប់ថា គាត់មានពូម្នាក់ឈ្មោះ ប៉ុល ជឿន បានបាត់ខ្លួននៅក្នុងរបបខ្មែរក្រហមដែរ ហើយគាត់នៅតែរំពឹងក្នុងចិត្តជានិច្ចថា ពូរបស់គាត់នៅមានជីវិតរស់នៅឡើយ ហើយនៅថ្ងៃណាមួយនឹងត្រឡប់មកផ្ទះវិញ ។ ថ្វីត្បិតតែខ្ញុំធ្វើការនៅទីនេះក៏ដោយ ប៉ុន្តែខ្ញុំមិនដែលគិតថា ខ្ញុំនឹងអាចរកដំណឹងតា ប៉ុល ជឿន ឃើញដែរ ព្រោះគាត់មិនអាចមានវាសនាដូចជាជនរងគ្រោះផ្សេងទៀតដែលខ្មែរក្រហមចាត់ទុកថាជាជនក្បត់អង្គការ ហើយបញ្ជូនមកសម្លាប់នៅមន្ទីរស-២១ ដែលជាគុកមជ្ឈិមរបស់ខ្មែរក្រហមទេ ។ ប៉ុន្តែអ្វីៗប្រែផ្ទុយស្រឡះពីការយល់ឃើញនិងជារឿងមួយដែលនឹកស្មានមិនដល់ ព្រោះខ្ញុំបែរជារកឃើញរូបថត ប្រវត្តិរូបនិងចម្លើយសារភាពរបស់គាត់ទៅវិញ ។ គុកទួលស្លែងដែលខ្មែរក្រហមចាត់ទុកជាគុកមជ្ឈិម និងមានអ្នកទោសប្រហែល១៤,០០០នាក់ត្រូវបានយកមកធ្វើទារុណកម្ម និងសម្លាប់នៅទីនោះ ក៏មានជីតាខ្ញុំម្នាក់ដែរ ។


ប៉ុល ជឿន

បន្ទាប់ពីខ្ញុំឃើញចម្លើយសារភាព ប្រវត្តិរូប និងរូបថតរបស់តា ប៉ុល ជឿន ទឹកភ្នែករបស់ខ្ញុំបែរជាស្រក់មកដោយមិនដឹងខ្លួន ហើយគិតថាតើគាត់បានធ្វើអ្វីខុសបានជាខ្មែរក្រហមយកគាត់ទៅសម្លាប់នៅគុកទួលស្លែងទៅ ដូច្នេះក្រៅពីអារម្មណ៍ទុក្ខសោកទាំងនេះ ខ្ញុំនឹកព្រួយបារម្ភថា តើខ្ញុំគួរតែនិយាយប្រាប់ម្តាយរបស់ខ្ញុំបែបណាអំពីការស្លាប់របស់លោកតា ប៉ុល ជឿន ។

ម្តាយរបស់ខ្ញុំមានឈ្មោះ នួន មករា មានបងប្អូនប្រាំពីរនាក់ (ស្រីប្រាំមួយនាក់ និងប្រុសមួយនាក់) ។ ឪពុករបស់គាត់ឈ្មោះ ប៉ុល ម៉េង និងម្តាយឈ្មោះ ញ៉ែម លឹម ។ គាត់មានស្រុកកំណើតនៅភូមិកន្ទោង ឃុំទឹកថ្លា ស្រុកព្រៃវែង ខេត្តព្រៃវែង ។ ក្រោយពីរបបខ្មែរក្រហមបានដួលរលំ ក្រុមគ្រួសាររបស់ម្តាយខ្ញុំបានព្យាយាមស្វែងរកដំណឹងរបស់តា ប៉ុល ជឿន តាមរយៈទស្សនាវដ្តី កាសែតវិទ្យុ ៧មករា និងធ្លាប់បានទៅរកនៅមន្ទីរស-២១ (គុកទួលស្លែង) ដែរ ប៉ុន្តែមិនដែលឃើញរូបថតរបស់គាត់ទាល់តែសោះ ។ ដោយអស់សង្ឃឹម និងមិនដឹងថារកតាមវិធីណាទៀត គ្រួសាររបស់ខ្ញុំបានទៅរកគ្រូទាយ ដើម្បីមើលថាតើគាត់នៅរស់ឬស្លាប់? ពេលនោះ គ្រូទាយឆ្លើយថា គាត់នៅរស់ ហើយមិនយូរទេ គាត់នឹងមករកបងប្អូនវិញហើយ ។ ម្តាយខ្ញុំសប្បាយចិត្តណាស់ ហើយសង្ឃឹមថាដូចជាពាក្យគ្រូទាយដែរ ។

ដោយសារតែគ្មានដំណឹងអ្វីសោះ នៅខែសីហា ឆ្នាំ២០១០ ម្តាយរបស់ខ្ញុំបានទៅរកគ្រូទាយម្តងទៀត ពេលនោះ គ្រូទាយបានប្រាប់ថា គាត់នឹងត្រឡប់មកវិញនៅខែធ្នូ ឆ្នាំ២០១១ ។ ម្តាយខ្ញុំមានអារម្មណ៍សប្បាយចិត្តម្តងទៀត ហើយបន់ឲ្យតែខែធ្នូ បានមកដល់ឆាប់ៗ ។ ពេលនេះខែធ្នូ ឆ្នាំ២០១១ បានមកដល់ហើយ ប៉ុន្តែក្តីសង្ឃឹមរបស់យើងបានរលាយសាបសូន្យទៅវិញ ដោយខ្ញុំបានត្រឹមតែឃើញរូបថត និងឯកសារដែលសរសេរជាប្រវត្តិរូបរបស់គាត់ថា ជាអ្នកទោសនៅគុកទួលស្លែង ។ ក្រោយពីខ្ញុំកាន់រូបថត និងចម្លើយសារភាពរបស់តា ប៉ុល ជឿន ទៅបង្ហាញម្តាយខ្ញុំ ក៏ដូចជាសមាជិកគ្រួសារឯទៀត ម្នាក់ៗតក់ស្លុតនិងរន្ធត់ជាខ្លាំងដោយសារតែទាំងអស់គ្នារំពឹងថា តា ប៉ុល ជឿន នៅរស់រានមានជីវិតនៅឡើយ ។ ពីមុនរហូតដល់ពេលនេះ ម្តាយរបស់ខ្ញុំគ្រាន់តែដឹងថា លោកតាបានចូលបដិវត្តន៍ខ្មែរក្រហមនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧០ នៅពេលនោះគាត់អាយុប្រហែល២៥ឆ្នាំ ។ នៅចុងឆ្នាំ១៩៧៦ គាត់បានមកលេងផ្ទះម្តង ក្រោយមកបាត់ដំណឹងរហូត ។ នៅក្នុងក្រុមគ្រួសារ តា ប៉ុល ជឿន គឺជាមនុស្សចិត្តល្អ ចេះជួយធុរៈគ្រួសារ និងបងប្អូនស្រឡាញ់ជាងគេ ។

ចំណែកប្អូនប្រុសរបស់គាត់ឈ្មោះ ប៉ុល អ៊ួង សព្វថ្ងៃអាយុ៦១ឆ្នាំ ហើយនៅពេលដែលគាត់ឃើញរូបថត និងប្រវត្តិរូបបងគាត់ ប៉ុល ជឿន ធ្វើឲ្យគាត់មានការសោកស្តាយ និងឈឺចាប់ជាទីបំផុត ហើយនិយាយទាំងអួលដើមកថា ហេតុអ្វីបងរបស់គាត់ត្រូវខ្មែរក្រហមចាប់ខ្លួនយកទៅសម្លាប់នៅទួលស្លែងទៅវិញ? ប៉ុល អ៊ួង បានបន្តថា “គាត់មិនអាចទទួលយកបានទេចំពោះរឿងនេះ ហើយក៏មិនជឿថាបងគាត់ចូលរួមធ្វើសកម្មភាពក្បត់រហូតដល់ចាប់ដាក់គុកទួលស្លែងដែរ ព្រោះគ្រួសារគាត់ជាគ្រួសារអ្នកស្រែចម្ការ មិនចេះក្បត់ ហើយមិនមានបក្សពួកធ្វើរដ្ឋប្រហារដែរ ។ ខ្មែរក្រហមគ្រាន់តែធ្វើការសន្មតដោយខ្លួនឯងថា អ្នកនេះ ឬអ្នកនោះក្បត់ ដើម្បីកម្ចាត់អ្នកណាដែលមានបំណងប្រឆាំងនឹងគោលនយោបាយដឹកនាំរបស់ខ្លួនប៉ុណ្ណោះ” ។

ក្រោយពីដឹងច្បាស់ថា តា ប៉ុល ជឿន ស្លាប់នៅគុកទួលស្លែង ក្រុមគ្រួសាររបស់ខ្ញុំគិតថានឹងជ្រើសរើសយកថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២ ដើម្បីធ្វើបុណ្យឧទ្ទិសកុសលឲ្យព្រលឹងរបស់គាត់ទៅកាន់សុគតិភព ព្រោះត្រូវជាថ្ងៃដែលគាត់ត្រូវខ្មែរក្រហមសម្លាប់ ។ ខណៈពេលជាមួយគ្នានេះដែរ គាត់ក៏សង្ឃឹមថា តុលាការនឹងដំណើរការកាត់ទោស មេដឹកនាំខ្មែរក្រហមឲ្យបានឆាប់ដើម្បីកុំឲ្យមេដឹកនាំទាំងនេះស្លាប់បាត់បង់ជីវិតមុនពេលការពិតត្រូវបានត្រដាង ហើយមេដឹកនាំទាំងនេះនឹងទទួលស្គាល់នូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តមិនមែនឆ្លើយដោះសា ហើយទម្លាក់កំហុសទៅឲ្យថ្នាក់ក្រោមដោយមិនទទួលខុសត្រូវនោះទេ ។

**ពៅ ពុទ្ធាទី**

# ដំណឹងស្វែងរកគ្រួសារ

ខ្ញុំបាទឈ្មោះ វង្ស ទ្រង់ ហៅ អួង ដេង ភេទប្រុស អាយុ៤៧ឆ្នាំ សព្វថ្ងៃរស់នៅផ្ទះលេខ ២៦៥A ផ្លូវ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ ក្រុងភ្នំពេញ ។ ខ្ញុំបាទសូមស្វែងរកគ្រួសារដែលបានបាត់ខ្លួនក្នុងរបបខ្មែរក្រហម ១) ឪពុកឈ្មោះ វង្ស ត្រុងយ៉ុង (ពេលបែកគ្នាអាយុប្រហែល៤៣ឆ្នាំ) ២) ម្តាយឈ្មោះ លឹម បូទី (កាលបែកគ្នាអាយុ៤០ឆ្នាំ) ៣) បងប្រុសទីមួយ មិនចាំឈ្មោះ ៤) បងប្រុសទីពីរ វង្ស បូឃី ឬ អួង បូឃី (កាលបែកគ្នាអាយុ១៨ឆ្នាំ) ៥) បងប្រុសទីបី វង្ស ម៉េង ឬ អួង ម៉េង (កាលបែកគ្នាអាយុ១៤ឆ្នាំ) ៦) ប្អូនប្រុសទីប្រាំ វង្ស រឿង ឬ អួង រឿន (កាលបែកគ្នាអាយុ៨ឆ្នាំ) ។ កាលពីមុនឆ្នាំ១៩៧៥ គាត់រស់នៅសង្កាត់លេខ៣ក្រុងភ្នំពេញ ត្រង់ផ្លូវសុខហុក កែងនឹងផ្លូវបត់ទៅផ្សារឌុយម៉ិច ។ ពេលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ គាត់ត្រូវបានជម្លៀសតាមបណ្តោយផ្លូវជាតិលេខ៤ ត្រង់ម្តុំពោធិចិនតុង ។

ប្រសិនបើបងប្អូនណាបានឮ ឬបានអានសេចក្តីប្រកាសនេះ សូមមេត្តាទំនាក់ទំនងមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២, ០៩២ ៤២៥ ៥៣៤ ឬ ០៧៧ ៦០៦ ០៣០ ឬអាសយដ្ឋានដូចខាងលើកុំបីខាន ។ សូមអរគុណ ។

# សេចក្ដីប្រកាសរកបងប្អូនឈ្មោះ តាំង មួយហ៊ាង និងគ្រួសារ

នាងខ្ញុំឈ្មោះ ឡាយ គីមឡាង អាយុ២៥ឆ្នាំ រស់នៅភូមិមណ្ឌល១ ឃុំមណ្ឌល១ ស្រុកស្វាយដង្គំ ខេត្តសៀមរាប ។ ឪពុករបស់ខ្ញុំឈ្មោះ ឡាយ ហាំងខេង ត្រូវជាបងប្អូនជីដូនមួយរបស់ តាំង ញឹក ។ តាំង ញឹក មានប្ដីឈ្មោះ តាំង ហ៊ួលី និងមានកូនប្រាំមួយនាក់ ១) តាំង មួយហ៊ាង ២) តាំង អួយស្រួយ (រស់នៅបាងកក ប្រទេសថៃ) ៣) តាំង ពាំងថាវ (រស់នៅសហរដ្ឋអាមេរិក) ៤) តាំង អូនតូច (រស់នៅបាង កក ប្រទេសថៃ) ៥) តាំង ហ៊ាង (រស់នៅបាងកក ប្រទេសថៃ) ៦) តាំង សុខនី (រស់នៅបាងកក ប្រទេសថៃ) ។ នាងខ្ញុំសូមប្រកាសសួររកឈ្មោះ តាំង មួយហ៊ាង និងប្ដី ណាំ ហុង ព្រមទាំងកូនស្រី ហ៊ួ ទៀង ដែលបានបាត់ខ្លួនពេលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ១៩៧៥ ។ មុនពេលបាត់ខ្លួន តាំង មួយហ៊ាង និង ណាំ ហុង រស់នៅផ្សារលើ ខេត្តកំពង់ឆ្នាំង និងប្រកបរបរលក់ការ៉េមបោះដុំ ។



ប្រសិនបើបងប្អូនណាបានឮ ឬបានអានសេចក្ដីប្រកាសនេះ សូមមេត្តាទំនាក់ទំនងមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០១២ ៨៦៣ ២៣៨ ឬអាសយដ្ឋានដូចខាងលើកុំបីខាន ។

**សូមអរគុណ ។**



# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ៈ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាសយដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 145, January 2012 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.